ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

# ការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា នៅឆ្នាំសិក្សា ២០២២-២០២៣ នៃមហាវិទ្យាល័យ វិទ្យាសាស្ត្រសេដ្ឋកិច្ច និងគ្រប់គ្រង

អនុគណកម្មការបច្ចេកទេស
បញ្ចូលទិន្នន័យ វិភាគ និងសរសេររបាយការណ៍

បណ្ឌិត ង៉ាន់ ស៊ុនដេត
លោក ឈាង ហ៊ុយ

ខែធ្នូ ឆ្នាំ២០២៤

# មាតិកា


**តារាង** ..... iii

**ក្រាភិច** ..... v

**ឧបសម្ព័ន្ធ** ..... vi

**សេចក្តីសង្ខេប** ..... 1

**លទ្ធផលនៃការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា** ..... 1

**ផ្នែកទី១. សេចក្តីផ្តើម** ..... 3

**១.១. សារសំខាន់នៃការសិក្សា** ..... 3

**១.២. វត្ថុបំណងនៃការសិក្សា** ..... 4

**១.៣. ការប្រើប្រាស់លទ្ធផលនៃការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សាកន្លងមក** ..... 4

**ផ្នែកទី២. វិធីសាស្ត្រនៃការសិក្សា** ..... 5

**២.១. វិធីសាស្ត្រប្រមូលទិន្នន័យ** ..... 5

**២.២. ក្រុមគោលដៅផ្តល់សម្ភាសន៍ (អ្នកចូលរួមឆ្លើយសំណួរនៃការសិក្សា)** ..... 5

**២.៣. ឧបករណ៍សម្រាប់ការសិក្សា និងការវិភាគទិន្នន័យ** ..... 5

**២.៤. វិសាលភាព និងដែនកំណត់នៃការសិក្សា** ..... 6

**២.៥. ក្រមសីលធម៌នៃការសិក្សា** ..... 6

**ផ្នែកទី៣. លទ្ធផលនៃការសិក្សា** ..... 7

**៣.១. ព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកចូលរួម** ..... 9

៣.១.១. អតីតសិស្សមកពីវិទ្យាល័យតាមរាជធានី និងខេត្ត ..... 9

៣.១.២. ចន្លោះអាយុរបស់និស្សិត ..... 10

៣.១.៣. អាសយដ្ឋានបច្ចុប្បន្នរបស់និស្សិត ..... 10

**៣.២. ព័ត៌មានពីការសិក្សា** ..... **11**

៣.២.១. ការចុះកម្មសិក្សា ឬហាត់ការ និងការទទួលបានប្រាក់ចំណូល ..... 11

៣.២.២. សេចក្តីពេញចិត្តចំពោះកម្មវិធីសិក្សាដែលអាចឆ្លើយតបទីផ្សារការងារ ..... 14

**៣.៣. ព័ត៌មានពីកម្មវិធីសិក្សា** ..... **15**

៣.៤. ព័ត៌មានពីស្ថានភាពការងារ ..... 18
៣.៤.១. ប្រភេទការងាររបស់និស្សិត ..... 19
៣.៤.២. ប្រភេទកិច្ចសន្យាការងារ ..... 19
៣.៤.៣. ការបង្កើតសហគ្រាសផ្ទាល់ខ្លួន ..... 22
៣.៤.៤. ប្រភេទនៃស្ថាប័នអាជីវកម្មដែលនិស្សិតបញ្ចប់ការសិក្សាបាន និងកំពុងបំពេញការងារ ..... 23
៣.៤.៥. ការទទួលបានការងារធ្វើនៅកន្លែងការចុះកម្មសិក្សា ..... 24
៣.៤.៦. ទីកន្លែងដែលនិស្សិតទទួលបានការងារធ្វើ ..... 25
៣.៤.៧. ឋានៈការងារនៅក្នុងស្ថាប័ន ..... 26
៣.៤.៨. ភាពមានការងារធ្វើស្របជំនាញច្រើនជាង ឬតិចជាង៥0% នៃកម្មវិធីសិក្សា ..... 27
៣.៤.៩. ការទទួលបានប្រាក់ចំណូលប្រចាំខែ ..... 31
៣.៤.១០. ករណីនានាដែលមិនទាន់មានការងារធ្វើ ..... 35
៣.៤.១១. រយៈពេលនៃការស្វែងរកការងារធ្វើបន្ទាប់ពីបញ្ចប់ការសិក្សា ..... 36
៣.៤.១២. ការចំណាយពេលដើម្បីទទួលបានការងារស្របជំនាញ ..... 39
៣.៤.១៣. ការបង្កើតសហគ្រាសផ្ទាល់ខ្លួន ..... 40
៣.៥. ព័ត៌មានពីតម្រូវការមុខជំនាញ ..... 43
៣.៥.១. តម្រូវការបំណិនជំនាញសម្រាប់ការងារដែលកំពុងធ្វើបច្ចុប្បន្ន ..... 45
៣.៦. ព័ត៌មានពីមតិយោបល់របស់អ្នកចូលរួម ..... 49
៣.៦.១. ការជួយនិស្សិតដើម្បីទទួលបានការងារ ..... 49
៣.៦.២. ការបណ្តុះបណ្តាលបន្ថែមនៅកន្លែងការងារ ..... 50
៣.៦.៣. ការសិក្សាបន្តទៅកម្រិតសញ្ញាបត្រផ្សេងទៀត ..... 51
៣.៦.៤. ការគាំទ្រដល់ការសិក្សាជំនាញខ្លីៗ ..... 52
៣.៦.៥. ការចូលរួមសកម្មភាពសង្គម ..... 52
ចំណុចខ្លាំង និងចំណុចខ្សោយខាត នៃកម្មវិធីបណ្តុះបណ្តាល ..... 55
ផ្នែកទី៤. សេចក្តីសន្និដ្ឋាន និងអនុសាសន៍ ..... 57
៤.១. ការសន្និដ្ឋាន ..... 57
៤.២. អានុសាសន៍ ..... 57
ផែនការសម្រាប់ឆ្នាំ២០២៥ និងសំណូមពរ ..... 57
ឯកសារយោង ..... 58
ឧបសម្ព័ន្ធ ..... 59

# តារាង


តារាង 1 . ភាពមានការងារធ្វើរបស់និស្សិតឆ្នាំសិក្សា២០២០-២១, ២០២១-២២និងឆ្នាំសិក្សា២០២២-២០២៣. 7

តារាង 2 ភាពមានការងារធ្វើរបស់និស្សិតក្នុងអំឡុងពេល៨ឆ្នាំចុងក្រោយ (ឆ្នាំសិក្សាបញ្ចប់) ........ 7

តារាង 3 អតីតសិស្សមកពីវិទ្យាល័យតាមរាជធានី និងខេត្ត........ 9

តារាង 4 ចន្លោះអាយុរបស់និស្សិត ........ 10

តារាង 5 ខេត្តដែលជាអាសយដ្ឋានបច្ចុប្បន្នរបស់និស្សិត........ 11

តារាង 6 ការចុះកម្មសិក្សា ឬហាត់ការ ........ 12

តារាង 7 តេសលទ្ធផល........ 13

តារាង 8. តេស្តលទ្ធផល........ 14

តារាង 9 កម្រិតសេចក្តីពេញចិត្តរបស់និស្សិតចំពោះកម្មវិធីសិក្សាតាមតម្រូវការទីផ្សារតាមជំនាញ........ 15

តារាង 10 ចំណាត់ថ្នាក់បំណិនរបស់និស្សិតបញ្ចប់ការសិក្សា........ 16

តារាង 11 ការផ្តល់ចំណាត់ថ្នាក់រវាងទ្រឹស្តីទៅនឹងការអនុវត្តការងារបច្ចុប្បន្ន........ 17

តារាង 12 ការផ្តល់ការពេញចិត្តការអនុវត្តន៍ជំនាញក្នុងពេលសិក្សាមានសារៈសំខាន់ចំពោះការងារបច្ចុប្បន្ន........ 18

តារាង 13 ប្រភេទការងាររបស់និស្សិត........ 19

តារាង 14 ការបង្កើតសហគ្រាសផ្ទាល់ខ្លួន........ 19

តារាង 15 ការបង្កើតសហគ្រាសផ្ទាល់ខ្លួន........ 22

តារាង 16 ស្ថានភាពការងារនៅតាមស្ថាប័ន ........ 23

តារាង 17 ចំនួននិស្សិតទទួលបានការងារធ្វើនៅកន្លែងដែលធ្លាប់បានចុះទៅធ្វើកម្មសិក្សា........ 24

តារាង 18 ទីកន្លែងដែលនិស្សិតទទួលបានការងារធ្វើ........ 25

តារាង 19 ភាពមានការងារធ្វើស្របតាមជំនាញ........ 28

តារាង 20 តេស្តលទ្ធផលទាក់ទងការផ្តល់ប្រាក់ឈ្នួលតាមភេទ និងធ្វើការត្រូវតាមជំនាញ ........ 34

តារាង 21 តេស្តលទ្ធផល........ 39

តារាង 22 រយៈពេលទទួលបានការងារធ្វើស្របជំនាញ........ 39

តារាង 23 តម្រូវការបំណិនជំនាញសម្រាប់ការងារ ........ 45

តារាង 24 តេស្តលទ្ធផលទាក់ទងជាមួយបំណិតលើជំនាញនីមួយៗ........ 46

តារាង 25 តេស្តលទ្ធផលទាក់ទងជាមួយបំណិតនៃការសម្រេចចិត្តលើជំនាញនីមួយៗ........ 47

តារាង 26 តេស្តលទ្ធផលទាក់ទងជាមួយបំណិតនៃការសម្រេចចិត្តលើជំនាញនីមួយៗ........ 47

តារាង 27 តេស្តលទ្ធផលទាក់ទងជាមួយបំណិតនៃការសម្រេចចិត្តលើជំនាញនីមួយៗ........ 47

តារាង 28 កម្រិតប្រែប្រួលនៃការប្រើប្រាស់ចំណេះដឹងក្នុងការងារធៀបនឹងសញ្ញាបត្រជំនាញ........ 48

តារាង 29 ការជួយនិស្សិតដើម្បីទទួលបានការងារ ........ 50

**តារាង 30 តេស្តលទ្ធផល** ...... 50
**តារាង 31 ការបណ្តុះបណ្តាលបន្ថែមនៅកន្លែងការងារ** ...... 50
**តារាង 32 ការសិក្សាបន្តទៅកម្រិតសញ្ញាបត្រផ្សេងទៀត** ...... 51
**តារាង 33 ការគាំទ្រដល់ការសិក្សាបន្តលើជំនាញខ្លីៗ** ...... 52
**តារាង 34 ការចូលរួមសកម្មភាពសង្គម** ...... 53
**តារាង 35 តេស្តលទ្ធផល** ...... 53
**តារាង 36 ការវិភាគលទ្ធផលទៅនឹងក្របខ័ណ្ឌគុណវុឌ្ឍិជាតិ** ...... 54

# ក្រាភិច

ក្រាភិច 1 បម្រែបម្រួលភាពមានការងារធ្វើរបស់និស្សិតនៅពេលឆ្នាំចុងក្រោយ ....................................................8
ក្រាភិច 2 ការចុះកម្មសិក្សា/ហាត់ការ និងការទទួលបានចំណូល ....................................................13
ក្រាភិច 3 កម្រិតសេចក្តីពេញចិត្តរបស់និស្សិតចំពោះកម្មវិធីសិក្សា....................................................14
ក្រាភិច 4 កម្រិតវាយតម្លៃនៃការផ្សារភ្ជាប់រវាងទ្រឹស្តីនិងការអនុវត្ត ....................................................18
ក្រាភិច 5 ភាគរយនិស្សិតទទួលបានការងារធ្វើតាមវិស័យ....................................................24
ក្រាភិច 6 ភាគរយនៃនិស្សិតដែលត្រូវបានស្ថាប័នទទួលយកមកធ្វើការវិញកាលពីបានមកចុះកម្មសិក្សា............24
ក្រាភិច 7 ស្ថានភាពនៃឋានៈការងារ....................................................27
ក្រាភិច 8 ភាគរយធ្វើការស្របជំនាញ និងមិនស្របជំនាញ....................................................29
ក្រាភិច 9 ភាពមានការងារធ្វើមិនស្របតាមជំនាញ ....................................................30
ក្រាភិច 10 ប្រាក់ចំណូលប្រចាំខែ ....................................................34
ក្រាភិច 11 ករណីនានាដែលមិនទាន់មានការងារធ្វើ....................................................36
ក្រាភិច 12 រយៈពេលនៃការស្វែងរកការងារធ្វើបន្ទាប់ពីបញ្ចប់ការសិក្សា....................................................37
ក្រាភិច 13 ការចំណាយពេលបង្កើតសហគ្រាសអាជីវកម្មស្របជំនាញផ្ទាល់ខ្លួន ....................................................42
ក្រាភិច 14 កម្រិតប្រែប្រួលនៃការប្រើប្រាស់ចំណេះដឹងក្នុងការងារធៀបនឹងសញ្ញាបត្រជំនាញ ........................49
ក្រាភិច 15 ការបណ្តុះបណ្តាលនៅតាមបណ្តាស្ថាប័ននានា.................................................... 51

# ឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធ 1. គោលការណ៍ណែនាំស្តីពីការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា**............................59
**ឧបសម្ព័ន្ធ 2. លិខិតឧទ្ទេសនាម**...........................................................................................64
**ឧបសម្ព័ន្ធ 3. កម្រងសំណួរស្រាវជ្រាវ**.....................................................................................68

# សេចក្តីសង្ខេប

# លទ្ធផលនៃការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច មានមហាវិទ្យាល័យចំនួន៤៖

- មហាវិទ្យាល័យនីតិសាស្ត្រមានជំនាញមួយគឺ នីតិសាស្ត្រ
- មហាវិទ្យាល័យរដ្ឋបាលសាធារណៈមានជំនាញពីរ គឺរដ្ឋបាលសាធារណៈ និងទំនាក់ទំនងអន្តរជាតិ
- មហាវិទ្យាល័យ សេដ្ឋកិច្ចព័ត៌មានវិទ្យាមានពីរជំនាញ គឺសេដ្ឋកិច្ចព័ត៌មាន និងវិទ្យាសាស្ត្រកុំព្យូទ័រ
- មហាវិទ្យាល័យវិទ្យាសាស្ត្រសេដ្ឋកិច្ចនិងគ្រប់គ្រងមានប្រាំជំនាញគឺ គ្រប់គ្រងធុរកិច្ច គណនេយ្យ សេដ្ឋកិច្ចអភិវឌ្ឍន៍ ធនាការនិងហិរញ្ញវត្ថុ និង គ្រប់គ្រងសណ្ឋាគារនិងបដិសណ្ឋារកិច្ច។

ការសិក្សាពីភាពមានការងារធ្វើរបស់និស្សិតបញ្ចប់ការសិក្សាត្រូវបានធ្វើឡើងចាប់ពីឆ្នាំ២០១៥ មក គឺនៅរៀងរាល់មុនពេលបើកពិធីប្រគល់សញ្ញាបត្រដល់បេក្ខជនជ័យលាភី ក្នុងគោលបំណងស្វែងយល់ស្ថានភាពមានការងារធ្វើរបស់និស្សិត និងសេវាផ្សេងៗទៀតដែលសាកលវិទ្យាល័យបានផ្តល់ទៅពួកគាត់។

ការពិនិត្យមើលស្ថានភាពមានការងារធ្វើរបស់និស្សិតដែលបានបញ្ចប់ការសិក្សានៅក្នុងឆ្នាំសិក្សា ២០២២ - ២០២៣នេះ ធ្វើនៅតែមហាវិទ្យាល័យវិទ្យាសាស្ត្រសេដ្ឋកិច្ច និងគ្រប់គ្រង និងមានគោលបំណងស្វែងយល់ស្ថានភាពមានការងារធ្វើរបស់និស្សិតនៅក្រោយបញ្ចប់ការបិទខ្ទប់ជំងឺឆ្លងកូវីដ-១៩។ លទ្ធផលនៃការសិក្សានេះគឺប្រើសម្រាប់មហាវិទ្យាល័យវិទ្យាសាស្ត្រសេដ្ឋកិច្ច និងគ្រប់គ្រងដែលបាន និងកំពុងបណ្តុះបណ្តាលបរិញ្ញាបត្រឯកទេសចំនួន៥ ក្នុងនោះរួមមាន បរិញ្ញាបត្រគ្រប់គ្រងធុរកិច្ច បរិញ្ញាបត្រគណនេយ្យ បរិញ្ញាបត្រសេដ្ឋកិច្ចអភិវឌ្ឍន៍ បរិញ្ញាបត្រធនាគារនិងហិរញ្ញវត្ថុ និងបរិញ្ញាបត្រគ្រប់គ្រងទេសចរណ៍និងបដិសណ្ឋារកិច្ច ដែលបានបញ្ចប់ការសិក្សាក្នុងឆ្នាំសិក្សា២០២២ - ២០២៣កន្លងទៅ។

ទំហំសំណាកសម្រាប់ធ្វើការសិក្សាចំនួន ៥៨៦នាក់(ស្រី ៤៣៧នាក់) ស្មើនឹង ៩២,២៨% ក្នុងចំណោមនិស្សិតបញ្ចប់ការសិក្សាសរុប ៦៣៥នាក់ នៅឆ្នាំសិក្សា ២០២២ -២០២៣។ លទ្ធផលជារួមនិស្សិតមានការងារធ្វើមានចំនួន ៥៥៥នាក់(ស្រី ៤១១នាក់) ស្មើនឹង ៩៤,៧% និង ចំនួន ៣១នាក់(ស្រី ២៦នាក់) ស្មើនឹង ៥,៣% មិនទាន់មានការងារធ្វើ ។ កិច្ចសន្យាការងារពេញម៉ោងមានចំនួន ៤៩៨នាក់(ស្រី ៣៧៣នាក់) ៩១,៧% និង កិច្ចសន្យាការងារមិនពេញម៉ោងមានចំនួន ៤៥នាក់(ស្រី៣១នាក់) ស្មើនឹង ៨,៣%។

គួរឱ្យមានការកត់សម្គាល់ថា ករណីការងារធ្វើស្របជំនាញចំនួន ៥៤៦កន្លែង មាននិស្សិតចំនួន ៣០៧នាក់ ស្មើនឹង៥៦,២%ធ្វើការស្របតាមជំនាញដែលបានសិក្សា ករណីមាននិស្សិត ២៣៩នាក់ ស្មើនឹង ៤៣,៨% មានការងារធ្វើខុសជំនាញដែលបានសិក្សា។ មាននិស្សិតបម្រើការនៅក្នុងវិស័យឯកជនចំនួន ៨២,៩% ក្នុងវិស័យសាធារណៈមានចំនួន ៥,៦% និង ១១,៥% ក្នុងវិស័យផ្សេងទៀត។ ចំពោះការចំណាយពេលរកការងារធ្វើ និស្សិតដែលមានការងារធ្វើស្រាប់មានចំនួន ៦២,៩% ប្រើរយៈពេលតិចជាង១ខែមានចំនួន ៩,៥% រយៈពេលចន្លោះ១ ខែ ដល់៣ខែមានចំនួន ១៤,៣% និងចាប់ពី ៣ខែឡើងទៅមានចំនួន ១៣,៣%។

ពាក់ព័ន្ធនឹងទីកន្លែងការងារ និស្សិតភាគច្រើនបម្រើការនៅរាជធានីភ្នំពេញមានចំនួន ៨៤,៣% បន្ទាប់

ខេត្តកណ្តាលមានចំនួន ៧,៧% ខេត្តតាកែវមានចំនួន ២,២% និងនៅតាមបណ្តាខេត្តផ្សេងៗចំនួន ៥,៨%។ គួរកត់សម្គាល់ថា និស្សិតមានការងារធ្វើដែលទទួលបានប្រាក់ឈ្នួលច្រើនជាង ១០០០$ ឬយ៉ាងតិច៥ដងនៃអ្នកគ្មានជំនាញមានចំនួន ១,៥% ហើយនិស្សិតទទួលបានប្រាក់ឈ្នួលនៅចន្លោះ ២០០$-៤០០$ មានចំនួន ៦៨,៥% ចន្លោះ ៤០០$-៦០០$ មានចំនួន ១៧,០% និងចន្លោះពី ៦០០$-១០០០$ មានចំនួន ៥,៣%។ និស្សិតអាចប្រើចំណេះដឹងត្រូវនឹងកម្រិតសញ្ញាបត្រឬខ្ពស់ជាងក្នុងការបំពេញការងារមានចំនួន ៥៦,៧% និងចំនួន ៤៣,៣% ប្រើចំណេះដឹងទាបជាងកម្រិតសញ្ញាបត្រដែលទទួលបានពីកម្មវិធីសិក្សា។ ជាចុងក្រោយនៃការសិក្សាបានរកឃើញថា កម្មវិធីសិក្សាជំនាញផ្នែកវិទ្យាសាស្ត្រសេដ្ឋកិច្ចនិងគ្រប់គ្រង ដែលបាននិងកំពុងអនុវត្តក្នុងពេលបច្ចុប្បន្នឆ្លើយតបបានច្រើនចំណុចទៅនឹងក្របខ័ណ្ឌគុណវុឌ្ឍិជាតិរួមមាន ចំណេះដឹង ជំនាញក្នុងការគិត ជំនាញទំនាក់ទំនងអន្តរបុគ្គលនិងការទទួលខុសត្រូវ និងជំនាញលេខនព្វន្ត ព័ត៌មានវិទ្យានិងទំនាក់ទំនង។

# ផ្នែកទី១. សេចក្តីផ្តើម

## ១.១. សារតារនៃការសិក្សា

ការសិក្សាតាមដានលទ្ធផលបញ្ចប់ការសិក្សារបស់និស្សិត គឺជាការសិក្សាស្រាវជ្រាវមួយដែលពាក់ព័ន្ធនឹងការតាមដាននិស្សិតដែលបានចុះឈ្មោះក្នុងវគ្គសិក្សាណាមួយរបស់គ្រឹះស្ថានសិក្សាមួយ ដោយគិតចាប់ពីពេលដែលនិស្សិតបានចុះឈ្មោះចូលរៀនក្នុងវគ្គសិក្សានោះ គឺពិនិត្យមើលការខិតខំរៀនក្នុងអំឡុងពេលសិក្សា និងអ្វីដែលពួកគេបានធ្វើជារៀងរាល់ឆ្នាំបន្ទាប់ពីពួកគេបានបញ្ចប់វគ្គសិក្សា សម្រាប់រយៈពេលមួយដែលពួកគេបានចូលរួម ឬបន្តការងារ ឬធ្វើការងារផ្ទាល់ខ្លួន។

ការសិក្សាតាមដានលទ្ធផលបញ្ចប់ការសិក្សារបស់និស្សិត គឺជាវិធីសាស្ត្រមួយដែលត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយនៅក្នុងស្ថាប័នភាគច្រើន ជាពិសេសនៅក្នុងស្ថាប័នអប់រំ ដើម្បីតាមដាន និងរក្សាកំណត់ត្រានិស្សិតរបស់ពួកគេនៅពេលដែលពួកគេបានបញ្ចប់ការសិក្សាពីស្ថាប័ននោះ។ វាជាការតាមដាននិស្សិតបញ្ចប់ការសិក្សាថ្នាក់ឧត្តមសិក្សា ឬវិទ្យាស្ថាន។ គោលបំណងគឺដើម្បីវាយតម្លៃពីភាពរីកចម្រើនរបស់និស្សិតរហូតដល់ពេលដែលពួកគាត់ទទួលបានការងារធ្វើ។ ការសិក្សានេះបង្កើតឡើង ដើម្បីឆ្លើយតបទៅនឹងការផ្លាស់ប្តូរនៃការវិវត្តឧស្សាហកម្ម ដោយការរួមបញ្ចូលគ្នារវាងស្ថាប័នឧត្តមសិក្សានិងទីផ្សារការងារ។ អត្ថប្រយោជន៍នៃការសិក្សា គឺប្រើសម្រាប់ការគ្រប់គ្រង និងជាឧបករណ៍សម្រាប់ធ្វើផែនការ ការត្រួតពិនិត្យកម្មវិធីបណ្តុះបណ្តាល និងជាឧបករណ៍ដ៏សាមញ្ញដែលត្រូវបានបង្កើតឡើង ដើម្បីវាស់ស្ទង់នៃភាពជាប់ពាក់ព័ន្ធក្នុងការបណ្តុះបណ្តាលវិជ្ជាជីវៈផងដែរ។ ការសិក្សានេះបានផ្តល់ព័ត៌មានសម្រាប់ការផ្លាស់ប្តូរភាពខ្វះចន្លោះ និងការពិនិត្យឡើងវិញរបស់កម្មវិធីសិក្សាបណ្តុះបណ្តាល។

ការសិក្សាតាមដានលទ្ធផលអង្កេតបញ្ចប់ការសិក្សារបស់និស្សិត អាចផ្តល់ឱ្យនូវព័ត៌មានសំខាន់ៗចំនួនបី៖ ទី១. ការផ្គូផ្គងជំនាញច្បាស់លាស់ ទី២. ការរួមបញ្ចូលគ្នានៃទិន្នន័យគោលដៅ និងទី៣ .ប្រធានបទស្តីពីស្ថានភាពនិស្សិតបញ្ចប់ការសិក្សា។ ក្រៅពីភាពអាចវាស់វែងបានពីភាពមានការងារធ្វើរបស់និស្សិតបញ្ចប់ការសិក្សា និងទទួលបានមតិកែលម្អធ្វើឱ្យប្រសើរឡើងនូវកម្មវិធីសិក្សា លើសពីនេះលទ្ធផលនៃការសិក្សាបានបង្ហាញឱ្យឃើញទិដ្ឋភាពនៃការផ្គូផ្គងរវាងភាពពាក់ព័ន្ធរបស់ការងារចុះកម្មសិក្សា ឬការអនុវត្តផ្ទាល់នៅកន្លែងការងារ និងកម្រិតគុណវុឌ្ឍិមួយដែលត្រូវអាចវាស់វែងបាន។ ការសិក្សានេះអាចជួយឆ្លើយនូវសំណួរដូចជា៖

ក. តើមានអ្វីកើតឡើងចំពោះនិស្សិតបញ្ចប់ការសិក្សាបន្ទាប់ពីបានចាកចេញពីគ្រឹះស្ថានឧត្តមសិក្សា?

ខ. តើចំណាយពេលប៉ុន្មានដែលអាចទទួលបានការងារធ្វើ និងទទួលបានប្រាក់ខែប៉ុន្មាន?

គ. តើអាចប្រើប្រាស់ជំនាញ និងសមត្ថភាពដែលទទួលបានពីការអប់រំការបណ្តុះបណ្តាលបានកម្រិតណា? ប្រសិនបើមិនបានប្រើប្រាស់ទេ តើបណ្តាលមកពីកត្តាអ្វីខ្លះ?

ឃ. តើជំនាញ និងសមត្ថភាពអ្វីខ្លះដែលត្រូវបានទាមទារដោយទីផ្សារការងារ?

លើសពីនេះ ការសិក្សាតាមដាននិស្សិតបញ្ចប់ការសិក្សាក្នុងរយៈពេលខ្លីខាងមុខ គឺជាការសិក្សាតាមដានសម្លឹងឆ្ពោះទៅអនាគត ដែលពាក់ព័ន្ធនឹងការរៀបចំផែនការ ដើម្បីតាមដានអ្នកសិក្សាចាប់ពីពេលដែលនិស្សិតបានចុះឈ្មោះក្នុងវគ្គសិក្សា ឬកម្មវិធីសិក្សា ឬចាប់ពីពេលដែលពួកគេបានបញ្ចប់វគ្គសិក្សា ឬកម្មវិធីសិក្សាមួយ។ បន្ទាប់

មកធ្វើការសិក្សាតាមដានអ្នកសិក្សាទាំងនោះក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខ។

ដូច្នេះយើងគួរស្នើឱ្យមានការកំណត់មុខវិជ្ជាដែលអាចបត់បែនបានជាថ្មី និងបង្កើតឱ្យមានការគាំទ្រយ៉ាងទូលំទូលាយ ហើយធ្វើការតាមដានអ្នកសិក្សាពីពេលដែលពួកគេបានចាប់ផ្តើមសិក្សាកម្មវិធីថ្មី រហូតដល់ពេលដែលពួកគេបានបញ្ចប់វគ្គសិក្សា ក្នុងគោលបំណងដើម្បីស្វែងយល់អំពីភាពរីកចំរើននៃជីវភាពរស់នៅរបស់ពួកគេនាពេលអនាគត។

## ១.២. វត្ថុបំណងនៃការសិក្សា

មហាវិទ្យាល័យវិទ្យាសាស្ត្រសេដ្ឋកិច្ចនិងគ្រប់គ្រង បានបណ្តុះបណ្តាលនិស្សិតនៅលើជំនាញរបស់ខ្លួនបានជាច្រើនពាន់នាក់អស់ជាច្រើនឆ្នាំកន្លងមកហើយ និងបានធ្វើការសិក្សាស្រាវជ្រាវពីភាពមានការងារធ្វើរបស់និស្សិតបានចំនួន៨ដងរួចមកហើយគិតមកដល់ឆ្នាំ២០១៩ (មុនព្រឹត្តិការណ៍ជំងឺឆ្លងកូវីដ-១៩)។ នៅក្នុងដំណាក់កាលក្រោយពីជំងឺឆ្លងកូវីដ-១៩បានចុះថមថយ។ នេះជាឱកាសថ្មីមួយទៀតដែលទទួលបានបទពិសោធន៍ថ្មីៗពីគ្រឹះស្ថានឧត្តមសិក្សាស្តីពីភាពមានការងារធ្វើរបស់និស្សិតបញ្ចប់ការសិក្សាបន្ទាប់ពីបានទៅចូលរួមសិក្ខាសាលាចំនួន២ដងរួចមក។

ការស្រាវជ្រាវនេះមានកម្មវត្ថុមួយចំនួនដូចខាងក្រោម៖

- ស្វែងរកចំនួនភាគរយភាពមានការងារធ្វើទាំងស្របជំនាញ និងមិនស្របជំនាញ
- រយៈពេលនៃការស្វែងរកការងារ
- កម្រិតប្រាក់ឈ្នួល ជាពិសេសប្រាក់ឈ្នួល ៥ដង លើសអ្នកគ្មានជំនាញ
- កម្មវិធីសិក្សាឆ្លើយតបនឹងតម្រូវការនៃទីផ្សារការងារ
- សមត្ថភាពបង្កើតសហគ្រាសផ្ទាល់ខ្លួន
- កម្មវិធីបណ្តុះបណ្តាលឆ្លើយតបទៅនឹងគុណវុឌ្ឍិជាតិ និង
- ចំណុចមួយចំនួនដែលជាព័ត៌មានត្រឡប់ទទួលបានពីនិស្សិត។

## ១.៣. ការប្រើប្រាស់លទ្ធផលនៃការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សាកន្លងមក

របាយការណ៍នេះ បានរៀបចំជាតារាងប្រៀបធៀបលទ្ធផលសិក្សាពីភាពមានការងារធ្វើរបស់និស្សិតបញ្ចប់ការសិក្សានៅឆ្នាំសិក្សា ២០២០-២០២១ និងភាពមានការងារធ្វើរបស់និស្សិតបញ្ចប់ការសិក្សានៅឆ្នាំសិក្សា ២០២១-២០២២ និងឆ្នាំសិក្សា ២០២២-២០២៣ ដែលជាការបញ្ចប់ការសិក្សាមួយដ៏លំបាករបស់និស្សិតនៅក្នុងដំណាក់កាលនៃជំងឺកូវីដ-១៩ កំពុងរីករាលដាលខ្លាំងនៅឡើយ។ យោងគោលការណ៍ណែនាំលេខ ៦៥៥ ស.ភ.ន.វ.ស. ចុះថ្ងៃទី ២៤ ខែឧសភា ឆ្នាំ២០២២ ស្តីពី ការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សានៅ ស.ភ.ន.វ.ស (ឧបសម្ព័ន្ធ១) ។ លទ្ធផលនៃការសិក្សាស្រាវជ្រាវ និងព័ត៌មានត្រឡប់ពីនិស្សិតបញ្ចប់ការសិក្សានៅឆ្នាំសិក្សា ២០២២-២០២៣ និងកាលពីឆ្នាំសិក្សាកន្លងទៅយកមកពិនិត្យ និងស្រង់យកចំណុចគន្លឹះសំខាន់ៗចាំបាច់ ដែលត្រូវបានទាមទារពីការវិវត្តនៃទីផ្សារពលកម្មសម័យឌីជីថលទុកជាមូលដ្ឋានសម្រាប់កែលម្អកម្មវិធីសិក្សានាពេលបច្ចុប្បន្ននិងទៅអនាគត ដើម្បីផ្តល់ដល់និស្សិតនូវអត្ថប្រយោជន៍យ៉ាងពេញលេញបន្ទាប់ពីពួកគេបានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យ។

# ផ្នែកទី២. វិធីសាស្ត្រនៃការសិក្សា

## ២.១. វិធីសាស្ត្រប្រមូលទិន្នន័យ

ការសិក្សាថ្នាក់បរិញ្ញាបត្រមានរយៈពេលចំនួនបួន(០៤)ឆ្នាំ ដោយរាប់ចាប់ពីឆ្នាំសិក្សាថ្នាក់មូលដ្ឋានរហូតដល់ឆ្នាំទី៤ដែលជាឆ្នាំប្រឡងបញ្ចប់ការសិក្សា។ នៅឆ្នាំសិក្សាថ្នាក់មូលដ្ឋាននិស្សិតសិក្សាពេញមួយឆ្នាំមានចំនួនដប់មុខវិជ្ជា និងមានចំនួន ៣០ ក្រេឌីត។

ការប្រមូលទិន្នន័យសម្រាប់បង្កើតរបាយការណ៍ស្តីពីស្ថានភាពនិស្សិតបញ្ចប់ការសិក្សានៅ ស.ភ.ន.វ.ស. ត្រូវធ្វើឡើងដោយលិខិតឧទ្ទេសនាម លេខ ១៦៦៥ ស.ភ.ន.វ.ស. ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២៤ សម្រាប់កិច្ចដំណើរការប្រមូលទិន្នន័យ និងព័ត៌មានទាក់ទងនឹងការបញ្ចប់ការសិក្សារបស់និស្សិតនៃមហាវិទ្យាល័យវិទ្យាសាស្ត្រសេដ្ឋកិច្ចនិងគ្រប់គ្រងក្នុងឆ្នាំសិក្សា ២០២២-២០២៣។ ក្នុងលិខិតឧទ្ទេសនាមនេះ បានរៀបចំភារកិច្ចជា៣ផ្នែកធំៗរួមមាន៖ ទី១. គណៈកម្មការទទួលបន្ទុករួម ទី២ .អនុគណៈកម្មការគាំទ្រ និងទី៣ .អនុគណៈកម្មការបច្ចេកទេស។ គណៈកម្មការ និងអនុគណៈកម្មការតាមផ្នែកនីមួយៗបានបំពេញភារកិច្ចទៅតាមការកំណត់និងមានចែងនៅក្នុងលិខិតឧទ្ទេសនាម (ឧបសម្ព័ន្ធ២)។ អនុគណៈកម្មការគាំទ្រ បានប្រើប្រាស់កម្រងសំណួរតាមរយៈ Microsoft form បញ្ជូនទៅនិស្សិតនៅក្រុម Telegram តាមជំនាញនីមួយៗ ដោយទុករយៈពេល១៧ថ្ងៃឱ្យនិស្សិតបំពេញ។ គ្រូទទួលបន្ទុកថ្នាក់ដើរតួនាទីសំខាន់ក្នុងការរំឭកនិស្សិតក្នុងក្រុមជាច្រើនដង។

## ២.២. ក្រុមគោលដៅផ្តល់សម្ភាសន៍ (អ្នកចូលរួមឆ្លើយសំណួរនៃការសិក្សា)

ក្រុមគោលដៅនៃការសម្ភាសន៍ គឺជានិស្សិតដែលបានបញ្ចប់ការសិក្សានៅឆ្នាំសិក្សា២០២២-២០២៣ រួមមាននិស្សិត បរិញ្ញាបត្រគ្រប់គ្រងធុរកិច្ច បរិញ្ញាបត្រសេដ្ឋកិច្ចអភិវឌ្ឍន៍ បរិញ្ញាបត្រគណនេយ្យ បរិញ្ញាបត្រធនាគារនិងហិរញ្ញវត្ថុ និងគ្រប់គ្រងទេសចរណ៍និងបដិសណ្ឋារកិច្ចដែលជំនាញទាំងអស់នេះ ស្ថិតនៅក្រោមការបណ្តុះបណ្តាលរបស់មហាវិទ្យាល័យវិទ្យាសាស្ត្រសេដ្ឋកិច្ចនិងគ្រប់គ្រង។ ទំហំសំណាកដែលប្រមូលបានមានចំនួន ៥៨៦នាក់ ស្មើនឹង ៩២,២៨% ក្នុងចំណោមនិស្សិតបញ្ចប់ការសិក្សាសរុបចំនួន ៦៣៥នាក់។ ដូចនេះ ភាគរយនៃការឆ្លើយតបនេះមានកម្រិតជឿជាក់ខ្ពស់។

## ២.៣. ឧបករណ៍សម្រាប់ការសិក្សា និងការវិភាគទិន្នន័យ

ទិន្នន័យនិងព័ត៌មានដែលទាក់ទងនឹងនិស្សិតបញ្ចប់ការសិក្សាក្នុងឆ្នាំសិក្សា២០២២-២០២៣ ត្រូវបានធ្វើឡើងតាមរយៈកម្រងសំណួរចំនួន ៤៥សំណួរ។ កម្រងសំណួរចែកចេញជា៦ផ្នែក៖ ផ្នែកទី១. ព័ត៌មានផ្ទាល់ខ្លួនរបស់និស្សិត ផ្នែកទី២. ព័ត៌មានស្តីពីការសិក្សា ផ្នែកទី៣. ព័ត៌មានស្តីពីការបណ្តុះបណ្តាល ផ្នែកទី៤. ព័ត៌មានស្តីពីស្ថានភាពមានការងារធ្វើ ផ្នែកទី៥. ព័ត៌មានស្តីពីតម្រូវការមុខជំនាញ និងផ្នែកទី៦. សិក្សាលើព័ត៌មានត្រឡប់។ នៅក្នុងផ្នែកទី៦នេះ មានសំណួរបើកចំនួន៣សំណួរ សម្រាប់ស្វែងរកជំនាញផ្សេងៗទៀតដែលជាការវិវត្តនៃតម្រូវការទីផ្សារការងារក្នុងពេលបច្ចុប្បន្ន (ឧបសម្ព័ន្ធ៣)។

ទិន្នន័យដែលទទួលបានពី Microsoft Form ត្រូវបានទាញជា Excel file រួចសម្អាតទិន្នន័យនិងកំណត់កូដឱ្យបានច្បាស់លាស់។ ជាចុងក្រោយ បញ្ចូល Excel file ទៅក្នុងកម្មវិធី SPSS ដើម្បីយកមកធ្វើការវិភាគដោយ

ប្រើលទ្ធផលជា Frequency, Descriptive, Cross table និង Independent Sample T- test ជាដើម ។

## ២.៤. វិសាលភាព និងដែនកំណត់នៃការសិក្សា

ការសិក្សាស្តីពីស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សានៅឆ្នាំសិក្សា ២០២២-២០២៣ គ្របដណ្តប់ទៅលើនិស្សិតជំនាញគ្រប់គ្រងធុរកិច្ច ជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍ ជំនាញគណនេយ្យ ជំនាញធនាគារនិងហិរញ្ញវត្ថុ និងជំនាញគ្រប់គ្រងទេសចរណ៍ និងបដិសណ្ឋារកិច្ច នៃមហាវិទ្យាល័យវិទ្យាសាស្ត្រសេដ្ឋកិច្ច និងគ្រប់គ្រង។

ដែនកំណត់នៃការសិក្សានេះ គឺចាប់ផ្តើមប្រមូលទិន្នន័យចាប់ពីថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២៤ រហូតដល់ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៤ មានចំនួន ៧ថ្ងៃ។

## ២.៥. ក្រមសីលធម៌នៃការសិក្សា

ពាក្យពេចន៍ និងខ្លឹមសារដែលបានប្រើប្រាស់នៅក្នុងកម្រងសំណួរពុំមានចំណុច ឬផ្នែកណាមួយបានធ្វើឱ្យប៉ះពាល់ដល់សិទ្ធិបុគ្គលណាម្នាក់ទេ។ ការស្ទង់មតិនេះ រក្សាការសម្ងាត់នូវរាល់ព័ត៌មានរបស់និស្សិត ដែលបានឆ្លើយតប។ លទ្ធផលនៃការសិក្សាស្រាវជ្រាវ ត្រូវបានយកទៅប្រើប្រាស់តែក្នុងគោលបំណងអភិវឌ្ឍការបណ្តុះបណ្តាលរបស់កម្មវិធីអប់រំតែប៉ុណ្ណោះ។

# ផ្នែកទី៣. លទ្ធផលនៃការសិក្សា

ផ្នែកទី៣នេះនឹងពិនិត្យលទ្ធផលនៃការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សានៃមហាវិទ្យាល័យវិទ្យាសាស្ត្រសេដ្ឋកិច្ច និងគ្រប់គ្រង ដែលបានបញ្ចប់ការសិក្សាក្នុងឆ្នាំសិក្សា ២០២០-២០២១ ក្នុងដំណាក់នៃការរីករាលដាលនៃជំងឺកូវីដ-១៩ ធ្វើការប្រៀបធៀបជាមួយឆ្នាំសិក្សា២០២១-២០២២ ក្រោយកូវីដ-១៩ ចុះថមថយ និងក្នុងឆ្នាំសិក្សា២០២២-២០២៣ បន្ទាប់ពីការបើកដំណើរការសេដ្ឋកិច្ចឡើងវិញ។

**តារាង 1 . ភាពមានការងារធ្វើរបស់និស្សិតឆ្នាំសិក្សា២០២០-២១, ២០២១-២២និងឆ្នាំសិក្សា២០២២-២០២៣**

| ជំនាញ | ឆ្នាំសិក្សា ២០២២-២០២៣ | | ឆ្នាំសិក្សា ២០២១-២០២២ | | ឆ្នាំសិក្សា ២០២០-២០២១ | |
|---|---|---|---|---|---|---|
| | មុនបញ្ចប់ការសិក្សា | ក្រោយបញ្ចប់ការសិក្សា | មុនបញ្ចប់ការសិក្សា | ក្រោយបញ្ចប់ការសិក្សា | មុនបញ្ចប់ការសិក្សា | ក្រោយបញ្ចប់ការសិក្សា |
| គ្រប់គ្រងធុរកិច្ច | 70,8% | 95,2% | 64.6% | 89.9% | 37.7% | 99.0% |
| សេដ្ឋកិច្ចអភិវឌ្ឍន៍ | 55,5% | 89,5% | 62.6% | 96.3% | 35.3% | 95.3% |
| គណនេយ្យ | 63,9% | 96,9% | 75.4% | 99.3% | 48.3% | 98.9% |
| ធនាគារនិងហិរញ្ញវត្ថុ | 62,5% | 95,5% | 66.4% | 97.6% | 39.6% | 97.2% |
| គ្រប់គ្រងទេសចរណ៍និងបដិសណ្ឋារកិច្ច | 45,8% | 96,4% | 55.6% | 100.0% | 56.5% | 95.7% |
| **សរុប** | **59,6%** | **94,7%** | **67.5%** | **96.3%** | **41.0%** | **97.7%** |

តារាងខាងលើនេះ បានបង្ហាញថាអត្រាភាពមានការងារធ្វើពេលកំពុងសិក្សារបស់និស្សិតទាំង៥ជំនាញ នៅក្នុងដំណាក់កាលមានជំងឺកូវីដ-១៩ចុះថមថយ ភាពមានការងារធ្វើចុះមកត្រឹម៤១,០% ករណីពេលបើកទីផ្សារឡើងវិញភាពមានការងារធ្វើកើនដល់ ៥៩,៦%។ ផ្ទុយទៅវិញក្រោយបញ្ចប់ការសិក្សា អត្រាភាពមានការងារធ្វើរបស់និស្សិតនៅក្នុងកំឡុងពេលបើកទីផ្សារឡើងវិញមានចំនួន ៩៤,៧% ករណីក្នុងអំឡុងពេលជំងឺកូវីដ-១៩ចុះថមថយ អត្រាភាពមានការងារធ្វើមានចំនួន ៩៦,៣% ពោលគឺមានកំណើនថយចុះចំនួន ១,៦%។

គួរកត់សម្គាល់ថា អត្រាការងារធ្វើទាបជាងគេ ក្រោយបញ្ចប់ការសិក្សា ក្នុងដំណាក់កាលបើកទីផ្សារឡើងវិញក្នុងចំណោមបរិញ្ញាបត្រទាំង៥គឺមានតែបរិញ្ញាបត្រសេដ្ឋកិច្ចអភិវឌ្ឍន៍ដែលមានអត្រាការងារទាបចំនួន ៨៩,៥%។

**តារាង 2 ភាពមានការងារធ្វើរបស់និស្សិតក្នុងអំឡុងពេល៨ឆ្នាំចុងក្រោយ (ឆ្នាំសិក្សាបញ្ចប់)**

| ជំនាញផ្នែកសេដ្ឋកិច្ច | 2014-15 | 2015-16 | 2016-17 | 2017-18 | 2018-19 | 2020-21 | 2021-22 | 2022-23 |
|---|---|---|---|---|---|---|---|---|
| គ្រប់គ្រងធុរកិច្ច | 92.5% | 96.9% | 96.8% | 97.2% | 97.3% | 99.0% | 89.9% | 94.9% |
| សេដ្ឋកិច្ចអភិវឌ្ឍន៍ | 86.30% | 91.9% | 94.8% | 95.2% | 97.4% | 95.3% | 96.3% | 88.3% |
| គណនេយ្យ | 92.8% | 98.4% | 94.7% | 94.4% | 97.8% | 98.9% | 99.3% | 96.7% |
| ធនាគារនិងហិរញ្ញវត្ថុ | 95.4% | 96.8% | 95.4% | 95.0% | 98.3% | 97.2% | 97.6% | 90.5% |
| គ្រប់គ្រងទេសចរណ៍និងបដិសណ្ឋារកិច្ច | 100% | 100% | 95.3% | 100% | 91.7% | 95.7% | 100.0% | 83.3% |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| អត្រាមធ្យមភាគភាពមានការងារធ្វើក្នុងឆ្នាំសិក្សានីមួយៗ | 93.4% | 96.8% | 95.4% | 96.4% | 96.5% | 97.2% | 96.3% | 90.7% |
| អត្រាមធ្យមភាគរួមនៃភាពមានការងារធ្វើក្នុងរយៈពេល៨ឆ្នាំចុងក្រោយ៖ 96.0% | | | | | | | | |

ប្រភព៖ របាយការណ៍ស្តីពីលទ្ធផលអង្កេតពីភាពមានការងារធ្វើរបស់និស្សិត ស.ភ.ន.វ.ស, ឆ្នាំ២០១៦ និងបន្តបន្ទាប់

លទ្ធផលនេះបង្ហាញថាកម្មវិធីបណ្តុះបណ្តាលជំនាញទាំង៥របស់មហាវិទ្យាល័យវិទ្យាសាស្ត្រសេដ្ឋកិច្ច និងគ្រប់គ្រង បានឆ្លើយតបទៅនឹងតម្រូវការទីផ្សារពលកម្ម និងការរីកចំរើនថ្មីនៃទីផ្សារការងារផងដែរ ដោយប្រៀបធៀបទៅនឹងការសិក្សាភាពមានការងារធ្វើក្រោយបញ្ចប់ការសិក្សារបស់និស្សិតដែលបានធ្វើឡើងដោយសាកលវិទ្យាល័យនៅចន្លោះឆ្នាំសិក្សា២០១៤-២០១៥ ដល់ឆ្នាំសិក្សា២០១៨-១៩ ។

**ក្រាភិច 1 បម្រែបម្រួលភាពមានការងារធ្វើរបស់និស្សិតនៅ៨ឆ្នាំចុងក្រោយ**




ក្រាភិកខាងលើនេះបានបង្ហាញថា និស្សិតដែលបានបញ្ចប់ការសិក្សានៅឆ្នាំសិក្សា២០១៨-២០១៩ អត្រាភាគរយនៃអ្នកមានការងារធ្វើបានធ្លាក់ចុះស្ទើរគ្រប់ជំនាញ អត្រាភាគរយនៃអ្នកមានការងារធ្វើខាងជំនាញគ្រប់គ្រងទេសចរណ៍និងបដិសណ្ឋារកិច្ច បានធ្លាក់ចុះពី១០០% នៅឆ្នាំ២០១៨-២០១៩ ពីផលប៉ះពាល់នៃការរីករាលនៃកូវីដ-១៩ មកនៅត្រឹម ៩១,៥% ប៉ុន្តែមកដល់ឆ្នាំសិក្សា ២០២១-២០២២នេះ ជំនាញគ្រប់គ្រងទេសចរណ៍និងបដិសណ្ឋារកិច្ចបានងើបឡើងវិញដល់ ១០០% ផ្ទុយមកវិញវាបានថយចុះមក ៨៣,3% ក្នុងពេលដែលវិស័យទេសចរណ៍

បើកដំណើរការឡើងវិញ។

## ៣.១. ព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកចូលរួម

### ៣.១.១. អតីតសិស្សមកពីវិទ្យាល័យតាមរាជធានី និងខេត្ត

ក្នុងចំណោមនិស្សិតដែលបានឆ្លើយតបចំនួនសរុប ៥៨៦នាក់ និស្សិតបុរសមានចំនួន១៤៩នាក់ស្មើនឹង ២៥,៤%និងនារីមានចំនួន៤៣៧នាក់ស្មើនឹង៧៤,៦ %។ និស្សិតទាំងនោះគឺជាអតីតសិស្សមកពីវិទ្យាល័យ តាមបណ្តារាជធានី ខេត្តសរុបចំនួន២៤ ដែលក្នុងនោះភាគច្រើនមករាជធានីភ្នំពេញចំនួន៣០,៥% ខេត្តកណ្តាល ចំនួន ២០,៣% ខេត្តព្រៃវែង ចំនួន ៦,៥% ខេត្តកំពង់ចាម ចំនួន ៧,៥% ខេត្តតាកែវ ចំនួន ១២,១% និងមានមកពីបណ្តាខេត្តផ្សេងៗទៀតចំនួន ២៣,១% ។

**តារាង 3 អតីតសិស្សមកពីវិទ្យាល័យតាមរាជធានី និងខេត្ត**

| ល.រ | រាជធានី/ខេត្ត | ចំនួន | ភាគរយ |
|---|---|---|---|
| 1 | រាជធានីភ្នំពេញ | 179 | 30.5% |
| 2 | កណ្តាល | 119 | 20.3% |
| 3 | កំពង់ចាម | 44 | 7.5% |
| 4 | បាត់ដំបង | 14 | 2.4% |
| 5 | ព្រៃវែង | 38 | 6.5% |
| 6 | សៀមរាប | 6 | 1.0% |
| 7 | តាកែវ | 71 | 12.1% |
| 8 | ត្បូងឃ្មុំ | 16 | 2.7% |
| 9 | បន្ទាយមានជ័យ | 1 | 0.2% |
| 10 | កំពង់ស្ពឺ | 19 | 3.2% |
| 11 | កំពង់ធំ | 10 | 1.7% |
| 12 | កំពង់ឆ្នាំង | 15 | 2.6% |
| 13 | កំពត | 14 | 2.4% |
| 14 | ស្វាយរៀង | 7 | 1.2% |

| | | | |
|---|---|---|---|
| 15 | ពោធិសាត់ | 9 | 1.5% |
| 16 | ក្រចេះ | 6 | 1.0% |
| 17 | ខេត្តព្រះសីហនុ | 3 | 0.5% |
| 18 | ព្រះវិហារ | 2 | 0.3% |
| 19 | រតនៈគិរី | 3 | 0.5% |
| 20 | កោះកុង | 2 | 0.3% |
| 21 | ស្ទឹងត្រែង | 2 | 0.3% |
| 22 | ឧត្តមានជ័យ | 2 | 0.3% |
| 23 | មណ្ឌលគីរី | 2 | 0.3% |
| 24 | កែប | 1 | 0.2% |
| | សរុប | 586 | 100.0% |

### ៣.១.២. ចន្លោះអាយុរបស់និស្សិត

អាយុរបស់និស្សិតដែលបានបញ្ចប់ការសិក្សានៅឆ្នាំ២០២៣ រហូតមកដល់បច្ចុប្បន្ន ត្រូវបានកំណត់ជា៤ចន្លោះ ដែលក្នុងនោះមាន ទី១. អាយុក្រោម២២ឆ្នាំមានចំនួន៦៥នាក់ ស្មើនឹង ១១,១% ទី២ អាយុចន្លោះ២២ឆ្នាំ ទៅ២៦ឆ្នាំមានចំនួន ៥១២នាក់ស្មើនឹង ៨៧,៤% ទី៣ អាយុចន្លោះ២៦ឆ្នាំ ទៅ៣០ឆ្នាំមានចំនួន៩នាក់ស្មើនឹង ១,៥% និងទី៤ ពុំមានអាយុលើសពី៣០ឆ្នាំទេ។

**តារាង 4 ចន្លោះអាយុរបស់និស្សិត**

| អាយុ | ចំនួន | ភាគរយ |
|---|---|---|
| អាយុក្រោម 22 ឆ្នាំ | 65 | 11.1% |
| អាយុចន្លោះ 22-26 ឆ្នាំ | 512 | 87.4% |
| អាយុចន្លោះ 26-30 ឆ្នាំ | 9 | 1.5% |
| **សរុប** | 586 | 100.0% |

### ៣.១.៣. អាសយដ្ឋានបច្ចុប្បន្នរបស់និស្សិត

តារាងខាងក្រោមបានបង្ហាញថា និស្សិតដែលបានបញ្ចប់ការសិក្សា ភាគច្រើនរស់នៅក្នុងរាជធានីភ្នំពេញមានចំនួន៨៤,៣% រស់នៅខេត្តកណ្ដាលមានចំនួន ៧,៧%។ គួរកត់សម្គាល់ថាមាននិស្សិតបញ្ចប់ការសិក្សារស់នៅតាមបណ្ដាខេត្តនានាមានចំនួន៨,០% តិចជាង១០ដង បើប្រៀបធៀបនឹងទីប្រជុំជនពិសេសរាជធានីភ្នំពេញ។

**តារាង 5 ខេត្តដែលជាអាសយដ្ឋានបច្ចុប្បន្នរបស់និស្សិត**

| ល.រ | រាជធានី/ខេត្ត | ចំនួន | ភាគរយ | ភាគរយបង្គរ |
|---|---|---|---|---|
| 1 | ភ្នំពេញ | 456 | 77.8% | 77.8% |
| 2 | កំពង់ស្ពឺ | 8 | 1.4% | 79.2% |
| 3 | កំពង់ធំ | 2 | 0.3% | 79.5% |
| 4 | កំពង់ឆ្នាំង | 1 | 0.2% | 79.7% |
| 5 | កំពត | 1 | 0.2% | 79.9% |
| 6 | ស្វាយរៀង | 2 | 0.3% | 80.2% |
| 7 | ពោធិ៍សាត់ | 1 | 0.2% | 80.4% |
| 8 | ក្រចេះ | 2 | 0.3% | 80.7% |
| 9 | ព្រះសីហនុ | 4 | 0.7% | 81.4% |
| 10 | រតនគីរី | 1 | 0.2% | 81.6% |
| 11 | កណ្ដាល | 77 | 13.1% | 94.7% |
| 12 | ឧត្ដមានជ័យ | 1 | 0.2% | 94.9% |
| 13 | នៅបរទេស | 1 | 0.2% | 95.1% |
| 14 | កំពង់ចាម | 1 | 0.2% | 95.2% |
| 15 | បាត់ដំបង | 2 | 0.3% | 95.6% |
| 16 | ព្រៃវែង | 11 | 1.9% | 97.4% |
| 17 | តាកែវ | 11 | 1.9% | 99.3% |
| 18 | ត្បូងឃ្មុំ | 2 | 0.3% | 99.7% |
| 19 | បន្ទាយមានជ័យ | 2 | 0.3% | 100.0% |
| | **សរុប** | **586** | **100.0%** | |

## ៣.២. ព័ត៌មានពីការសិក្សា

និស្សិតដែលសិក្សាក្នុងមហាវិទ្យាល័យនេះ តម្រូវឱ្យសិក្សាជោគជ័យនៅថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ដែលគ្រប់គ្រងដោយដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន និងសិក្សាចាប់ពីឆ្នាំទី២ ទី៣ និងទី៤ ដែលគ្រប់គ្រងដោយការិយាល័យសិក្សា។

### ៣.២.១. ការចុះកម្មសិក្សា ឬហាត់ការ និងការទទួលបានប្រាក់ចំណូល

ដើម្បីបញ្ចប់ការសិក្សា និស្សិតឆ្នាំទី៤អាចមានជម្រើស២ ដែលក្នុងនោះជម្រើសទី១ និស្សិតអាចប្រឡងបញ្ចប់ដោយសិក្សាមុខវិជ្ជាចំនួន៣មុខនៅឆមាសទី២នៃឆ្នាំទី៤ និងជម្រើសទី២ និស្សិតពូកែចំនួន១៥%នៃថ្នាក់នីមួយៗអាចសរសេរសារណាបញ្ចប់ការសិក្សា ឬចុះកម្មសិក្សានិងសរសេររបាយការណ៍កម្មសិក្សា។ លើសពីនេះ និស្សិត

ដែលមិនទាន់សិក្សាដល់ឆ្នាំទី៤ ក៏អាចចុះហាត់ការនៅតាមស្ថាប័ន ឬក្រុមហ៊ុននានា ដើម្បីទទួលបានបទពិសោធន៍ការងារនៅមុនបញ្ចប់ការសិក្សារបស់ពួកគេដែរ។

- ចំនួននិស្សិតចុះកម្មសិក្សាក្នុងអំឡុងពេលសិក្សា ចំនួនសរុប /ស្រី
  - និស្សិតចុះកម្មសិក្សាក្នុងអំឡុងពេលសិក្សា សរុបចំនួន១៩៩នាក់ ស្មើ ៣៤,០% ធៀបនឹងនិស្សិតចូលរួមឆ្លើយសរុប ៥៨៦នាក់(ស្រីចំនួន ១៤៧នាក់ ស្មើនឹង ២៥,០៨%)
  - និស្សិតចុះកម្មសិក្សាសរុបក្នុងអំឡុងពេលសិក្សា មានចំនួន១៩៩នាក់ ស្មើនឹង ៣១,៣៣% ធៀបនឹងនិស្សិតបញ្ចប់ការសិក្សាសរុប ៦៣៥នាក់ (ស្រីចំនួន ១៤៧នាក់ ស្មើនឹង ២៣,១៥%) ។

តារាងខាងក្រោមនេះបង្ហាញចំនួននិស្សិតដែលបានចុះកម្មសិក្សា ហាត់ការ/និងទទួលបានប្រាក់ចំណូលខ្លះ។

### ៣.២.១.១. ការចុះកម្មសិក្សា ឬហាត់ការ

**តារាង 6 ការចុះកម្មសិក្សា ឬហាត់ការ**

| ជំនាញ | | ចុះកម្មសិក្សា/ហាត់ការ | | សរុប |
|---|---|---|---|---|
| | | បាន | មិនបាន | |
| គ្រប់គ្រងធុរកិច្ច | ចំនួន | 57 | 88 | 145 |
| | % | 39.3% | 60.7% | 100.0% |
| សេដ្ឋកិច្ចអភិវឌ្ឍន៍ | ចំនួន | 27 | 78 | 105 |
| | % | 25.7% | 74.3% | 100.0% |
| គណនេយ្យ | ចំនួន | 42 | 88 | 130 |
| | % | 32.3% | 67.7% | 100.0% |
| ធនាគារ និងហិរញ្ញវត្ថុ | ចំនួន | 67 | 111 | 178 |
| | % | 37.6% | 62.4% | 100.0% |
| គ្រប់គ្រងទេសចរណ៍ និងបដិសណ្ឋារកិច្ច | ចំនួន | 6 | 22 | 28 |
| | % | 21.4% | 78.6% | 100.0% |
| **សរុប** | **ចំនួន** | 199 | 387 | 586 |
| | **%** | 34.0% | 66.0% | 100.0% |

តារាងខាងលើបានបង្ហាញថា និស្សិតចំនួន ៣៤,០% បានចុះកម្មសិក្សា ហាត់ការ/ក្នុងចំណោមនិស្សិត សរុបចំនួន ៥៨៦នាក់ ចំណែក ៦៦,០%ទៀត មិនបានចុះធ្វើកម្មសិក្សាទេ។ គួរកត់សម្គាល់ថា និស្សិតដែលបានចុះកម្មសិក្សា/ហាត់ការមានភាគរយច្រើនជាងគេគឺនិស្សិតសិក្សាគ្រប់គ្រងធុរកិច្ចដែលមានចំនួន ៣៩,៣% នៃនិស្សិតសរុបក្នុងជំនាញនេះ១៤៥នាក់ ហើយនិស្សិតដែលចុះកម្មសិក្សាតិចជាងគេគឺនិស្សិតសិក្សាជំនាញទេសចរណ៍និងបដិសណ្ឋារកិច្ចដែលមានចំនួន ២១,៤% នៃនិស្សិតសរុបដែលសិក្សាក្នុងជំនាញនេះ២៨នាក់។

### ៣.២.១.២. ការចុះកម្មសិក្សា/ហាត់ការ និងការទទួលបានចំណូល

- ចំនួននិស្សិតទទួលបានប្រាក់ចំណូលក្នុងអំឡុងពេលចុះកម្មសិក្សា(អប្បបរមា/អតិបរិមា)

- %ធៀបនឹងនិស្សិតចូលរួមឆ្លើយតាមសំណួរ សរុប/ស្រី
- ចំនួននិស្សិតទទួលបានប្រាក់ចំណូលក្នុងអំឡុងពេលចុះកម្មសិក្សាសរុបចំនួន ១៨៨នាក់ ស្មើនឹង ៣២,០៨% នៃចំនួននិស្សិតឆ្លើយសរុប ៥៨៦នាក់ ក្នុងនោះមានស្រីចំនួន ១៣៧នាក់ស្មើនឹងចំនួន ២៣,៣៧%។
- ចំនួននិស្សិតទទួលបានការឧបត្ថម្ភផ្នែកខ្លះ ឬទាំងស្រុងក្នុងអំឡុងពេលចុះកម្មសិក្សា សរុបចំនួន ៦០នាក់ ស្មើនឹង ៣១,៩១% ក្នុងនោះមានស្រីចំនួន ១៣៧នាក់ស្មើនឹងចំនួន ៧២,៨៧%( ទទួលបានការឧបត្ថម្ភទាំងស្រុងមាន ៦នាក់(ស្រី៣នាក់))។
- ប្រាក់ចំណូលប្រចាំខែជាមធ្យម ១៥២,៣$ (អប្បបរមា ៦$ អតិបរមា ៤៥០$ គម្លាតស្តង់ដា ១០៦,០៩$) ករណីជាស្រីទទួលបានប្រាក់ចំណូលជាមធ្យម ១៥៨,៤៦$ ( ប្រុស ១២៩,៤៣$)។

**ក្រាភិច 2 ការចុះកម្មសិក្សា/ហាត់ការ និងការទទួលបានចំណូល**




ក្រាភិកខាងលើបានបង្ហាញក្នុងចំណោមនិស្សិតដែលបានចុះកម្មសិក្សាឬហាត់ការចំនួន១៨៨នាក់ និស្សិតដែលទទួលបានការឧបត្ថម្ភមួយផ្នែក និងទាំងស្រុងមានចំនួន ៣១,៩% ហើយមាននិស្សិតចំនួន ៦៨,១% មិនទទួលបានការឧបត្ថម្ភអ្វីទេ។

មួយចំណែកទៀត ពេលចុះកម្មសិក្សាឬហាត់ការទទួលបានប្រាក់ចំណូលប្រចាំខែ គឺមាននិស្សិតចំនួន ៦០នាក់ ស្មើនឹង ១០,២៣% នៃចំនួននិស្សិតសរុប ៥៨៦នាក់។ ប្រាក់ចំណូលប្រចាំខែជាមធ្យមជាង ១៥២,៣ដុល្លារ ជាមួយគម្លាតស្តង់ដា ១០៦,០៩ដុល្លារ។ ប្រាក់ចំណូលនេះពុំមានភាពខុសគ្នារវាងនិស្សិតប្រុស និងនិស្សិតនារីទេ។

**តារាង 7 តេសលទ្ធផល**

| ភេទ | N | Mean | Std. Deviation | Sig. |
|---|---|---|---|---|
| ប្រុស | 7 | 129.43 | 106.281 | 0.529 |
| ស្រី | 26 | 158.46 | 107.283 | |

*: p<0.10, **: p<0.05, ***: p<0.01

និស្សិតប្រុសទទួលបានប្រាក់ចំណូលប្រចាំខែជាមធ្យម ១២៩,៨៣ដុល្លារ និងនារីទទួលបាន ១៥៨,៤៦ដុល្លារ។

- ប្រាក់ចំណូលសម្រាប់ការចុះកម្មសិក្សាពីពេលចាប់ផ្តើមរហូតដល់ពេលបញ្ចប់នៃការចុះកម្មសិក្សាចំនួនប៉ុន្មានរៀល/ដុល្លារ (ស្រីប៉ុន្មានរៀល/ដុល្លារ)
  - ក្នុងចំណុចនេះពុំមានទិន្នន័យជាថវិកាទេ ប៉ុន្តែសហគ្រាសបានឧបត្ថម្ភមួយផ្នែកដល់និស្សិតកម្មសិក្សាចំនួនសរុប ៣៣នាក់ ក្នុងនោះមានស្រីចំនួន ២៦នាក់ ស្មើនឹង៤,៨៣%នៃនិស្សិតបានឆ្លើយតាមសំណួរ និងមានករណីនារី ៣នាក់ សហគ្រាសបានឧបត្ថម្ភ១០០%ក្នុងរយៈពេលចុះកម្មសិក្សាពេញលេញ។

### ៣.២.២. សេចក្តីពេញចិត្តចំពោះកម្មវិធីសិក្សាដែលអាចឆ្លើយតបទីផ្សារការងារ

- កម្រិតនៃការពេញចិត្តលើកម្មវិធីសិក្សា(%ធៀបនឹងអ្នកឆ្លើយតបសរុប និង%ធៀបនឹងនិស្សិតចូលរួមឆ្លើយតាមសំណួរ)
  - កម្រិតនៃការពេញចិត្តរបស់និស្សិតចំពោះកម្មវិធីសិក្សានៃអ្នកឆ្លើយចំនួន ៥៨៦នាក់ ស្មើនឹង ៩២,២៨% ធៀបនឹងនិស្សិតសរុបចំនួន ៦៣៥នាក់(ស្រីចំនួន ៤៣៧នាក់)
  - កម្រិតសេចក្តីពេញចិត្តរបស់និស្សិតចំពោះកម្មវិធីសិក្សា ដែលគិតថាអាចបំពេញការងារឆ្លើយតបតម្រូវការទីផ្សារបង្ហាញក្នុងតារាងខាងក្រោម៖

**ក្រាភិច 3 កម្រិតសេចក្តីពេញចិត្តរបស់និស្សិតចំពោះកម្មវិធីសិក្សា**




គួរកត់សម្គាល់ថា ក្នុងចំណោមនិស្សិតឆ្លើយតប៥៨៦នាក់ និស្សិតដែលពេញចិត្តកម្មវិធីសិក្សាចាប់ពីកម្រិតបង្គួរទៅដល់កម្រិតពេញចិត្តខ្លាំងណាស់មានចំនួនជាង៩៤,៦% ករណីនិស្សិតពេញចិត្តកម្មវិធីសិក្សាតិចតួចមានចំនួនត្រឹមតែ១,៥% ប៉ុណ្ណោះ រីឯកម្រិតពេញចិត្តខ្លាំងចំពោះកម្មវិធីសិក្សាមានចំនួន ៥,១% គឺច្រើនជាង ៣,៤ដង។

**តារាង 8. តេស្តលទ្ធផល**

| Label | N | Mean | SD | t | Sig. | Lower | Upper |
|---|---|---|---|---|---|---|---|

| | | | | | | | |
|---|---|---|---|---|---|---|---|
| Curriculum Satisfaction | 586 | 3.42 | 0.719 | 115.080 | 0.000 | 3.36 | 3.48 |

*: p<0.10, **: p<0.05, ***: p<0.01

យោងតាមវិធីវាយតម្លៃ One Sample T-Test ក្នុងកម្រិតជឿជាក់ ៩៥% មាននិស្សិតលើសពីចំនួន ៣៨,៧% បានពេញចិត្តខ្លាំង ចំពោះកម្មវិធីសិក្សាដែលបានបណ្តុះបណ្តាលនៅមហាវិទ្យាល័យវិទ្យាសាស្ត្រសេដ្ឋកិច្ចនិងគ្រប់គ្រង។

**តារាង 9 កម្រិតសេចក្តីពេញចិត្តរបស់និស្សិតចំពោះកម្មវិធីសិក្សាតាមតម្រូវការទីផ្សារតាមជំនាញ**

| តារាងពេញចិត្តដោយឡែកចំពោះកម្មវិធីសិក្សាតាមតម្រូវការទីផ្សារ | | | | | | | |
|---|---|---|---|---|---|---|---|
| | | ពេញចិត្តតិចតួច | ពេញចិត្តមធ្យម | ពេញចិត្តបង្គួរ | ពេញចិត្តខ្លាំង | ពេញចិត្តខ្លាំងណាស់ | សរុប |
| គ្រប់គ្រងធុរកិច្ច | ចំនួន | 2 | 6 | 75 | 57 | 5 | 145 |
| | % | 1.4% | 4.1% | 51.7% | 39.3% | 3.4% | 100.0% |
| សេដ្ឋកិច្ចអភិវឌ្ឍន៍ | ចំនួន | 1 | 5 | 59 | 36 | 4 | 105 |
| | % | 1.0% | 4.8% | 56.2% | 34.3% | 3.8% | 100.0% |
| គណនេយ្យ | ចំនួន | 5 | 7 | 76 | 36 | 6 | 130 |
| | % | 3.8% | 5.4% | 58.5% | 27.7% | 4.6% | 100.0% |
| ធនាគារ និងហិរញ្ញវត្ថុ | ចំនួន | 0 | 3 | 74 | 87 | 14 | 178 |
| | % | 0.0% | 1.7% | 41.6% | 48.9% | 7.9% | 100.0% |
| គ្រប់គ្រងទេសចរណ៍និងបដិសណ្ឋារកិច្ច | ចំនួន | 1 | 2 | 13 | 11 | 1 | 28 |
| | % | 3.6% | 7.1% | 46.4% | 39.3% | 3.6% | 100.0% |
| **សរុប** | **ចំនួន** | 9 | 23 | 297 | 227 | 30 | 586 |
| | **%** | 1.5% | 3.9% | 50.7% | 38.7% | 5.1% | 100.0% |

តារាងខាងលើបង្ហាញថា សេចក្តីពេញចិត្តរបស់និស្សិតបញ្ចប់ការសិក្សាតាមជំនាញនីមួយៗ ចំពោះកម្មវិធីសិក្សាចាប់ពីកម្រិតបង្គួរឡើងមានចំនួនលើសពី៩៤,៦%។ គួរឱ្យកត់សម្គាល់ និស្សិតជំនាញធនាគារនិងហិរញ្ញវត្ថុមានសេចក្តីពេញចិត្តចំពោះកម្មវិធីសិក្សាចាប់ពីកម្រិតបង្គួរឡើងមានចំនួន៩៨,៤% ។ រីឯជំនាញគ្រប់គ្រងទេសចរណ៍និងបដិសណ្ឋារកិច្ច សេចក្តីពេញចិត្តចាប់ពីកម្រិតល្អបង្គួរឡើងមានចំនួន ៨៩,៣%។

## ៣.៣. ព័ត៌មានពីកម្មវិធីសិក្សា

កម្មវិធីសិក្សា/ជំនាញទាំង៥ នៃមហាវិទ្យាល័យវិទ្យាសាស្ត្រសេដ្ឋកិច្ចនិងគ្រប់គ្រង បានធ្វើការកែលម្អកម្មវិធីសិក្សាចុងក្រោយនៅឆ្នាំ២០១៨ ឱ្យស្របទៅតាមក្របខ័ណ្ឌគុណវុឌ្ឍិជាតិដែលបានកំណត់ និងបានដាក់ឱ្យអនុវត្តរហូតមកដល់បច្ចុប្បន្ន។ កន្លងមក នៅឆ្នាំសិក្សា ២០២២-២០២៣ គណៈកម្មការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ដែលហៅកាត់ថា «គ.ទ.ក.» បានចុះវាយតម្លៃផ្តល់ការទទួលស្គាល់គុណភាពអប់រំលើគ្រឹះស្ថានឧត្តមសិក្សា និងទទួលបានលទ្ធផលល្អគួរឱ្យកត់សម្គាល់ ក្នុងនោះកម្មវិធីសិក្សានៃមហាវិទ្យាល័យវិទ្យាសាស្ត្រសេដ្ឋកិច្ចនិងគ្រប់គ្រង ក៏បាន

ផ្តល់អនុសាសន៍កែលម្អឱ្យកាន់តែប្រសើរបានម្តងរួចមកហើយ។

- កម្រិតនៃការពេញចិត្តលើបំណិនដែលទទួលបានពីកម្មវិធីបណ្តុះបណ្តាល

ពិន្ទុមធ្យមរួមបានមកពីការស្ទង់មតិរបស់និស្សិត៥៨៦នាក់ដែលបានចូលរួមមានតម្លៃ ៣៤,៣ ជាមួយគម្លាតស្តង់ដា ៥,114 នៃកម្រិតជឿជាក់ ៩៥% គឺនៅចន្លោះពិន្ទុ [៣៣,៨៨ – ៣៤,៧១] (ពិន្ទុអប្បបរមា១៦ និងអតិបរមា៥០) មានន័យថានិស្សិតមានការពេញចិត្តលើបំណិតដែលទទួលបានពីការបណ្តុះបណ្តាលនៅ ស.ភ.ន.វ.ស. ចាប់ពីកម្រិត*ពេញចិត្តខ្លាំង* ឡើងទៅ។




ការវាយតម្លៃតាមរយៈធ្វើតេស្ត

| Label | N | Mean | SD | t | Sig. | Lower | Upper |
|---|---|---|---|---|---|---|---|
| ការពេញលើចិត្តលើបំណិន | 586 | 34.303 | 5.114 | 162.366 | 0.000 | 33.88 | 34.71 |
| *: p<0.10, **: p<0.05, ***: p<0.01 | | | | | | | |

តាមតារាងលទ្ធផលធ្វើតេស្តពិន្ទុស្តីពីបំណិនបញ្ជាក់ថា ៩៥% ជឿជាក់ថា និស្សិតមានការពេញចិត្តខ្លាំងលើបំណិនដែលបានទទួលពីការបណ្តុះបណ្តាលលើជំនាញផ្នែកសេដ្ឋកិច្ចនៅ ស.ភ.ន.វ.ស.។

ខាងក្រោមនេះជាតារាងលទ្ធផល ដែលបានធ្វើការស្រាវជ្រាវជាបន្តទៀតលើនិស្សិតបញ្ចប់ការសិក្សានៅឆ្នាំសិក្សា ២០២២-២០២៣ ចំនួន៥ជំនាញ។ លទ្ធផលចំណាត់ថ្នាក់បំណិនដែលនិស្សិតបញ្ចប់ការសិក្សាបន្ទាប់ពីបានរៀនចប់ក្នុងរយៈពេល៤ឆ្នាំត្រូវបានបង្ហាញលើតារាងខាងក្រោមនេះ៖

**តារាង 10 ចំណាត់ថ្នាក់បំណិនរបស់និស្សិតបញ្ចប់ការសិក្សា**

| លរ | បរិយាយ | | តិចតួច | មធ្យម | ច្រើនបង្គួរ | ច្រើន | ច្រើនណាស់ | សរុប |
|---|---|---|---|---|---|---|---|---|
| ១ | ការច្នៃប្រឌិត | ចំនួន | 3 | 42 | 329 | 194 | 18 | 586 |
| | | % | 0.5% | 7.2% | 56.1% | 33.1% | 3.1% | 100.0% |
| ២ | ការងារជាក្រុម | ចំនួន | 5 | 18 | 191 | 326 | 46 | 586 |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | % | 0.9% | 3.1% | 32.6% | 55.6% | 7.8% | 100.0% |
| ៣ | ការគិតពិចារណា | ចំនួន | 3 | 13 | 218 | 317 | 35 | 586 |
| | | % | 0.5% | 2.2% | 37.2% | 54.1% | 6.0% | 100.0% |
| ៤ | ការដោះស្រាយបញ្ហា | ចំនួន | 4 | 27 | 261 | 265 | 29 | 586 |
| | | % | 0.7% | 4.6% | 44.5% | 45.2% | 4.9% | 100.0% |
| ៥ | សហគ្រិនភាព | ចំនួន | 10 | 53 | 348 | 162 | 13 | 586 |
| | | % | 1.7% | 9.0% | 59.4% | 27.6% | 2.2% | 100.0% |
| ៦ | ភាពជាអ្នកដឹកនាំ | ចំនួន | 7 | 47 | 301 | 206 | 25 | 586 |
| | | % | 1.2% | 8.0% | 51.4% | 35.2% | 4.3% | 100.0% |
| ៧ | ការសម្រេចចិត្ត | ចំនួន | 2 | 23 | 222 | 296 | 43 | 586 |
| | | % | 0.3% | 3.9% | 37.9% | 50.5% | 7.3% | 100.0% |
| ៨ | ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន | ចំនួន | 8 | 64 | 275 | 212 | 27 | 586 |
| | | % | 1.4% | 10.9% | 46.9% | 36.2% | 4.6% | 100.0% |
| ៩ | ការប្រាស្រ័យទាក់ទងគ្នា | ចំនួន | 5 | 28 | 246 | 271 | 36 | 586 |
| | | % | 0.9% | 4.8% | 42.0% | 46.2% | 6.1% | 100.0% |
| ១០ | ភាសាអង់គ្លេស | ចំនួន | 6 | 48 | 346 | 174 | 12 | 586 |
| | | % | 1.0% | 8.2% | 59.0% | 29.7% | 2.0% | 100.0% |

តារាងខាងលើនេះបង្ហាញថា ចំណុចនានានៃបំណិនត្រូវបានបង្ហាញពីកម្រិតនៃការផ្សារភ្ជាប់ទំនាក់ទំនងរវាងទ្រឹស្តីដែលបានសិក្សានិងការអនុវត្តក្នុងការងារជាក់ស្តែងដែលនិស្សិតបានជួបប្រទះ។ គួរឱ្យកត់សម្គាល់ថា ចំណាត់ថ្នាក់ក្នុងចំណោមបំណិននានាដែលវាស់ចាប់ពីកម្រិតច្រើនឡើងទៅ បំណិនដែលមានកម្រិតខ្ពស់ជាងគេ គឺផ្នែក *ការងារជាក្រុម* មានចំនួន ៦៣,៤% ដោយឡែកបំណិនដែលមានកម្រិតទាបជាងគេ គឺផ្នែក *សហគ្រិនភាព* មានចំនួន ២៩,៨% ។

## តារាង 11 ការផ្តល់ចំណាត់ថ្នាក់រវាងទ្រឹស្តីទៅនឹងការអនុវត្តការងារបច្ចុប្បន្ន

| **តារាងបង្ហាញការវាយតម្លៃការផ្សារភ្ជាប់រវាងទ្រឹស្តីទៅនឹងការងារអនុវត្តបច្ចុប្បន្ន** | | | |
|---|---|---|---|
| **កម្រិតវាយតម្លៃ** | **ចំនួន** | **ភាគរយ** | **ភាគរយបូកបង្គរ** |
| តិចតួច | 9 | 1.5% | 1.5% |
| មធ្យម | 25 | 4.3% | 5.8% |
| ច្រើនបង្គួរ | 279 | 47.6% | 53.4% |
| ច្រើន | 239 | 40.8% | 94.2% |
| ច្រើនណាស់ | 34 | 5.8% | 100.0% |
| **សរុប** | 586 | 100.0% | |

នៅលើតារាងខាងលើបង្ហាញថា និស្សិតចំនួន៩៤,២% នៃនិស្សិតឆ្លើយសរុប៥៨៦នាក់ គិតថាទ្រឹស្តីបានផ្សារ

ភ្ជាប់នឹងការអនុវត្តន៍ការងារបច្ចុប្បន្នបានចាប់ពីកម្រិតច្រើនបង្គួរឡើង។ ដោយឡែកមាន និស្សិតចំនួន ៥,៨% គិតថាទ្រឹស្តីបានផ្សារភ្ជាប់នឹងការអនុវត្តការងារជាក់ស្តែងនៅក្រោមកម្រិតច្រើនបង្គួរ។

**ក្រាភិច 4 កម្រិតវាយតម្លៃនៃការផ្សារភ្ជាប់រវាងទ្រឹស្តីនិងការអនុវត្ត**




**តារាង 12 ការផ្តល់ការពេញចិត្តការអនុវត្តន៍ជំនាញក្នុងពេលសិក្សាមានសារៈសំខាន់ចំពោះការងារបច្ចុប្បន្ន**

| តារាងបង្ហាញការការពេញចិត្តការអនុវត្តជំនាញក្នុងពេលសិក្សាមានសារៈសំខាន់ចំពោះការងារបច្ចុប្បន្ន | | | |
|---|---|---|---|
| **កម្រិតវាយតម្លៃ** | **ចំនួន** | **ភាគរយ** | **ភាគរយបូកបង្គរ** |
| តិចតួច | 8 | 1.4% | 1.4% |
| មធ្យម | 27 | 4.6% | 6.0% |
| ច្រើនបង្គួរ | 246 | 42.0% | 48.0% |
| ច្រើន | 265 | 45.2% | 93.2% |
| ច្រើនណាស់ | 40 | 6.8% | 100.0% |
| **សរុប** | 586 | 100.0% | |

ប្រហាក់ប្រហែលនឹងទំនាក់ទំនងរវាងទ្រឹស្តីនិងការអនុវត្តដែរ និស្សិតចំនួន៩៤,០% នៃនិស្សិតឆ្លើយសរុប៥៨៦នាក់ពេញចិត្តការអនុវត្តន៍ជំនាញក្នុងពេលសិក្សាមានសារៈសំខាន់ចំពោះការងារបច្ចុប្បន្ន ចាប់ពីកម្រិតច្រើនបង្គួរឡើង។ ដោយឡែក និស្សិតចំនួន ៦,០% វាយតម្លៃការអនុវត្តជំនាញក្នុងពេលសិក្សាមានសារៈសំខាន់ចំពោះការងារបច្ចុប្បន្ននៅកម្រិតក្រោមច្រើនបង្គួរ។

## ៣.៤. ព័ត៌មានពីស្ថានភាពការងារ

និស្សិតដែលបានចាប់ផ្តើមចូលសិក្សានៅសាកលវិទ្យាល័យអាចមានមួយចំនួនស្វែងរកការងារធ្វើ និងមួយចំនួនទៀតមិនស្វែងរកការងារធ្វើគឺដោយសារមានកត្តាផ្សេងៗដូចជា ចង់បានបទពិសោធន៍ការងារថ្មី កត្តាហិរញ្ញវត្ថុ

ស្វែងរកចំណូលសម្រាប់បំពេញតម្រូវការនៃការសិក្សា ឬកត្តាជីវភាព និងការចូលប្រឡូកក្នុងកិច្ចការសង្គមផ្សេងៗ។ ទំនងដោយសារហេតុផលទាំងនេះហើយ បានជាមាននិស្សិតខ្លះមានការងារធ្វើតាំងតែពីពួកគាត់នៅជានិស្សិតកំពុងសិក្សានៅឡើយ ហើយក៏អាចមាននិស្សិតមួយចំនួនអាចបង្កើតសហគ្រាសខ្នាតតូចផ្ទាល់ខ្លួនបានផងដែរ។ ខាងក្រោមនេះជាស្ថានភាពមានការងារធ្វើរបស់និស្សិត ដែលបានបញ្ចប់ការសិក្សានៅក្នុងដំណាក់កាលបើកលំហរទីផ្សារឡើងវិញនៃនិស្សិតដែលបានបញ្ចប់ការសិក្សានៅឆ្នាំសិក្សា២០២២-២០២៣។

- ចំនួននិស្សិតមានការងារធ្វើ សរុប/ស្រី
  - %ធៀបនឹងនិស្សិតបញ្ចប់ការសិក្សាសរុប សរុប/ស្រី
    និស្សិតមានការងារធ្វើមានចំនួន ៥៥៥នាក់ ស្មើនឹង ៨៧,៤% (ស្រីចំនួន ៤១១នាក់ ស្មើនឹង ៦៤,៧២%) នៃនិស្សិតសរុប ៦៣៥នាក់
  - %ធៀបនឹងនិស្សិតចូលរួមឆ្លើយសរុប សរុប/ស្រី
    និស្សិតមានការងារធ្វើមានចំនួន ៥៥៥នាក់ ស្មើនឹង ៩៤,៧% (ស្រីចំនួន ៤១១នាក់ ស្មើនឹង ៧៤,៦%) នៃនិស្សិតចូលរួមឆ្លើយសំណួរសរុប ៥៨៦នាក់

### ៣.៤.១. ប្រភេទការងាររបស់និស្សិត

**តារាង 13 ប្រភេទការងាររបស់និស្សិត**

| ប្រភេទការងារ | ចំនួន | ភាគរយ | ភាគរយបូកបង្គរ |
|---|---|---|---|
| មិនមានការងារធ្វើ/មិនមានអាជីវកម្មផ្ទាល់ខ្លួន | 31 | 5.3% | 5.3% |
| មានការងារធ្វើ | 429 | 73.2% | 78.5% |
| មានអាជីវកម្មផ្ទាល់ខ្លួន | 12 | 2.0% | 80.5% |
| មានការងារធ្វើ និងមានអាជីវកម្មផ្ទាល់ខ្លួន | 24 | 4.1% | 84.6% |
| មានការងារធ្វើផ្សេងៗ | 42 | 7.2% | 91.8% |
| នៅបន្តការសិក្សា | 13 | 2.2% | 94.0% |
| ព្រះសង្ឃ | 5 | 0.9% | 94.9% |
| ផ្សេងទៀត | 30 | 5.1% | 100.0% |
| **សរុប** | 586 | 100.0% | |

តារាងខាងលើ កត់សម្គាល់ឃើញថា និស្សិតបញ្ចប់ការសិក្សាដែលមានអាជីវកម្មផ្ទាល់ខ្លួនមានចំនួន ២,0% នៃចំនួននិស្សិតឆ្លើយសរុប៥៨៦នាក់។ ចំណែកឯស្ថាប័នផ្សេងទៀតបានស្រូបយកការងារចំនួនជាង ៨៩,0%។

### ៣.៤.២. ប្រភេទកិច្ចសន្យាការងារ

**តារាង 14 ការបង្កើតសហគ្រាសផ្ទាល់ខ្លួន**

| | ចំនួន | ភាគរយ | ភាគរយបង្គរ |
|---|---|---|---|
| កិច្ចសន្យាពេញម៉ោង | 498 | 91.7% | 91.7% |
| កិច្ចសន្យាមិនពេញម៉ោង | 45 | 8.3% | 100.0% |
| សរុប | 543 | 100.0% | |

ក្នុងចំណោមកិច្ចសន្យាការងារ៥៤៣ ក្នុងនោះមានកិច្ចសន្យាការងារពេញម៉ោងចំនួន ៤៩៨ស្មើនឹង ៩១,៧% និងការងារមិនពេញម៉ោងមានចំនួន ៤៥នាក់ ស្មើនឹង ៨,៣%។

- ចំនួននិស្សិតដែលរកបានការងារធ្វើពេញម៉ោងក្រោម១ខែ សរុប/ស្រី
  - %ធៀបនឹងនិស្សិតបញ្ចប់ការសិក្សាសរុប សរុប/ស្រី
    និស្សិតរកបានការងារធ្វើពេញម៉ោងក្រោម១ខែចំនួន ៣៦៣នាក់ ស្មើនឹង៥៧,១៦% (ស្រីចំនួន ២៧៤នាក់ ស្មើនឹង ៤៣,១៤%)នៃនិស្សិតសរុប ៦៣៥នាក់
  - %ធៀបនឹងនិស្សិតចូលរួមឆ្លើយសរុប សរុប/ស្រី
    និស្សិតរកបានការងារធ្វើពេញម៉ោងក្រោម១ខែចំនួន ៣៦៣នាក់ ស្មើនឹង៦១,៩% (ស្រីចំនួន ២៧៤នាក់ ស្មើនឹង ៤៦,៧៥%)នៃនិស្សិតឆ្លើយសរុប ៥៨៦នាក់
  - %ធៀបនឹងនិស្សិតចូលរួមឆ្លើយតាមសំណួរ សរុប/ស្រី
    និស្សិតរកបានការងារធ្វើពេញម៉ោងក្រោម១ខែចំនួន ៣៦៣នាក់ ស្មើនឹង៧៤,៦៩% (ស្រីចំនួន ២៧៤នាក់ ស្មើនឹង ៥៦,៣៧%)នៃនិស្សិតឆ្លើយសរុប ៤៨៦នាក់
  - %ធៀបនឹងនិស្សិតចូលរួមឆ្លើយតាមសំណួរ សរុប/ស្រី
    និស្សិតរកបានការងារធ្វើពេញម៉ោងក្រោម១ខែចំនួន ៣៦៣នាក់ ស្មើនឹង៦៦,៨៥% (ស្រីចំនួន ២៧៤នាក់ ស្មើនឹង ៥០,៤៦%)នៃនិស្សិតសរុប ៥៤៣នាក់
- ចំនួននិស្សិតរកបានការងារធ្វើពេញម៉ោងចន្លោះពី១ខែដល់៣ខែ សរុប/ស្រី
  - %ធៀបនឹងនិស្សិតបញ្ចប់ការសិក្សាសរុប សរុប/ស្រី
    និស្សិតរកបានការងារធ្វើពេញម៉ោងចន្លោះ១ខែដល់៣ខែចំនួន ៧២នាក់ ស្មើនឹង១១,៣៣% (ស្រីចំនួន ៥៤នាក់ ស្មើនឹង ៤,៧%)នៃនិស្សិតសរុប ៦៣៥នាក់
  - %ធៀបនឹងនិស្សិតចូលរួមឆ្លើយសរុប សរុប/ស្រី
    និស្សិតរកបានការងារធ្វើពេញម៉ោងចន្លោះ១ខែដល់៣ខែចំនួន ៧២នាក់ ស្មើនឹង៩,៣% (ស្រីចំនួន ៥៤នាក់ ស្មើនឹង ៨,៥%)នៃនិស្សិតសរុប ៥៨៦នាក់
  - %ធៀបនឹងនិស្សិតចូលរួមឆ្លើយតាមសំណួរ សរុប/ស្រី
    និស្សិតរកបានការងារធ្វើពេញម៉ោងចន្លោះ១ខែដល់៣ខែចំនួន ៧២នាក់ ស្មើនឹង១៤,៨១% (ស្រីចំនួន ៥៤នាក់ ស្មើនឹង ១១,១១%)នៃនិស្សិតសរុប ៤៨៦នាក់
  - %ធៀបនឹងនិស្សិតចូលរួមឆ្លើយតាមសំណួរ សរុប/ស្រី
    និស្សិតរកបានការងារធ្វើពេញម៉ោងចន្លោះ១ខែដល់៣ខែចំនួន ៧២នាក់ ស្មើនឹង១៣,២៦% (ស្រីចំនួន ៥៤នាក់ ស្មើនឹង ៨,២៨%)នៃនិស្សិតសរុប ៥៤៣នាក់

- ចំនួននិស្សិតរកបានការងារធ្វើពេញម៉ោងចន្លោះពី៣ខែដល់៦ខែ សរុប/ស្រី
  - %ធៀបនឹងនិស្សិតបញ្ចប់ការសិក្សាសរុប សរុប/ស្រី
  និស្សិតរកបានការងារធ្វើពេញម៉ោងចន្លោះ៣ខែដល់៦ខែចំនួន ២៣នាក់ ស្មើនឹង៣,៦២% (ស្រីចំនួន ១៨នាក់ ស្មើនឹង ២,៨៣%)នៃនិស្សិតសរុប ៦៣៥នាក់
  - %ធៀបនឹងនិស្សិតចូលរួមឆ្លើយសរុប សរុប/ស្រី
  និស្សិតរកបានការងារធ្វើពេញម៉ោងចន្លោះ៣ខែដល់៦ខែចំនួន ២៣នាក់ ស្មើនឹង៣,៩២% (ស្រីចំនួន ១៨នាក់ ស្មើនឹង ៣,០៧%)នៃនិស្សិតសរុប ៥៨៦នាក់
  - %ធៀបនឹងនិស្សិតចូលរួមឆ្លើយតាមសំណួរ សរុប/ស្រី
  និស្សិតរកបានការងារធ្វើពេញម៉ោងចន្លោះ៣ខែដល់៦ខែចំនួន ២៣នាក់ ស្មើនឹង៤,៧% (ស្រីចំនួន ១៨នាក់ ស្មើនឹង ៣,៧%)នៃនិស្សិតសរុប ៤៨៦នាក់
  - %ធៀបនឹងនិស្សិតមានការងារធ្វើសរុប សរុប/ស្រី
  និស្សិតរកបានការងារធ្វើពេញម៉ោងចន្លោះ៣ខែដល់៦ខែចំនួន ២៣នាក់ ស្មើនឹង៤,២៣% (ស្រីចំនួន ១៨នាក់ ស្មើនឹង ៣,៣១%)នៃនិស្សិតសរុប ៥៤៣នាក់
- ចំនួននិស្សិតរកបានការងារធ្វើពេញម៉ោងចាប់ពី៦ខែចុះក្រោម សរុប/ស្រី
  - %ធៀបនឹងនិស្សិតបញ្ចប់ការសិក្សាសរុប សរុប/ស្រី
  និស្សិតរកបានការងារធ្វើពេញម៉ោងចាប់ពី៦ខែចុះក្រោមចំនួន ៤៥៨នាក់ ស្មើនឹង៧២,១២% (ស្រីចំនួន ៣៤៦នាក់ ស្មើនឹង ៥៤,៤៨%)នៃនិស្សិតសរុប ៦៣៥នាក់
  - %ធៀបនឹងនិស្សិតចូលរួមឆ្លើយសរុប សរុប/ស្រី
  និស្សិតរកបានការងារធ្វើពេញម៉ោងចាប់ពី៦ខែចុះក្រោមចំនួន ៤៥៨នាក់ ស្មើនឹង៧៨,១៥% (ស្រីចំនួន ៣៤៦នាក់ ស្មើនឹង ៥៩,០៤%)នៃនិស្សិតសរុប ៥៨៦នាក់
  - %ធៀបនឹងនិស្សិតចូលរួមឆ្លើយតាមសំណួរ សរុប/ស្រី
  និស្សិតរកបានការងារធ្វើពេញម៉ោងចាប់ពី៦ខែចុះក្រោមចំនួន ៤៥៨នាក់ ស្មើនឹង៩៩,៨% (ស្រីចំនួន ៣៤៦នាក់ ស្មើនឹង ៧១,១៩%)នៃនិស្សិតសរុប ៤៨៦នាក់
  - %ធៀបនឹងនិស្សិតមានការងារធ្វើសរុប សរុប/ស្រី
  និស្សិតរកបានការងារធ្វើពេញម៉ោងចាប់ពី៦ខែចុះក្រោមចំនួន ៤៥៨នាក់ ស្មើនឹង៨៤,៣៤% (ស្រីចំនួន ៣៤៦នាក់ ស្មើនឹង ៦៣,៧២%)នៃនិស្សិតសរុប ៥៤៣នាក់
- ចំនួននិស្សិតរកបានការងារធ្វើពេញម៉ោងលើសពី៦ខែ សរុប/ស្រី
  - %ធៀបនឹងនិស្សិតបញ្ចប់ការសិក្សាសរុប សរុប/ស្រី
  និស្សិតរកបានការងារធ្វើពេញម៉ោងលើសពី៦ខែចំនួន ២៨នាក់ ស្មើនឹង៤,៤% (ស្រីចំនួន ១៩នាក់ ស្មើនឹង ៣,០%)នៃនិស្សិតសរុប ៦៣៥នាក់
  - %ធៀបនឹងនិស្សិតចូលរួមឆ្លើយសរុប សរុប/ស្រី
  និស្សិតរកបានការងារធ្វើពេញម៉ោងលើសពី៦ខែចំនួន ២៨នាក់ ស្មើនឹង៤,៧% (ស្រីចំនួន ១៩នាក់ ស្មើនឹង ៣,២%)នៃនិស្សិតសរុប ៥៨៦នាក់

- %ធៀបនឹងនិស្សិតចូលរួមឆ្លើយតាមសំណួរ សរុប/ស្រី
  និស្សិតរកបានការងារធ្វើពេញម៉ោងលើសពី៦ខែចំនួន ២៨នាក់ ស្មើនឹង៥,៧% (ស្រីចំនួន ១៩នាក់ ស្មើនឹង ៣,៩%)នៃនិស្សិតសរុប ៤៨៦នាក់
- %ធៀបនឹងនិស្សិតមានការងារធ្វើសរុប សរុប/ស្រី
  និស្សិតរកបានការងារធ្វើពេញម៉ោងលើសពី៦ខែចំនួន ២៨នាក់ ស្មើនឹង៥,១% (ស្រីចំនួន ១៩នាក់ ស្មើនឹង ៣,៥%)នៃនិស្សិតសរុប ៥៤៣នាក់

### ៣.៤.៣. ការបង្កើតសហគ្រាសផ្ទាល់ខ្លួន

និស្សិតមួយចំនួនទទួលបានឱកាស និងមានលទ្ធភាពអាចបង្កើតសហគ្រាសអាជីវកម្មផ្ទាល់ខ្លួនបានជាបន្តបន្ទាប់ ក្រោយពីបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យ។ យោងតាមទិន្នន័យអង្កេតនិស្សិតចំនួន ៥៨៦នាក់ និស្សិតដែលមានលទ្ធភាពបង្កើតសហគ្រាសអាជីវកម្មផ្ទាល់ខ្លួនមានចំនួន ១៥៥ ដែលក្នុងនោះមាន ៩៥ ជាអាជីវកម្មខ្នាតតូច ៥៤ ជាអាជីវកម្មខ្នាតមធ្យម និងចំនួន ៦ ជាអាជីវកម្មខ្នាតធំ។ ចំណែក ១៩៣ ជាប្រភេទអាជីវកម្មផ្សេងៗ។ ក្នុងពេលនេះការសិក្សាលើកយកតែប្រភេទអាជីវកម្មខ្នាតតូច ខ្នាតមធ្យម និងខ្នាតធំមកបង្ហាញ។

- ចំនួននិស្សិតមានអាជីវកម្ម/សហគ្រាសផ្ទាល់ខ្លួន សរុប/ស្រី
  - %ធៀបនឹងនិស្សិតបញ្ចប់ការសិក្សាសរុប សរុប/ស្រី
    ចំនួននិស្សិតមានអាជីវកម្ម/សហគ្រាសផ្ទាល់ខ្លួន សរុប ១៥៥នាក់ ស្មើនឹង ២៤,៤% (ស្រីចំនួន ១០០នាក់ ស្មើនឹង ១៥,៧%)នៃនិស្សិតសរុប ៦៣៥នាក់
  - %ធៀបនឹងនិស្សិតចូលរួមឆ្លើយសរុប សរុប/ស្រី
    ចំនួននិស្សិតមានអាជីវកម្ម/សហគ្រាសផ្ទាល់ខ្លួន សរុប ១៥៥នាក់ ស្មើនឹង ២៦,៤៥% (ស្រីចំនួន ១០០នាក់ ស្មើនឹង ១៧,០៦%)នៃនិស្សិតសរុប ៥៨៦នាក់
  - %ធៀបនឹងនិស្សិតចូលរួមឆ្លើយតាមសំណួរ សរុប/ស្រី
    ចំនួននិស្សិតមានអាជីវកម្ម/សហគ្រាសផ្ទាល់ខ្លួន សរុប ១៥៥នាក់ ស្មើនឹង ៤៤,៥៤% (ស្រីចំនួន ១០០នាក់ ស្មើនឹង ២៨,៧៣%)នៃនិស្សិតសរុប ៣៤៨នាក់

**តារាង 15 ការបង្កើតសហគ្រាសផ្ទាល់ខ្លួន**

| តារាងការបង្កើតសហគ្រាសផ្ទាល់ខ្លួនបន្ទាប់ពីបញ្ចប់ការសិក្សា | | | | | |
|---|---|---|---|---|---|
| សហគ្រាសផ្ទាល់ខ្លួន | ទំហំសហគ្រាសអាជីវកម្មផ្ទាល់ខ្លួន/ | | | | សរុប |
| | អាជីវកម្ម ខ្នាតតូច | អាជីវកម្ម ខ្នាតមធ្យម | អាជីវកម្ម ខ្នាតធំ | អាជីវកម្ម ផ្សេងៗ | |
| ចំនួនសហគ្រាស | 95 | 54 | 6 | 193 | 348 |
| ចំនួនភាគរយធៀប(៥៨៦) | 16.2% | 9.2% | 1.0% | 32.9% | 59.4% |
| ចំនួនដែលទទួលយកបាន | 27.3% | 15.5% | 1.7% | 55.5% | 100.0% |

| | | | | | |
|---|---|---|---|---|---|
| ចំនួនភាគរយបង្គរ | 27.3% | 42.8% | 44.5% | 100.0% | |

នៅលើតារាងបង្ហាញឱ្យឃើញថា ក្នុងចំណោមនិស្សិតបញ្ចប់ការសិក្សាបានឆ្លើយសំណួរចំនួន ៥៨៦នាក់ ក្នុងនោះមានចំនួន ៣៤៨នាក់ស្មើនឹង ៥៩,៤% បានបង្កើតសហគ្រាសអាជីវកម្មផ្ទាល់ខ្លួនដែលក្នុងនោះមាន អាជីវកម្មខ្នាតតូច ២៧,៣% អាជីវកម្មខ្នាតមធ្យមមាន ១៥,៥% និងខ្នាតធំមាន ១,៧%។

### ៣.៤.៤. ប្រភេទនៃស្ថាប័នអាជីវកម្មដែលនិស្សិតបញ្ចប់ការសិក្សាបាន និងកំពុងបំពេញការងារ

និស្សិតបញ្ចប់ការសិក្សាបានទៅស្វែងរកការងារធ្វើនៅតាមស្ថាប័ននានា គ្រឹះស្ថានអាជីវកម្មផ្សេងៗទាំងនៅក្នុងស្ថាប័នរដ្ឋ ក៏ដូចជានៅក្នុងក្រុមហ៊ុនឯកជនព្រមទាំងនៅតាមបណ្តាអង្គការជាតិ អង្គការអន្តរជាតិ ភ្នាក់ងារសហប្រតិបត្តិការដែលមានទីតាំងទាំងនៅក្នុងស្រុកនិងនៅឯបរទេសដែរ។

**តារាង 16 ស្ថានភាពការងារនៅតាមស្ថាប័ន**

| តារាងស្ថានភាពការងារនៅតាមស្ថាប័ននានា | | | |
|---|---|---|---|
| | ចំនួន | ភាគរយ | ភាគរយបូកបង្គរ |
| ស្ថាប័នរដ្ឋ | 31 | 5.6% | 5.6% |
| ក្រុមហ៊ុនឯកជន | 455 | 82.9% | 88.5% |
| អង្គការជាតិ | 2 | 0.4% | 88.9% |
| ភ្នាក់ងារសហប្រតិបត្តិការ | 4 | 0.7% | 89.6% |
| ផ្សេងៗ | 57 | 10.4% | 100.0% |
| **សរុប** | 549 | 100.0% | |

តារាងខាងលើបានបង្ហាញថា និស្សិតបញ្ចប់ការសិក្សាបានបម្រើការងារនៅក្នុងវិស័យឯកជនមានចំនួន ៤៥៥នាក់ស្មើនឹង ៨២,៩% នៃនិស្សិតសរុបចំនួន៥៤៩នាក់ ចំណែកស្ថាប័នរដ្ឋផ្តល់ការងារបាន ៥,៦%។ វិស័យឯកជនដើរតួនាទីសំខាន់ក្នុងការស្រូបយកកម្លាំងពលកម្ម បន្ទាប់ពីនិស្សិតបានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យ និងគ្រឹះស្ថានអប់រំនានាជាពិសេសជំនាញក្នុងវិស័យសេដ្ឋកិច្ច។

**ក្រាភិច 5 ភាគរយនិស្សិតទទួលបានការងារធ្វើតាមវិស័យ**




## ៣.៤.៥. ការទទួលបានការងារធ្វើនៅកន្លែងការចុះកម្មសិក្សា

និស្សិតបន្ទាប់ពីបានបញ្ចប់ការសិក្សាភ្លាមបានស្វែងរកការងារធ្វើនៅតាមស្ថាប័ននានាទាំងស្ថាប័នរដ្ឋ ក្រុមហ៊ុនឯកជន និងនៅតាមអង្គការនានាអាស្រ័យតាមលទ្ធភាព សមត្ថភាពដែលនិស្សិតបានសិក្សាពីសាកលវិទ្យាល័យ ឬទៅតាមចំណង់ចំណូលចិត្ត ហើយក៏មាននិស្សិតខ្លះអាចទទួលបានការងារធ្វើនៅនឹងស្ថាប័នឬក្រុមហ៊ុន ដែលធ្លាប់បានចុះកម្មសិក្សាផងដែរ។

**តារាង 17 ចំនួននិស្សិតទទួលបានការងារធ្វើនៅកន្លែងដែលធ្លាប់បានចុះទៅធ្វើកម្មសិក្សា**

| តារាងបង្ហាញចំនួននិស្សិតទទួលបានការងារធ្វើនៅកន្លែងដែលធ្លាប់បានចុះទៅធ្វើកម្មសិក្សា | | | |
|---|---|---|---|
| | ចំនួន | ភាគរយ | ភាគរយបូកបង្គរ |
| បានការងារធ្វើនៅកន្លែងចុះធ្វើកម្មសិក្សាវិញ | 122 | 27.6% | 27.6% |
| មិនបានការងារធ្វើនៅកន្លែងចុះធ្វើកម្មសិក្សា | 320 | 72.4% | 100.0% |
| **សរុប** | 442 | 100.0% | |

តារាងខាងលើបានបង្ហាញថា ក្នុងចំណោមនិស្សិតដែលបានចុះកម្មសិក្សាចំនួន៤៤២នាក់ និស្សិតដែលបានទទួលការងារធ្វើនៅកន្លែងចុះកម្មសិក្សាវិញមានចំនួន ១២២នាក់ ស្មើនឹង ២៧,៦%។ ក្នុងរយៈពេលនៃការបំពេញការងារជាអ្នកហាត់ការនិស្សិតម្នាក់ៗបានបញ្ចេញអស់ពីសមត្ថភាព ដើម្បីធ្វើកិច្ចការទាំងនោះឱ្យបានជោគជ័យ។ ឆ្លងតាមស្នាដៃលទ្ធផលការងារ និស្សិតហាត់ការអាចដឹង ឬអាចទទួលបានការងារធ្វើនៅកន្លែងចុះកម្មសិក្សាបន្ទាប់ពីថេរៈវេលានៃការចុះបំពេញកម្មសិក្សាត្រូវបានបញ្ចប់ និងប្រឡងជាប់ជាស្ថាពរ។

ខាងក្រោមនេះជាក្រាភិកបង្ហាញពីលទ្ធភាពទទួលបានការងារធ្វើនៅកន្លែងដែលបានចុះកម្មសិក្សា។

**ក្រាភិច 6 ភាគរយនៃនិស្សិតដែលត្រូវបានស្ថាប័នទទួលយកមកធ្វើការវិញកាលពីបានមកចុះកម្មសិក្សា**




ក្រាភិកខាងលើបង្ហាញថា និស្សិតភាគច្រើនបានទទួលការងារធ្វើនៅកន្លែងដែលបានចុះកម្មសិក្សាវិញ គឺនៅក្នុងវិស័យឯកជនដែលមាន១០៩នាក់ស្មើនឹង ៨៩,៣% នៃចំនួនបានការងារធ្វើនៅកន្លែងចុះកម្មសិក្សា ១២២នាក់។ ចំណែកឯស្ថាប័នរដ្ឋស្រូបយកធនធាននិស្សិតកម្មសិក្សាឲ្យមកធ្វើការវិញបានចំនួន ៥នាក់ ស្មើនឹង ៤,១%។

### ៣.៤.៦. ទីកន្លែងដែលនិស្សិតទទួលបានការងារធ្វើ

និស្សិតដែលបានបញ្ចប់ការសិក្សាបានទៅបំពេញការងារតាមជំនាញរៀងៗខ្លួន និងនៅតាមស្ថាប័ននានាទូទាំងរាជធានី និងបណ្តាខេត្ត ក្រុងនៃព្រះរាជាណាចក្រកម្ពុជា។ តទៅនេះយើងនឹងដឹងស្ថានភាពទីតាំងការងាររបស់និស្សិតបញ្ចប់ការសិក្សា។ ជាលទ្ធផលបញ្ជាក់ថា ភាគច្រើននៃនិស្សិតបញ្ចប់ការសិក្សាទទួលបានការងារធ្វើនៅក្នុងរាជធានីភ្នំពេញ ៨៤,៣% នៅខេត្តកណ្តាមាន ៧,៧% និងនៅតាមបណ្តាខេត្តនានាមួយចំនួនទៀតមាន ៨,0% ។

**តារាង 18 ទីកន្លែងដែលនិស្សិតទទួលបានការងារធ្វើ**

| ល.រ | រាជធានី/ខេត្ត | ចំនួន | ភាគរយ |
|---|---|---|---|
| 1 | រាជធានីភ្នំពេញ | 382 | 84.3% |
| 2 | កណ្តាល | 35 | 7.7% |
| 3 | កំពុងចាម | 1 | 0.2% |
| 4 | បាត់ដំបង | 2 | 0.4% |
| 5 | ព្រៃវែង | 5 | 1.1% |
| 6 | សៀមរាប | 1 | 0.2% |

| | | | |
|---|---|---|---|
| 7 | តាកែវ | 10 | 2.2% |
| 8 | ត្បូងឃ្មុំ | 1 | 0.2% |
| 9 | បន្ទាយមានជ័យ | 2 | 0.4% |
| 10 | កំពង់ស្ពឺ | 5 | 1.1% |
| 11 | កំពង់ធំ | 2 | 0.4% |
| 12 | កំពង់ឆ្នាំង | 1 | 0.2% |
| 13 | ស្វាយរៀង | 2 | 0.4% |
| 14 | ក្រុងព្រះសីហនុ | 2 | 0.4% |
| 15 | រតនៈគីរី | 1 | 0.2% |
| 16 | ឧត្តមានជ័យ | 1 | 0.2% |
| | សរុប | 453 | 100.0% |

### ៣.៤.៧. ឋានៈការងារនៅក្នុងស្ថាប័ន

ការចាប់ផ្តើមការងារដំបូង អង្គភាពអាជីវកម្ម ឬអង្គភាពរបស់រដ្ឋតែងតែបង្ហាញឋានៈតួនាទីទៅកាន់បុគ្គលិកថ្មីដើម្បីទុកជាព័ត៌មានលើកទឹកចិត្ត។ ខាងក្រោមនេះជាស្ថានភាពនៃឋានៈការងារដែលនិស្សិតបញ្ចប់ការសិក្សាបានទទួលនៅកន្លែងការងារ។

## ក្រាភិច 7 ស្ថានភាពនៃឋានៈការងារ




| | បុគ្គលិកទូទៅ | អ្នកបច្ចេកទេស | អ្នកគ្រប់គ្រងកម្រិតទាម | អ្នកគ្រប់គ្រងកម្រិតកណ្ដាល | អ្នកគ្រប់គ្រងកម្រិតខ្ពស់ |
|---|---|---|---|---|---|
| ចំនួន | 432 | 36 | 21 | 39 | 9 |
| ភាគរយ | 80.4% | 6.7% | 3.9% | 7.3% | 1.7% |

នៅលើក្រាភិកបង្ហាញកម្រិតឋានានុក្រមការងាររបស់និស្សិតបញ្ចប់ការសិក្សាបន្ទាប់ពីទទួលបានការងារធ្វើនៅក្នុងស្ថាប័នរដ្ឋ ឬអង្គភាពអាជីវកម្ម។ ឋានៈឬតួនាទី ទី១ ជាបុគ្គលិកទូទៅមានចំនួន ៨០,4% ទី២ មានតួនាទីជាអ្នកបច្ចេកទេសមានចំនួន ៦,៧% ទី៣ មានតួនាទីជាអ្នកគ្រប់គ្រងកម្រិតកណ្ដាលមានចំនួន ៧,៣% និងទី៤ មានតួនាទីជាអ្នកគ្រប់គ្រងកម្រិតខ្ពស់មានចំនួន ១,៧% ។

### ៣.៤.៨. ភាពមានការងារធ្វើស្របជំនាញច្រើនជាង ឬតិចជាង៥0% នៃកម្មវិធីសិក្សា

#### ៣.៤ .១.៨.ភាពមានការងារធ្វើស្របជំនាញ

ការផ្គូផ្គងការងារគឺជាដំណើរការនៃការកំណត់អត្តសញ្ញាណការងារដែលសមល្អសម្រាប់ជំនាញ បទពិសោធន៍ និងចំណាប់អារម្មណ៍របស់បុគ្គលណាមួយ។ ការផ្គូផ្គងការងារអាចជាឧបករណ៍ដ៏មានតម្លៃសម្រាប់អ្នកស្វែងរកការងារ និងនិយោជក។ សម្រាប់អ្នកស្វែងរកការងារ វាអាចជួយឱ្យពួកគេកំណត់អត្តសញ្ញាណការងារដែលពួកគេមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងដែលពួកគេទំនងជាចូលចិត្ត។ សម្រាប់និយោជក វាអាចជួយពួកគេស្វែងរកបេក្ខជនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលស័ក្តិសមសម្រាប់មុខតំណែងបើកចំហរបស់ពួកគេ។ គុណភាពនៃការផ្គូផ្គងការងារគឺជារង្វាស់សមត្ថភាពថាតើលក្ខណៈរបស់បុគ្គលិកត្រូវគ្នានឹងការងារបែបណា។ វាមានសារៈសំខាន់សម្រាប់អ្នកស្វែងរកការងារ និងនិយោជកក្នុងការពិចារណាអំពីគុណភាពនៃការងារដែលត្រូវគ្នានៅពេលធ្វើការនៃសម្រេចចិត្តអំពីការងារ។

លទ្ធផលនៃការសិក្សាបង្ហាញថា និស្សិត ៥៤៦នាក់ ក្នុងនោះមាន ៣០៧នាក់ ស្មើនឹង ៥៦,២% មានការងារធ្វើស្របជំនាញតាមកម្មវិធីសិក្សាដែលបានរៀនចប់ពីសាកលវិទ្យាល័យ និងចំនួន ២៣៩នាក់ស្មើនឹង ៤៣,៨% មានការងារធ្វើមិនស្របជំនាញ។ តារាងខាងក្រោមនេះបង្ហាញចំនួនភាគរយនៃនិស្សិតមានការងារធ្វើស្របជំនាញបន្ទាប់ពីបានបញ្ចប់សិក្សាពី ស.ភ.ន.វ.ស.។

## តារាង 19 ភាពមានការងារធ្វើស្របតាមជំនាញ

| ភាពមានការងារធ្វើស្របតាមជំនាញ | | | | |
|---|---|---|---|---|
| | | មានការងារធ្វើស្របជំនាញ | មានការងារធ្វើមិនស្របជំនាញ | សរុប |
| គ្រប់គ្រងធុរកិច្ច | ចំនួន | 85 | 51 | 136 |
| | % | 62.5% | 37.5% | 100.0% |
| សេដ្ឋកិច្ចអភិវឌ្ឍន៍ | ចំនួន | 39 | 54 | 93 |
| | % | 41.9% | 58.1% | 100.0% |
| គណនេយ្យ | ចំនួន | 62 | 63 | 125 |
| | % | 49.6% | 50.4% | 100.0% |
| ធនាគារ និងហិរញ្ញវត្ថុ | ចំនួន | 111 | 57 | 168 |
| | % | 66.1% | 33.9% | 100.0% |
| គ្រប់គ្រងទេសចរណ៍ និងបដិសណ្ឋារកិច្ច | ចំនួន | 10 | 14 | 24 |
| | % | 41.7% | 58.3% | 100.0% |
| **សរុប** | **ចំនួន** | 307 | 239 | 546 |
| | **%** | 56.2% | 43.8% | 100.0% |

តារាងខាងលើបង្ហាញថា ជំនាញគ្រប់គ្រងធុរកិច្ចចំនួន ៦២,៥% និងរត់ពីមុខដោយជំនាញធនាគារនិងហិរញ្ញវត្ថុទទួលបានការងារធ្វើស្របចំនួន ៦៦,១% ក្នុងករណីដែលជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍ និងគ្រប់គ្រងទេសចរណ៍និងបដិសណ្ឋារកិច្ចទទួលបានការងារធ្វើភាគច្រើនមិនស្របតាមជំនាញមានចំនួនប្រហែលគ្នាជាង ៥៨% ដែលបានសិក្សាពីសាកលវិទ្យាល័យ។

- ចំនួននិស្សិតមានការងារធ្វើត្រូវនឹងជំនាញ សរុប/ស្រី
  - %ធៀបនឹងនិស្សិតបញ្ចប់ការសិក្សាសរុប សរុប/ស្រី
    ចំនួននិស្សិតមានការងារធ្វើត្រូវនឹងជំនាញ សរុប ៣០៧នាក់ ស្មើនឹង៤៨,៣៤% (ស្រី២២២នាក់ ស្មើនឹង ៣៤,៩៦%)នៃនិស្សិតសរុប ៦៣៥នាក់
  - %ធៀបនឹងនិស្សិតចូលរួមឆ្លើយសរុប សរុប/ស្រី
    ចំនួននិស្សិតមានការងារធ្វើត្រូវនឹងជំនាញ សរុប ៣០៧នាក់ ស្មើនឹង៥២,៤% (ស្រី២២២នាក់ ស្មើនឹង ៣៧,៨៨%)នៃនិស្សិតសរុប ៥៨៦នាក់
  - %ធៀបនឹងនិស្សិតចូលរួមឆ្លើយតាមសំណួរ សរុប/ស្រី
    ចំនួននិស្សិតមានការងារធ្វើត្រូវនឹងជំនាញ សរុប ៣០៧នាក់ ស្មើនឹង៥៦,២% (ស្រី២២២នាក់ ស្មើនឹង ៤០,៦៥%)នៃនិស្សិតសរុប ៥៤៦នាក់
  - %ធៀបនឹងនិស្សិតមានការងារធ្វើសរុប សរុប/ស្រី
    ចំនួននិស្សិតមានការងារធ្វើត្រូវនឹងជំនាញ សរុប ៣០៧នាក់ ស្មើនឹង៥៥,៣១% (ស្រី២២២នាក់ ស្មើនឹង ៤០,០%)នៃនិស្សិតសរុប ៥៥៥នាក់

## ក្រាភិច ៩ ភាគរយធ្វើការស្របជំនាញ និងមិនស្របជំនាញ




| | គ្រប់គ្រងធុរកិច្ច | សេដ្ឋកិច្ចអភិវឌ្ឍន៍ | គណនេយ្យ | ធនាគារនិងហិរញ្ញវត្ថុ | ទេសចរណ៍ និងបដិសណ្ឋារកិច្ច |
|---|---|---|---|---|---|
| ត្រូវជំនាញ ចំនួន | 85 | 39 | 62 | 111 | 10 |
| ត្រូវជំនាញ ភាគរយ | 27.7% | 12.7% | 20.2% | 36.2% | 3.3% |
| ខុសជំនាញ ចំនួន | 51 | 54 | 63 | 57 | 14 |
| ខុសជំនាញ ភាគរយ | 21.3% | 22.6% | 26.4% | 23.8% | 5.9% |

តាមក្រាភិកខាងលើបានបង្ហាញថា ជំនាញគ្រប់គ្រងធុរកិច្ចមានការងារធ្វើស្របជំនាញ ៣៧,៧% និង ជំនាញធនាគារនិងហិរញ្ញវត្ថុមាន ៣៦,២% ធៀបនឹងនិស្សិតមានការងារធ្វើស្របជំនាញ។ ដោយឡែកជំនាញគណនេយ្យមាននិស្សិតទៅបំពេញការងារមិនស្របជំនាញ ២៦,៤% ច្រើនជាងគេធៀបនឹងការងារមិនស្របជំនាញ។

### ៣.៤ .២.៨.ភាពមានការងារធ្វើមិនស្របជំនាញ

ជាធម្មតានិស្សិតបានរៀនចប់លើជំនាញអ្វីតែងតែស្វែងរកការងារធ្វើលើជំនាញនោះ។ ប៉ុន្តែភាពមានការងារធ្វើ វាក៏អាចអាស្រ័យលើចំណង់ចំណូលចិត្តរបស់និស្សិតបញ្ចប់ការសិក្សាផងដែរ ឬអាចនឹងមាននិស្សិតមួយចំនួនបានសម្រេចចិត្តរកការងារធ្វើអាស្រ័យតាមកត្តាផ្សេងៗ ដែលទាក់ទងទៅនឹងស្ថានភាពជីវភាពរស់នៅទៅតាមកាលៈទេសៈដែលតម្រូវឱ្យ។ ជាបន្តយើងនឹងពិនិត្យមើលលទ្ធផលនៃការទទួលបានការងារករណីមិនស្របជំនាញ។

ការជ្រើសរើសការងារមិនស្របជំនាញ គឺជាស្ថានភាពមួយដែលមនុស្សម្នាក់ជ្រើសរើសការងារដែលមិនសមស្របនឹងជំនាញ ឬការអប់រំរបស់ពួកគេ។ នេះអាចកើតឡើងដោយសារហេតុផលជាច្រើនដូចជា៖

- ពួកគេប្រហែលជាមិនអាចស្វែងរកការងារដែលត្រូវនឹងជំនាញ ឬការអប់រំរបស់ពួកគេបានទេ
- ពួកគេអាចមានឆន្ទៈក្នុងការទទួលយកការងារដែលទាបជាងលក្ខណៈសម្បត្តិរបស់ពួកគេសម្រាប់ហេតុផលហិរញ្ញវត្ថុ
- ពួកគេអាចចាប់អារម្មណ៍លើវិស័យ ឬឧស្សាហកម្មជាក់លាក់មួយ ទោះបីជាវាមិនត្រូវការជំនាញ ឬការអប់រំជាក់លាក់របស់ពួកគេក៏ដោយ
- ពួកគេប្រហែលជាមានឆន្ទៈក្នុងការចាប់យកការងារដែលជាជំហានមួយឆ្ពោះទៅរកអាជីពដែលចង់បានជាង

ការជ្រើសរើសការងារមិនស្របជំនាញអាចមានផលវិបាកអវិជ្ជមានមួយចំនួន រួមមាន÷

- ប្រាក់ឈ្នួលទាប
- ការពេញចិត្តការងារតិច
- ភាពតានតឹងកើនឡើង
- លទ្ធភាពនៃចំណូលកើនឡើង
- កាត់បន្ថយផលិតភាព

មានរឿងមួយចំនួនដែលមនុស្សអាចធ្វើបាន ដើម្បីជៀសវាងការជ្រើសរើសការងារមិនស្របជំនាញ ដូចជា៖

- យល់ច្បាស់អំពីជំនាញ និងចំណាប់អារម្មណ៍របស់ពួកគេ
- ធ្វើការស្រាវជ្រាវលើជម្រើសអាជីពផ្សេងៗ
- រកបណ្តាញជាមួយមនុស្សនៅក្នុងវិស័យដែលពួកគេចង់បាន
- ទទួលបានកម្មសិក្សា ឬបទពិសោធន៍ស្ម័គ្រចិត្ត
- មានឆន្ទៈផ្លាស់ប្តូរទីលំនៅ

ប្រសិនបើអ្នកស្ថិតក្នុងស្ថានភាពការងារមិនស្របជំនាញ មានរឿងមួយចំនួនដែលអ្នកអាចធ្វើដើម្បីកែលម្អស្ថានភាពរបស់អ្នក ដូចជា៖

- និយាយជាមួយអ្នកគ្រប់គ្រងរបស់អ្នកអំពីគោលដៅអាជីពរបស់អ្នក
- ទទួលបន្ទុកបន្ថែម
- ទទួលបានការបណ្តុះបណ្តាល ឬវិញ្ញាបនបត្រលើជំនាញថ្មីៗ
- រកបណ្តាញជាមួយមនុស្សនៅក្នុងវិស័យដែលអ្នកចង់បាន
- ចាប់ផ្តើមស្វែងរកការងារថ្មី

វាជាការសំខាន់ដែលត្រូវចងចាំថាជម្រើសការងារមិនស្របជំនាញនឹងមិនតែងតែអាក្រក់ទាំងអស់នោះទេ។ ពេលខ្លះពួកគេអាចជាជំហានឆ្ពោះទៅរកអាជីពដែលចង់បាន។ ទោះជាយ៉ាងណាក៏ដោយ វាជាការសំខាន់ណាស់ដែលត្រូវដឹងអំពីផលវិបាកដែលអាចកើតមាននៃជម្រើសការងារដែលមិនស្របជំនាញមុនពេលចាប់ផ្តើមធ្វើការដំបូង។

**ក្រាភិច ១ ភាពមានការងារធ្វើមិនស្របតាមជំនាញ**




| | ប្រាក់ឈ្នួលច្រើន | ទីផ្សារចង្អៀត | មានអាជីវកម្មផ្ទាល់ខ្លួន | តាមតម្រូវការទីផ្សារ | ចំណង់ចំណូលចិត្ត | ផ្សេងៗ |
|---|---|---|---|---|---|---|
| ចំនួន | 52 | 100 | 27 | 69 | 59 | 133 |
| ភាគរយ | 11.8% | 22.7% | 6.1% | 15.7% | 13.4% | 30.2% |

ក្រាភិកខាងលើបានបង្ហាញថា ការប្រែប្រួលភាពមានការងារធ្វើមិនស្របជំនាញអាស្រ័យទៅតាមកត្តាផ្សេងៗ មានដូចជា ទី១ ទទួលបានប្រាក់ឈ្នួលច្រើន ១១,៨% ទី២ មានទីផ្សារចង្អៀត២២,៧% ទី៣ មានអាជីវកម្មផ្ទាល់ខ្លួនចំនួន ៦,១% ទី៤ តាមតម្រូវការទីផ្សារមានចំនួន ១៥,៧% ទី៥ តាមចំណង់ចំណូលចិត្តមានចំនួន ១៣,៦% ទី៦ ការងារផ្សេងៗមានចំនួន ៣០,២% ។ មានន័យថាការមានការងារធ្វើមិនស្របជំនាញ កាលៈទេសៈខ្លះមានការពាក់ព័ន្ធជាមួយបុគ្គលផ្ទាល់ផងដែរ។

### ៣.៤.៩. ការទទួលបានប្រាក់ចំណូលប្រចាំខែ

គោលគំនិតនៃប្រាក់ឈ្នួល សំដៅលើសំណងជារូបិយវត្ថុដែលនិយោជកបង់ឱ្យនិយោជិតជាថ្នូរនឹងការងារដែលបានធ្វើ។ ប្រាក់ឈ្នួលអាចត្រូវបានបង់ក្នុងមួយម៉ោង ប្រចាំថ្ងៃ ឬតាមអត្រាដុំ។ វាគឺជាការចំណាយចម្បងមួយនៃអាជីវកម្ម ហើយវាអាចប្រែប្រួលអាស្រ័យលើកត្តាមួយចំនួនដូចជាកម្រិតជំនាញរបស់បុគ្គលិក ទីតាំងនៃការងារ និងតម្លៃនៃការរស់នៅ។ ប្រាក់ឈ្នួលមានពីរប្រភេទសំខាន់ៗ៖

– **ប្រាក់ឈ្នួលអប្បបរមា៖** ប្រាក់ឈ្នួលអប្បបរមាគឺជាចំនួនប្រាក់កម្រៃទាបបំផុតដែលនិយោជកត្រូវបានអនុញ្ញាតឱ្យបង់ទៅឱ្យនិយោជិតដោយស្របច្បាប់។ វាត្រូវបានកំណត់ដោយច្បាប់នៅក្នុងប្រទេសភាគច្រើន ហើយវាត្រូវបានបង្កើតឡើងដើម្បីធានាថាបុគ្គលិកទាំងអស់ទទួលបានប្រាក់ឈ្នួលសម្រាប់ចិញ្ចឹមជីវិត។

ករណីប្រាក់ឈ្នួលអប្បបរមានៅកម្ពុជា ក្រសួងការងារបានធ្វើការកែលម្អជាបន្តបន្ទាប់៖

- គិតត្រឹមខែមករា ឆ្នាំ 2024 ប្រាក់ឈ្នួលអប្បបរមារបស់កម្ពុជាសម្រាប់កម្មករក្នុងវិស័យសំខាន់ៗដូចជា កាត់ដេរ វាយនភ័ណ្ឌ ស្បែកជើង ទំនិញធ្វើដំណើរ និងកាបូបត្រូវបានកំណត់នៅ 204 ដុល្លារក្នុងមួយខែ ដែលឆ្លុះបញ្ចាំងពីការកើនឡើង 4 ដុល្លារពីឆ្នាំ 2023។ តួលេខនេះអនុវត្តចំពោះកម្មករដែលមានបទពិសោធន៍ ខណៈពេលដែល និយោជិតថ្មីរកបាន 202 ដុល្លារក្នុងអំឡុងពេលសាកល្បងរបស់ពួកគេ។
- សេចក្ដីសម្រេចនេះត្រូវបានបញ្ចប់បន្ទាប់ពីការពិគ្រោះយោបល់ចំនួន 20 វាំងក្រុមប្រឹក្សាជាតិស្ដីពីប្រាក់

ឈ្នួលអប្បបរមា (NCMW) និងអ្នកពាក់ព័ន្ធ ដោយបន្ថែមទឹកប្រាក់បន្ថែមចំនួន 2 ដុល្លារដោយលោកនាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែត ទៅនឹងសំណើដំបូងចំនួន 202 ដុល្លារ។ កម្មករនិយោជិតក៏ទទួលបានអត្ថប្រយោជន៍ផងដែរ រួមទាំងប្រាក់បន្ថែមសម្រាប់ចូលរួម ថ្លៃជិះកជញ្ជូន និងថ្លៃជួល និងការផ្តល់អាហារបន្ថែមម៉ោង ដែលអាចនាំមកនូវប្រាក់ចំណូលដ៏មានប្រសិទ្ធភាពរបស់ពួកគេរវង្វង់ $221-$232 ក្នុងមួយខែ។

– **ប្រាក់ឈ្នួលរស់នៅ៖** ប្រាក់ឈ្នួលរស់នៅ គឺជាចំនួនប្រាក់ចំណូលដែលបុគ្គល ឬគ្រួសារត្រូវការដើម្បីបំពេញតម្រូវការមូលដ្ឋានរបស់ពួកគេ ដូចជា លំនៅដ្ឋាន អាហារ មធ្យោបាយធ្វើដំណើរ និងការថែទាំសុខភាព។ ជាធម្មតាវាខ្ពស់ជាងប្រាក់ឈ្នួលអប្បបរមា ហើយជារឿយៗវាត្រូវបានគេប្រើជាគោលសម្រាប់កំណត់ថាតើប្រាក់ឈ្នួលមានភាពយុត្តិធម៌ដែរឬទេ។ គោលគំនិតនៃប្រាក់ឈ្នួលមានសារៈសំខាន់សម្រាប់ហេតុផលមួយចំនួន៖ ទីមួយ វាជួយធានាឱ្យកម្មករនិយោជិតទទួលបានសំណងសមរម្យសម្រាប់កម្លាំងពលកម្មរបស់ពួកគេ ទីពីរ វាអាចជួយកាត់បន្ថយភាពក្រីក្រ និងវិសមភាព ទីបី វាអាចជំរុញសេដ្ឋកិច្ចតាមរយៈការបង្កើនការចំណាយរបស់អ្នកប្រើប្រាស់។

មានកត្តាមួយចំនួនដែលអាចប៉ះពាល់ដល់ប្រាក់ឈ្នួល រួមមាន៖

– កម្រិតជំនាញរបស់និយោជិត៖ កម្មករដែលមានកម្រិតជំនាញខ្ពស់ ជាធម្មតាទទួលបានប្រាក់ឈ្នួលខ្ពស់ជាង
– ទីតាំងនៃការងារ៖ ប្រាក់ឈ្នួលមានទំនោរទៅទីប្រជុំជនខ្ពស់ជាងនៅតំបន់ជនបទ
– តម្លៃនៃការរស់នៅ៖ ប្រាក់ឈ្នួលត្រូវខ្ពស់ល្មមនឹងចំណាយលើការរស់នៅក្នុងតំបន់ដែលមានការងារធ្វើ
– ការផ្គត់ផ្គង់ និងតម្រូវការកម្លាំងពលកម្ម៖ ប្រាក់ឈ្នួលមានទំនោរខ្ពស់នៅពេលមានការខ្វះខាតកម្មករក្នុងវិស័យជាក់លាក់ណាមួយ
– ប្រាក់ឈ្នួលអប្បបរមា៖ ប្រាក់ឈ្នួលអប្បបរមាកំណត់ជាន់លើប្រាក់ឈ្នួល ហើយវាអាចប៉ះពាល់ដល់ប្រាក់ឈ្នួលរបស់កម្មករទាំងអស់

គំនិតនៃប្រាក់ឈ្នួលគឺស្មុគស្មាញមួយ ហើយវាត្រូវបានជះឥទ្ធិពលដោយកត្តាមួយចំនួន។ ទោះជាយ៉ាងនេះក្តី វាជាគោលគំនិតដ៏សំខាន់ដែលជះឥទ្ធិពលយ៉ាងខ្លាំងដល់ជីវិតរបស់កម្មករ និងសេដ្ឋកិច្ចទាំងមូល។

- និស្សិតទទួលបានប្រាក់ចំណូល២ដងធៀបនឹងអ្នកគ្មានជំនាញ សរុប/ស្រី
  - %ធៀបនឹងនិស្សិតចូលរួមឆ្លើយសរុប សរុប/ស្រី
    និស្សិតទទួលបានប្រាក់ចំណូល២ដងធៀបនឹងអ្នកគ្មានជំនាញ សរុប ៩២នាក់ ស្មើនឹង ១៥,៦៩% (ស្រី ៦១នាក់ ស្មើនឹង ១០,៤%)នៃនិស្សិតចូលរួមឆ្លើយសរុប ៥៨៦នាក់
  - %ធៀបនឹងនិស្សិតចូលរួមឆ្លើយតាមសំណួរ សរុប/ស្រី
    និស្សិតទទួលបានប្រាក់ចំណូល២ដងធៀបនឹងអ្នកគ្មានជំនាញ សរុប ៩២នាក់ ស្មើនឹង ១៦,៩៧% (ស្រី ៦១នាក់ ស្មើនឹង ១១,២៥%)នៃនិស្សិតចូលរួមឆ្លើយតាមសំណួរសរុប ៥៤២នាក់
  - %ធៀបនឹងនិស្សិតមានការងារធ្វើសរុប សរុប/ស្រី
    និស្សិតទទួលបានប្រាក់ចំណូល២ដងធៀបនឹងអ្នកគ្មានជំនាញ សរុប ៩២នាក់ ស្មើនឹង ១៦,៥៧% (ស្រី ៦១នាក់ ស្មើនឹង ១០,៩៩%)នៃនិស្សិតសរុប ៥៥៥នាក់
- និស្សិតទទួលបានប្រាក់ចំណូល៣ដងធៀបនឹងអ្នកគ្មានជំនាញ សរុប/ស្រី
  - %ធៀបនឹងនិស្សិតចូលរួមឆ្លើយសរុប សរុប/ស្រី

និស្សិតទទួលបានប្រាក់ចំណូល៣ដងធៀបនឹងអ្នកគ្មានជំនាញ សរុប ២៥នាក់ ស្មើនឹង ៤,២៦% (ស្រី១៦ នាក់ ស្មើនឹង ២,៧៣%)នៃនិស្សិតសរុប ៥៨៦នាក់

- %ធៀបនឹងនិស្សិតចូលរួមឆ្លើយតាមសំណួរ សរុប/ស្រី
  និស្សិតទទួលបានប្រាក់ចំណូល៣ដងធៀបនឹងអ្នកគ្មានជំនាញ សរុប ២៥នាក់ ស្មើនឹង ៤,៦១% (ស្រី ១៦ នាក់ ស្មើនឹង ២,៩៥%)នៃនិស្សិតចូលរួមឆ្លើយតាមសំណួរសរុប ៥៤២នាក់
- %ធៀបនឹងនិស្សិតមានការងារធ្វើសរុប សរុប/ស្រី
  និស្សិតទទួលបានប្រាក់ចំណូល៣ដងធៀបនឹងអ្នកគ្មានជំនាញ សរុប ២៥នាក់ ស្មើនឹង ៤,៥% (ស្រី ១៦ នាក់ ស្មើនឹង ២,៨៨%)នៃនិស្សិតសរុប ៥៥៥នាក់

- និស្សិតទទួលបានប្រាក់ចំណូល៤ដងធៀបនឹងអ្នកគ្មានជំនាញ សរុប/ស្រី
  - %ធៀបនឹងនិស្សិតចូលរួមឆ្លើយសរុប សរុប/ស្រី
    និស្សិតទទួលបានប្រាក់ចំណូល៤ដងធៀបនឹងអ្នកគ្មានជំនាញ សរុប ៤នាក់ ស្មើនឹង ០,៦៨% (ស្រី ២នាក់ ស្មើនឹង ០,៣៤%)នៃនិស្សិតសរុប ៥៨៦នាក់
  - %ធៀបនឹងនិស្សិតចូលរួមឆ្លើយតាមសំណួរ សរុប/ស្រី
    និស្សិតទទួលបានប្រាក់ចំណូល៤ដងធៀបនឹងអ្នកគ្មានជំនាញ សរុប ៤នាក់ ស្មើនឹង ០,៧៣% (ស្រី២នាក់ ស្មើនឹង ០,៣៦%)នៃនិស្សិតសរុប ៥៤២នាក់
  - %ធៀបនឹងនិស្សិតមានការងារធ្វើសរុប សរុប/ស្រី
    និស្សិតទទួលបានប្រាក់ចំណូល៤ដងធៀបនឹងអ្នកគ្មានជំនាញ សរុប ៤នាក់ ស្មើនឹង ០,៧២% (ស្រី២នាក់ ស្មើនឹង ០,៣៦%)នៃនិស្សិតសរុប ៥៥៥នាក់
- និស្សិតទទួលបានប្រាក់ចំណូល៥ដងធៀបនឹងអ្នកគ្មានជំនាញ សរុប/ស្រី
  - %ធៀបនឹងនិស្សិតចូលរួមឆ្លើយសរុប សរុប/ស្រី
    និស្សិតទទួលបានប្រាក់ចំណូល៥ដងធៀបនឹងអ្នកគ្មានជំនាញ សរុប ៨នាក់ ស្មើនឹង ១,៣៦% (ស្រី៦នាក់ ស្មើនឹង ១,០២%)នៃនិស្សិតសរុប ៥៨៦នាក់
  - %ធៀបនឹងនិស្សិតចូលរួមឆ្លើយតាមសំណួរ សរុប/ស្រី
    និស្សិតទទួលបានប្រាក់ចំណូល៥ដងធៀបនឹងអ្នកគ្មានជំនាញ សរុប ៨នាក់ ស្មើនឹង ១,៤៧% (ស្រី៦នាក់ ស្មើនឹង ១,១%)នៃនិស្សិតសរុប ៥៤២នាក់
  - %ធៀបនឹងនិស្សិតមានការងារធ្វើសរុប សរុប/ស្រី
    និស្សិតទទួលបានប្រាក់ចំណូល៥ដងធៀបនឹងអ្នកគ្មានជំនាញ សរុប ៨នាក់ ស្មើនឹង ១,៤៤% (ស្រី៦នាក់ ស្មើនឹង ១,០៨%)នៃនិស្សិតសរុប ៥៥៥នាក់

## ក្រាភិច 10 ប្រាក់ចំណូលប្រចាំខែ




ប្រាក់ចំណូលប្រចាំខែមានការប្រែប្រួលខ្លាំង និងផ្តុំនៅចន្លោះ ២០០$-៤០០$ និង ៤០១$-៦០០$។ ប្រាក់ឈ្នួលលើសពី ៦០០$ គឺមានកម្រិតភាគរយទាបគួរឱ្យកត់សម្គាល់។ ប្រាក់ចំណូលប្រចាំខែរបស់និស្សិតដែលបានបញ្ចប់ការសិក្សាកាលពីឆ្នាំសិក្សា ២០២២-២០២៣ បានផ្តល់ព័ត៌មានស្តីពីប្រាក់ឈ្នួលតាមរយៈកម្រងសំណួរបានឱ្យដឹងថានិស្សិតទទួលបានប្រាក់ចំណូលប្រចាំខែច្រើនជាងគេគឺចន្លោះ ២០១$-៤០០$ មានចំនួន ៦៨,៥%។ ករណីបើប្រៀបធៀបជាមួយអ្នកគ្មានជំនាញដែលទទួលបានប្រាក់ឈ្នួលជាមធ្យមប្រចាំខែ ២០០$ គឺមានពីរករណីដែលគួរចាប់អារម្មណ៍ទី១. ប្រាក់ចំណូលប្រចាំខែនៅចន្លោះ ៨០១$-១០០០$ មានចំនួន ៧,០% ដែលលើសយ៉ាងតិច ៤ដង បើធៀបនឹងកម្មករគ្មានជំនាញ និងទី២. ប្រាក់ចំណូលប្រចាំខែច្រើនជាង ១០០០$ មានចំនួន ១,៥% ដែលលើសយ៉ាងតិច៥ដង បើធៀបនឹងកម្មករគ្មានជំនាញ។ គួរកត់សម្គាល់ផងដែរ បើគិតបង្រួមប្រាក់ឈ្នួលនៅចន្លោះចាប់ពី 200$-600$ មានចំនួនរហូតដល់ ៨៥,៥%។

**តារាង 20 តេស្តលទ្ធផលទាក់ទងការផ្តល់ប្រាក់ឈ្នួលតាមភេទ និងធ្វើការត្រូវតាមជំនាញ**

| Variable | Label | N | Mean | SD | t | Sig. |
|---|---|---|---|---|---|---|
| Salary ( $ ) | Male | 138 | 2.36 | 0.904 | 1.615 | 0.003*** |
| | Female | 404 | 2.23 | 0.781 | | |
| Salary ( $ ) | Job match | 300 | 2.36 | 0.879 | 2.774 | 0.001*** |
| | Job mismatch | 229 | 2.16 | 0.723 | | |

*: p<0.10, * *: p<0.05, * * *: p<0.01

តារាងខាងលើបានបង្ហាញថា៖

លទ្ធផលតេស្ត ANOVA តាមវិធី Independent sample t-test ប្រៀបធៀបគម្លាតប្រាក់ខែមធ្យម បង្ហាញថា៖

- **ប្រាក់ខែមធ្យមរបស់បុរស និង នារី** វាទំនងមានភាពខុសគ្នាក្នុងកម្រិតនៃភាពជឿជាក់ ៩៥%

- **វាទំនងអាចមានភាពខុសគ្នាក្នុងការទទួលបានប្រាក់ចំណូលច្រើន**រវាងអ្នកធ្វើការស្របជំនាញ និងអ្នកធ្វើការមិនស្របជំនាញក្នុងកម្រិតនៃភាពជឿជាក់ ៩៥%។

### ៣.៤.១០. ករណីនានាដែលមិនទាន់មានការងារធ្វើ

- ភាពគ្មានការងារធ្វើគឺជាស្ថានភាពនៃបុគ្គលដែលកំពុងស្វែងរកការងារធ្វើយ៉ាងសកម្មមិនអាចស្វែងរកការងារធ្វើបាន។
- អត្រាអត់ការងារធ្វើគឺជាភាគរយនៃកម្លាំងពលកម្មដែលអត់ការងារធ្វើ។ វាត្រូវបានគណនាដោយបែងចែកចំនួនអ្នកគ្មានការងារធ្វើដោយកម្លាំងពលកម្មសរុប ហើយគុណនឹង 100 ។
- ភាពគ្មានការងារធ្វើមានបីប្រភេទសំខាន់ៗ៖ វដ្តគ្មានការងារធ្វើ រចនាសម្ព័ន្ធការងារ និងដោយប្រយោល។
  - **វដ្តគ្មានការងារធ្វើ** គឺបណ្តាលមកពីការប្រែប្រួលនៃវដ្តអាជីវកម្ម។ វាកើតឡើងនៅពេលដែលមានវិបត្តិសេដ្ឋកិច្ចហើយអាជីវកម្មត្រូវបញ្ឈប់បុគ្គលិក។
  - **ភាពគ្មានការងារធ្វើតាមរចនាសម្ព័ន្ធ** គឺបណ្តាលមកពីការផ្លាស់ប្តូរនៅក្នុងសេដ្ឋកិច្ច ដូចជាការផ្លាស់ប្តូរបច្ចេកវិទ្យា ឬសកលភាវូបនីយកម្ម។ វាកើតឡើងនៅពេលដែលជំនាញរបស់កម្មករលែងមានតម្រូវការ។
  - **ភាពគ្មានការងារធ្វើដោយប្រយោល** គឺបណ្តាលមកពីការផ្លាស់ប្តូរធម្មតានៃទីផ្សារការងារ។ វាកើតឡើងនៅពេលដែលមនុស្សនៅចន្លោះការងារ ឬ សម្រាប់កម្លាំងការងារថ្មី។
- ភាពគ្មានការងារធ្វើអាចមានផលវិបាកអវិជ្ជមានមួយចំនួន ដូចជាការថយចុះនៃទិន្នផលសេដ្ឋកិច្ច ភាពក្រីក្រ និងចលាចលក្នុងសង្គម។

នេះគឺជាកត្តាមួយចំនួនដែលអាចបណ្តាលឱ្យអ្នកគ្មានការងារធ្វើក្រោយបញ្ចប់ការសិក្សា៖

- **វិបត្តិសេដ្ឋកិច្ច**៖ នៅពេលដែលសេដ្ឋកិច្ចស្ថិតក្នុងវិបត្តិសេដ្ឋកិច្ច អាជីវកម្មត្រូវបញ្ឈប់បុគ្គលិក ដើម្បីកាត់បន្ថយការចំណាយ។ នេះអាចនាំឱ្យមានការកើនឡើងនៃអត្រាគ្មានការងារធ្វើ។
- **បម្រែបម្រួលបច្ចេកវិជ្ជា**៖ បច្ចេកវិជ្ជាថ្មីអាចធ្វើឱ្យការងារមួយចំនួនលែងប្រើជាហេតុនាំឱ្យគ្មានការងារធ្វើ។ ជាឧទាហរណ៍ ការដាក់ឱ្យប្រើប្រាស់ម៉ាស៊ីនគិតលុយដោយខ្លួនឯងនៅក្នុងហាងលក់គ្រឿងទេសបាននាំឱ្យបាត់បង់ការងារសម្រាប់អ្នកគិតលុយ។ បច្ចុប្បន្នការីកចំរើនបច្ចេកវិទ្យាបញ្ញាប្បនិម្មិត(AI)ក៏ជាកត្តាមួយមានឥទ្ធិពលនៃភាពគ្មានការងារធ្វើ។
- **សកលភាវូបនីយកម្ម**៖ សាកលភាវូបនីយកម្មអាចនាំឱ្យមានការបាត់បង់ការងារនៅក្នុងប្រទេសអភិវឌ្ឍន៍ នៅពេលដែលអាជីវកម្មផ្លាស់ទីប្រតិបត្តិការរបស់ពួកគេទៅកាន់ប្រទេសដែលមានតម្លៃពលកម្មទាប។
- **គោលនយោបាយរបស់រដ្ឋាភិបាល**៖ គោលនយោបាយរបស់រដ្ឋាភិបាល ដូចជាការរឹតបន្តឹងពាណិជ្ជកម្ម ក៏អាចនាំទៅរកភាពអត់ការងារធ្វើផងដែរ។

មានកិច្ចការមួយចំនួនដែលអាចធ្វើបានដើម្បីកាត់បន្ថយភាពអត់ការងារធ្វើដូចជា៖

- **គោលនយោបាយសារពើពន្ធ**៖ រដ្ឋាភិបាលអាចប្រើប្រាស់គោលនយោបាយសារពើពន្ធ ដូចជាការកាត់បន្ថយពន្ធ ឬការបង្កើនការចំណាយ ដើម្បីជំរុញសេដ្ឋកិច្ច និងបង្កើតការងារ។

- **គោលនយោបាយរូបិយវត្ថុ៖** រដ្ឋាភិបាលអាចប្រើប្រាស់គោលនយោបាយរូបិយវត្ថុ ដូចជាការផ្លាស់ប្តូរអត្រាការប្រាក់ ដើម្បីធ្វើឱ្យអាជីវកម្មមានភាពងាយស្រួលក្នុងការខ្ចីប្រាក់ និងវិនិយោគ។
- **ការអប់រំ និងបណ្តុះបណ្តាល៖** រដ្ឋាភិបាលអាចផ្តល់កម្មវិធីអប់រំ និងបណ្តុះបណ្តាល ដើម្បីជួយកម្មករអភិវឌ្ឍជំនាញដែលពួកគេត្រូវការដើម្បីទទួលបានការងារ។
- **កម្មវិធីបង្កើតការងារ៖** រដ្ឋាភិបាលអាចបង្កើតកម្មវិធីបង្កើតការងារ ដូចជាគម្រោងហេដ្ឋារចនាសម្ព័ន្ធ ដើម្បីដាក់មនុស្សឱ្យធ្វើការ។

ភាពអត់ការងារធ្វើគឺជាបញ្ហាស្មុគស្មាញដែលពុំមានដំណោះស្រាយងាយស្រួលទេ។ ទោះជាយ៉ាងណាក៏ដោយ តាមរយៈការយល់ដឹងអំពីមូលហេតុនៃភាពគ្មានការងារធ្វើ និងគោលនយោបាយដែលអាចប្រើដើម្បីដោះស្រាយវាបាន យើងអាចធ្វើការដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមានរបស់វាទៅលើសេដ្ឋកិច្ច និងសង្គមរបស់យើង។

**ក្រាភិច 11 ករណីនានាដែលមិនទាន់មានការងារធ្វើ**




ករណីនិស្សិតដែលមិនទាន់មានការងារធ្វើ នៅលើក្រាភិកបង្ហាញពីកត្តាមួយចំនួនដែលជាហេតុនៃភាពមិនទាន់មានការងារធ្វើ៖ ទី១ ពិបាករកការងារធ្វើមាន ៣០,៦% ទី២ ការងារខុសជំនាញមាន ១៤,២% ទី៣ កំពុងរៀនបន្តមាន ៨,២% ទី៤ មានគ្រួសារមាន ០,៩% ទី៥ ផ្លាស់ប្តូរទីលំនៅមាន ១,២% និងទី៦ កត្តាផ្សេងៗទៀត មានចំនួន ៤៤,៨%។

### ៣.៤.១១. រយៈពេលនៃការស្វែងរកការងារធ្វើបន្ទាប់ពីបញ្ចប់ការសិក្សា

និស្សិតក្រោយពីបញ្ចប់ការសិក្សាភ្លាមពួកគេបានស្វះស្វែងរកការងារធ្វើភ្លាមដែរ។ ទន្ទឹមគ្នានោះក៏មាននិស្សិតមួយចំនួនមានការងារធ្វើតាំងតែពីពេលកំពុងរៀន។ តទៅនេះយើងនឹងបានឃើញពីស្ថានភាពនៃពេលវេលាដែលនិស្សិតស្វែងរកការងារធ្វើ។

## ក្រាភិច 12 រយៈពេលនៃការស្វែងរកការងារធ្វើបន្ទាប់ពីបញ្ចប់ការសិក្សា




ក្រាភិកខាងលើបានបង្ហាញឱ្យឃើញថា និស្សិតភាគច្រើនមានការងារធ្វើតាំងពីកំពុងនៅរៀន ឬមានន័យថាពួកគាត់មានការងារធ្វើមុនពេលបញ្ចប់ការសិក្សាមានរហូតដល់ ៦២,៩%។ និស្សិតចំណាយពេលរកការងារធ្វើតិចជាង ១ខែមាន ៩,៥% និងនិស្សិតចំណាយពេលរកការងារធ្វើនៅចន្លោះពី ១ខែ ទៅ ៣ខែមាន ១៤,៣%។ ចំណែក ១៣,៣%ទៀត ចំណាយពេលរកការងារធ្វើលើសពី ៣ខែ បន្ទាប់ពីពួកគាត់បានបញ្ចប់ការសិក្សា។

- ចំនួននិស្សិតមានការងារធ្វើក្រោម១ខែ សរុប/ស្រី
  - %ធៀបនឹងនិស្សិតបញ្ចប់ការសិក្សាសរុប សរុប/ស្រី
    និស្សិតមានការងារធ្វើក្រោម១ខែ សរុបមានចំនួន ៣៩៥នាក់ ស្មើនឹង ៦២,២% (ស្រីចំនួន ៣០០នាក់ ស្មើនឹង ៤៧,២៤%)នៃនិស្សិតសរុប ៦៣៥នាក់
  - %ធៀបនឹងនិស្សិតចូលរួមឆ្លើយសរុប សរុប/ស្រី
    និស្សិតមានការងារធ្វើក្រោម១ខែ សរុបមានចំនួន ៣៩៥នាក់ ស្មើនឹង ៦៧,៤%(ស្រីចំនួន ៣០០នាក់ ស្មើនឹង ៥១,១៩%)នៃនិស្សិតឆ្លើយសរុប ៥៨៦នាក់
  - %ធៀបនឹងនិស្សិតចូលរួមឆ្លើយតាមសំណួរ សរុប/ស្រី
    និស្សិតមានការងារធ្វើក្រោម១ខែ សរុបមានចំនួន ៣៩៥នាក់ ស្មើនឹង ៧២,៤៧%(ស្រីចំនួន ៣០០នាក់ ស្មើនឹង ៥៥,០៤%)នៃនិស្សិតឆ្លើយតាមសំណួរសរុប ៥៤៥នាក់
  - %ធៀបនឹងនិស្សិតមានការងារធ្វើសរុប សរុប/ស្រី
    និស្សិតមានការងារធ្វើក្រោម១ខែ សរុបមានចំនួន ៣៩៥នាក់ ស្មើនឹង ៧១,១៧%(ស្រីចំនួន ៣០០នាក់ ស្មើនឹង ៥៤,០៥%)នៃនិស្សិតមានការងារធ្វើសរុប ៥៥៥នាក់
- ចំនួននិស្សិតមានការងារធ្វើចន្លោះពី១ខែដល់៣ខែ សរុប/ស្រី
  - %ធៀបនឹងនិស្សិតបញ្ចប់ការសិក្សាសរុប សរុប/ស្រី
    និស្សិតមានការងារធ្វើចន្លោះពី១ខែដល់៣ខែ សរុបមានចំនួន ៧៨នាក់ ស្មើនឹង១២,២៨% (ស្រីចំនួន ៥៨នាក់ ស្មើនឹង ៩,១៣%)នៃនិស្សិតសរុប ៦៣៥នាក់

- %ធៀបនឹងនិស្សិតចូលរួមឆ្លើយសរុប សរុប/ស្រី
  និស្សិតមានការងារធ្វើចន្លោះពី១ខែដល់៣ខែ សរុបមានចំនួន ៧៨នាក់ ស្មើនឹង១៣,៣១% (ស្រីចំនួន ៥៨ នាក់ ស្មើនឹង ៩,៨៩%)នៃនិស្សិតសរុប ៥៨៦នាក់
- %ធៀបនឹងនិស្សិតចូលរួមឆ្លើយតាមសំណួរ សរុប/ស្រី
  និស្សិតមានការងារធ្វើចន្លោះពី១ខែដល់៣ខែ សរុបមានចំនួន ៧៨នាក់ ស្មើនឹង១៤,៣១% (ស្រីចំនួន ៥៨ នាក់ ស្មើនឹង ១០,៦៤%)នៃនិស្សិតសរុប ៥៤៥នាក់
- %ធៀបនឹងនិស្សិតមានការងារធ្វើសរុប សរុប/ស្រី
  និស្សិតមានការងារធ្វើចន្លោះពី១ខែដល់៣ខែ សរុបមានចំនួន ៧៨នាក់ ស្មើនឹង១៤,០៥% (ស្រីចំនួន ៥៨ នាក់ ស្មើនឹង ១០,៤៥%)នៃនិស្សិតសរុប ៥៥៥នាក់

• ចំនួននិស្សិតមានការងារធ្វើចន្លោះពី៣ខែដល់៦ខែ សរុប/ស្រី
- %ធៀបនឹងនិស្សិតបញ្ចប់ការសិក្សាសរុប សរុប/ស្រី
  និស្សិតមានការងារធ្វើចន្លោះពី៣ខែដល់៦ខែ សរុបមានចំនួន ៣០នាក់ ស្មើនឹង៤,៧២% (ស្រីចំនួន ២១ នាក់ ស្មើនឹង ៣,៣%)នៃនិស្សិតសរុប ៦៣៥នាក់
- %ធៀបនឹងនិស្សិតចូលរួមឆ្លើយសរុប សរុប/ស្រី
  និស្សិតមានការងារធ្វើចន្លោះពី៣ខែដល់៦ខែ សរុបមានចំនួន ៣០នាក់ ស្មើនឹង៥,១១% (ស្រីចំនួន ២១នាក់ ស្មើនឹង ៣,៥៨%)នៃនិស្សិតសរុប ៥៨៦នាក់
- %ធៀបនឹងនិស្សិតចូលរួមឆ្លើយតាមសំណួរ សរុប/ស្រី
  និស្សិតមានការងារធ្វើចន្លោះពី៣ខែដល់៦ខែ សរុបមានចំនួន ៣០នាក់ ស្មើនឹង៥,៥% (ស្រីចំនួន ២១នាក់ ស្មើនឹង ៣,៨៥%)នៃនិស្សិតសរុប ៥៤៥នាក់
- %ធៀបនឹងនិស្សិតមានការងារធ្វើសរុប សរុប/ស្រី
  និស្សិតមានការងារធ្វើចន្លោះពី៣ខែដល់៦ខែ សរុបមានចំនួន ៣០នាក់ ស្មើនឹង៥,៤% (ស្រីចំនួន ២១នាក់ ស្មើនឹង ៣,៧៨%)នៃនិស្សិតសរុប ៥៥៥នាក់

• ចំនួននិស្សិតមានការងារធ្វើចាប់ពី៦ខែចុះក្រោម
- %ធៀបនឹងនិស្សិតបញ្ចប់ការសិក្សាសរុប សរុប/ស្រី
  និស្សិតមានការងារធ្វើពី៦ខែចុះក្រោម សរុបមានចំនួន ៥០៣នាក់ ស្មើនឹង៧៩,២១% (ស្រីចំនួន ៣៧៩នាក់ ស្មើនឹង ៥៩,៦៨%)នៃនិស្សិតសរុប ៦៣៥នាក់
- %ធៀបនឹងនិស្សិតចូលរួមឆ្លើយសរុប សរុប/ស្រី
  និស្សិតមានការងារធ្វើពី៦ខែចុះក្រោម សរុបមានចំនួន ៥០៣នាក់ ស្មើនឹង៨៥,៨៣% (ស្រីចំនួន ៣៧៩នាក់ ស្មើនឹង ៦៤,៦៧%)នៃនិស្សិតសរុប ៥៨៦នាក់
- %ធៀបនឹងនិស្សិតចូលរួមឆ្លើយតាមសំណួរ សរុប/ស្រី
  និស្សិតមានការងារធ្វើពី៦ខែចុះក្រោម សរុបមានចំនួន ៥០៣នាក់ ស្មើនឹង៩២,២៩% (ស្រីចំនួន ៣៧៩នាក់ ស្មើនឹង ៦៩,៥៤%)នៃនិស្សិតសរុប ៥៤៥នាក់
- %ធៀបនឹងនិស្សិតមានការងារធ្វើសរុប សរុប/ស្រី

និស្សិតមានការងារធ្វើពី៦ខែចុះក្រោម សរុបមានចំនួន ៥០៣នាក់ ស្មើនឹង៩០,៦៣% (ស្រីចំនួន ៣៧៩នាក់ ស្មើនឹង ៦៨,២៨%)នៃនិស្សិតសរុប ៥៥៥នាក់

- ចំនួននិស្សិតមានការងារធ្វើលើសពី៦ខែ សរុប/ស្រី

- %ធៀបនឹងនិស្សិតបញ្ចប់ការសិក្សាសរុប សរុប/ស្រី

និស្សិតមានការងារធ្វើលើសពី៦ខែ សរុបមានចំនួន ៤២នាក់ ស្មើនឹង៦,៦១% (ស្រីចំនួន ២៨នាក់ ស្មើនឹង ៤,៤%)នៃនិស្សិតសរុប ៦៣៥នាក់

- %ធៀបនឹងនិស្សិតចូលរួមឆ្លើយសរុប សរុប/ស្រី

និស្សិតមានការងារធ្វើលើសពី៦ខែ សរុបមានចំនួន ៤២នាក់ ស្មើនឹង៧,១៦% (ស្រីចំនួន ២៨នាក់ ស្មើនឹង ៤,៧៧%)នៃនិស្សិតសរុប ៥៨៦នាក់

- %ធៀបនឹងនិស្សិតចូលរួមឆ្លើយតាមសំណួរ សរុប/ស្រី

និស្សិតមានការងារធ្វើលើសពី៦ខែ សរុបមានចំនួន ៤២នាក់ ស្មើនឹង៧,៧% (ស្រីចំនួន ២៨នាក់ ស្មើនឹង ៥,១៣%)នៃនិស្សិតសរុប ៥៤៥នាក់

- %ធៀបនឹងនិស្សិតមានការងារធ្វើសរុប សរុប/ស្រី

និស្សិតមានការងារធ្វើលើសពី៦ខែ សរុបមានចំនួន ៤២នាក់ ស្មើនឹង៧,៥៦% (ស្រីចំនួន២៨នាក់ ស្មើនឹង ៥,០៤%)នៃនិស្សិតសរុប ៥៥៥នាក់

**តារាង 21 តេស្តលទ្ធផល**

| Label | N | Mean | SD | t | Sig. | Lower | Upper |
|---|---|---|---|---|---|---|---|
| ការចំណាយពេលរកការងារធ្វើ | 545 | 1.94 | 1.519 | 29.756 | 0.000*** | 1.81 | 2.06 |

*: p<0.10, **: p<0.05, ***: p<0.01

រយៈពេលនៃការរកការងារធ្វើ និស្សិតប្រមាណជាង ៧២,៤% អាចនឹងទទួលបានការងារធ្វើដោយចំណាយពេលតិចជាង១ខែ នេះបើយោងតាមវិធីវាយតម្លៃ One Sample T-Test ក្នុងកម្រិតជឿជាក់ ៩៥%។

### ៣.៤.១២. ការចំណាយពេលដើម្បីទទួលបានការងារស្របជំនាញ

ការងារស្របជំនាញគឺជាការងារដែលត្រូវធ្វើតាមចំណេះ ជំនាញក្នុងកិច្ចការជាក់ស្តែងស្របតាមទ្រឹស្តីដែលបានសិក្សានៅតាមគ្រឹះស្ថានសិក្សា។ និស្សិតបញ្ចប់ការសិក្សាបានយកទ្រឹស្តីដែលបានសិក្សាពីសាលាទៅប្រើប្រាស់ និងអនុវត្តបានយ៉ាងប៉ិនប្រសប់នៅតាមបណ្តាអង្គភាពរដ្ឋ ឬសហគ្រាសអាជីវកម្មនានាក្នុងវិស័យឯកជន។

**តារាង 22 រយៈពេលទទួលបានការងារធ្វើស្របជំនាញ**

| រយៈពេលស្វែងរកការងារ | | មានការងារធ្វើ | | សរុប |
|---|---|---|---|---|
| | | ស្របជំនាញ | មិនស្របជំនាញ | |
| មានការងារមុនពេលបញ្ចប់ការសិក្សា | ចំនួន | 202 | 138 | 340 |
| | % | 59.4% | 40.6% | 100.0% |
| ក្រោមមួយខែ | ចំនួន | 30 | 21 | 51 |

| | | | | |
|---|---|---|---|---|
| | % | 58.8% | 41.2% | 100.0% |
| ចន្លោះ ១ខែ ទៅ ៣ខែ | ចំនួន | 40 | 35 | 75 |
| | % | 53.3% | 46.7% | 100.0% |
| ចន្លោះ ៣ខែ ទៅ ៦ខែ | ចំនួន | 21 | 8 | 29 |
| | % | 72.4% | 27.6% | 100.0% |
| ចន្លោះ ៦ខែ ទៅ ៩ខែ | ចំនួន | 3 | 9 | 12 |
| | % | 25.0% | 75.0% | 100.0% |
| ចន្លោះ ៩ខែ ទៅ ១២ខែ | ចំនួន | 4 | 10 | 14 |
| | % | 28.6% | 71.4% | 100.0% |
| លើស ១២ខែ | ចំនួន | 4 | 8 | 12 |
| | % | 33.3% | 66.7% | 100.0% |
| សរុប | ចំនួន | 304 | 229 | 533 |
| | % | 57.0% | 43.0% | 100.0% |

តាមតារាងខាងលើបានបង្ហាញថា និស្សិតមានការងារធ្វើ ៥៣៣នាក់ ក្នុងនោះមាន ៣០៤នាក់ ស្មើនឹង ៥៧,0% ធ្វើការស្របជំនាញ ២២៩នាក់ ស្មើនឹង ៤៣,0% ធ្វើការមិនស្របជំនាញ។ រយៈពេលនៃការស្វែងរកការងារស្របជំនាញ មាននិស្សិតចំនួន២៩៣នាក់ ស្មើនឹង ៥៤,៩៧% រកបានការងារធ្វើស្របជំនាញក្រោម៦ខែ និងករណីមានចំនួន១១នាក់ ស្មើនឹង២,០៦% រកការងារធ្វើស្របជំនាញលើសពី៦ខែ។

### ៣.៤.១៣. ការបង្កើតសហគ្រាសផ្ទាល់ខ្លួន

#### ៣.៤.១៣.១ .ការចំណាយពេលដើម្បីបង្កើតសហគ្រាសផ្ទាល់ខ្លួន

ការបង្កើតសហគ្រាមួយទាមទារនូវការគិតពិចារណាបានល្អិតល្អន់មានដូចជា យុទ្ធសាស្ត្រអាជីវកម្ម ការគ្រប់គ្រងសហគ្រាស ការគ្រប់គ្រងហិរញ្ញវត្ថុ និងសកម្មភាពអាជីវកម្មផ្សេងទៀតដែលមានជាប់ពាក់ព័ន្ធគ្នា។ ករណីមានអាជីវកម្មផ្ទាល់ខ្លួននេះអាចជាអាជីវកម្មរបស់គ្រួសារ ឬអាចជាអាជីវកម្មផ្ទាល់ខ្លួនដែលនិស្សិតបញ្ចប់ការសិក្សាបានបង្កើតវាបានដោយខ្លួនឯង។ បន្ថែមលើនេះយើងនឹងពិនិត្យលើរយៈពេលសម្រាប់បង្កើតសហគ្រាសអាជីវកម្មផ្ទាល់ខ្លួនរបស់និស្សិតបញ្ចប់ការសិក្សា។ តាមទិន្នន័យស្ទង់មតិបង្ហាញថា ក្នុងចំនួនបង្កើតអាជីវកម្ម ៣៤៨ករណីមាន ៩៥ករណីជាអាជីវកម្មខាតតូច ស្មើនឹង ២៧,៣% អាជីវកម្មខ្នាតមធ្យម មាន៥៤ករណី ស្មើនឹង ១៥,៥% និង ៦ករណីជាអាជីវកម្មខ្នាតធំ ស្មើនឹង ១,៧%។ ក្រៅពីនេះជាអាជីវកម្មផ្សេងៗមានចំនួន ៥៥,៥%។

ទិន្នន័យខាងក្រោមនេះលម្អិតតែក្នុងករណីនិស្សិតបញ្ចប់ការសិក្សា និងចំណាយពេលដើម្បីបង្កើតសហគ្រាសដោយផ្ទាល់ខ្លួន៖

- ចំនួននិស្សិតមានអាជីវកម្ម/សហគ្រាសផ្ទាល់ខ្លួនក្រោម១ខែ សរុប/ស្រី
  - %ធៀបនឹងនិស្សិតបញ្ចប់ការសិក្សាសរុប សរុប /ស្រី

ចំនួននិស្សិតមានអាជីវកម្ម/សហគ្រាសផ្ទាល់ខ្លួនក្រោម១ខែ សរុប ៧នាក់ ស្មើនឹង ១,១% (ស្រីចំនួន ៥នាក់ ស្មើនឹង ០,៧៨%)នៃនិស្សិតសរុប ៦៣៥នាក់

- %ធៀបនឹងនិស្សិតចូលរួមឆ្លើយសរុប សរុប/ស្រី
  ចំនួននិស្សិតមានអាជីវកម្ម/សហគ្រាសផ្ទាល់ខ្លួនក្រោម១ខែ សរុប ៧នាក់ ស្មើនឹង ១,១៩% (ស្រីចំនួន ៥ នាក់ ស្មើនឹង ០,៨៥%)នៃនិស្សិតសរុប ៥៨៦នាក់
- %ធៀបនឹងនិស្សិតចូលរួមឆ្លើយតាមសំណួរ សរុប/ស្រី
  ចំនួននិស្សិតមានអាជីវកម្ម/សហគ្រាសផ្ទាល់ខ្លួនក្រោម១ខែ សរុប ៧នាក់ ស្មើនឹង ៥៨,៣៣% (ស្រីចំនួន ៥ នាក់ ស្មើនឹង ៤១,៦៦%)នៃនិស្សិតសរុប ១២នាក់
- %ធៀបនឹងនិស្សិតមានការងារធ្វើសរុប សរុប/ស្រី
  ចំនួននិស្សិតមានអាជីវកម្ម/សហគ្រាសផ្ទាល់ខ្លួនក្រោម១ខែ សរុប ៧នាក់ ស្មើនឹង ១,២៦% (ស្រីចំនួន ៥ នាក់ ស្មើនឹង ០,៩%)នៃនិស្សិតសរុប ៥៥៥នាក់

• ចំនួននិស្សិតមានអាជីវកម្ម/សហគ្រាសផ្ទាល់ខ្លួនចន្លោះពី១ខែដល់៣ខែ សរុប/ស្រី
- %ធៀបនឹងនិស្សិតបញ្ចប់ការសិក្សាសរុប សរុប/ស្រី
  ចំនួននិស្សិតមានអាជីវកម្ម/សហគ្រាសផ្ទាល់ខ្លួនចន្លោះពី១ខែដល់៣ខែ សរុប ២នាក់ ស្មើនឹង ០,៣% (ស្រីចំនួន ១នាក់ ស្មើនឹង ០,១៥%)នៃនិស្សិតសរុប ៦៣៥នាក់
- %ធៀបនឹងនិស្សិតចូលរួមឆ្លើយសរុប សរុប/ស្រី
  ចំនួននិស្សិតមានអាជីវកម្ម/សហគ្រាសផ្ទាល់ខ្លួនចន្លោះពី១ខែដល់៣ខែ សរុប ២នាក់ ស្មើនឹង ០,៣៤% (ស្រីចំនួន ១នាក់ ស្មើនឹង ០,១៧%)នៃនិស្សិតសរុប ៥៨៦នាក់
- %ធៀបនឹងនិស្សិតចូលរួមឆ្លើយតាមសំណួរ សរុប/ស្រី
  ចំនួននិស្សិតមានអាជីវកម្ម/សហគ្រាសផ្ទាល់ខ្លួនចន្លោះពី១ខែដល់៣ខែ សរុប ២នាក់ ស្មើនឹង ១៦,៦៦% (ស្រីចំនួន ១នាក់ ស្មើនឹង ៨,៣៣%)នៃនិស្សិតសរុប ១២នាក់
- %ធៀបនឹងនិស្សិតមានការងារធ្វើសរុប សរុប/ស្រី
  ចំនួននិស្សិតមានអាជីវកម្ម/សហគ្រាសផ្ទាល់ខ្លួនចន្លោះពី១ខែដល់៣ខែ សរុប ២នាក់ ស្មើនឹង ០,៣៦% (ស្រីចំនួន ១នាក់ ស្មើនឹង ០,១៨%)នៃនិស្សិតសរុប ៥៥៥នាក់

• ចំនួននិស្សិតមានអាជីវកម្ម/សហគ្រាសផ្ទាល់ខ្លួនចន្លោះពី៣ខែដល់៦ខែ សរុប/ស្រី
- ចន្លោះពី៣ខែដល់៦ខែ ពុំមានទិន្នន័យនៅក្នុងការស្ទង់មតិទេ។

• ចំនួននិស្សិតមានអាជីវកម្ម/សហគ្រាសផ្ទាល់ខ្លួន ចាប់ពី៦ខែចុះក្រោម សរុប/ស្រី
- %ធៀបនឹងនិស្សិតបញ្ចប់ការសិក្សាសរុប សរុប/ស្រី
  ចំនួននិស្សិតមានអាជីវកម្ម/សហគ្រាសផ្ទាល់ខ្លួន ចាប់ពី៦ខែចុះក្រោម សរុប ៩នាក់ ស្មើនឹង ១,៤១% (ស្រីចំនួន ៦នាក់ ស្មើនឹង ០,៩៤%)នៃនិស្សិតសរុប ៦៣៥នាក់
- %ធៀបនឹងនិស្សិតចូលរួមឆ្លើយសរុប សរុប/ស្រី
  ចំនួននិស្សិតមានអាជីវកម្ម/សហគ្រាសផ្ទាល់ខ្លួន ចាប់ពី៦ខែចុះក្រោម សរុប ៩នាក់ ស្មើនឹង ១,៥៣% (ស្រីចំនួន ៦នាក់ ស្មើនឹង ១,០២%)នៃនិស្សិតសរុប ៥៨៦នាក់

- %ធៀបនឹងនិស្សិតចូលរួមឆ្លើយតាមសំណួរ សរុប/ស្រី
  ចំនួននិស្សិតមានអាជីវកម្ម/សហគ្រាសផ្ទាល់ខ្លួន ចាប់ពី៦ខែចុះក្រោម សរុប ៩នាក់ ស្មើនឹង ៧៥,០% (ស្រីចំនួន ៦នាក់ ស្មើនឹង ៥០,០%)នៃនិស្សិតសរុប ១២នាក់
- %ធៀបនឹងនិស្សិតមានការងារធ្វើសរុប សរុប/ស្រី
  ចំនួននិស្សិតមានអាជីវកម្ម/សហគ្រាសផ្ទាល់ខ្លួន ចាប់ពី៦ខែចុះក្រោម សរុប ៩នាក់ ស្មើនឹង ១,៦២% (ស្រីចំនួន ៦នាក់ ស្មើនឹង ១,០៨%)នៃនិស្សិតសរុប ៥៥៥នាក់

• ចំនួននិស្សិតមានអាជីវកម្ម/សហគ្រាសផ្ទាល់ខ្លួន លើសពី៦ខែ សរុប/ស្រី
- %ធៀបនឹងនិស្សិតបញ្ចប់ការសិក្សាសរុប សរុប/ស្រី
  ចំនួននិស្សិតមានអាជីវកម្ម/សហគ្រាសផ្ទាល់ខ្លួន លើសពី៦ខែ សរុប ៣នាក់ ស្មើនឹង ០,៤៧% (ស្រីចំនួន ១នាក់ ស្មើនឹង ០,១៥%)នៃនិស្សិតសរុប ៦៣៥នាក់
- %ធៀបនឹងនិស្សិតចូលរួមឆ្លើយសរុប សរុប/ស្រី
  ចំនួននិស្សិតមានអាជីវកម្ម/សហគ្រាសផ្ទាល់ខ្លួន លើសពី៦ខែ សរុប ៣នាក់ ស្មើនឹង ០,៥១% (ស្រីចំនួន ១នាក់ ស្មើនឹង ០,១៧%)នៃនិស្សិតសរុប ៥៨៦នាក់
- %ធៀបនឹងនិស្សិតចូលរួមឆ្លើយតាមសំណួរ សរុប/ស្រី
  ចំនួននិស្សិតមានអាជីវកម្ម/សហគ្រាសផ្ទាល់ខ្លួន លើសពី៦ខែ សរុប ៣នាក់ ស្មើនឹង ២៥,០% (ស្រីចំនួន ១នាក់ ស្មើនឹង ៨,៣៣%)នៃនិស្សិតសរុប ១២នាក់
- %ធៀបនឹងនិស្សិតមានការងារធ្វើសរុប សរុប/ស្រី
  ចំនួននិស្សិតមានអាជីវកម្ម/សហគ្រាសផ្ទាល់ខ្លួន លើសពី៦ខែ សរុប ៣នាក់ ស្មើនឹង ០,៥៤% (ស្រីចំនួន ១នាក់ ស្មើនឹង ០,១៨%)នៃនិស្សិតសរុប ៥៥៥នាក់

## ក្រាភិច 13 ការចំណាយពេលបង្កើតសហគ្រាសអាជីវកម្មស្របជំនាញផ្ទាល់ខ្លួន



តាមក្រាភិកបង្ហាញថា ក្រោយបញ្ចប់សិក្សាតិចជាង១ខែ មាននិស្សិតចំនួន ៧នាក់ ស្មើនឹង ៥២,៣% បានបង្កើតអាជីវកម្មផ្ទាល់ខ្លួន ហើយចំនួន ២នាក់ ស្មើនឹង ១៦,៧% បានបង្កើតអាជីវកម្មផ្ទាល់ខ្លួននៅចន្លោះ ១ទៅ៣ខែ ខណៈ ២៤,៩%ផ្សេងទៀតបានបង្កើតអាជីវកម្មផ្ទាល់ខ្លួនចាប់ពី៦ខែឡើងទៅ។

### ៣.៤ .២.១៣.ការបង្កើតសហគ្រាសអាជីវកម្មផ្ទាល់ខ្លួនស្របជំនាញ

ការបង្កើតសហគ្រាសអាជីវកម្មខ្លះមិនទាមទារ ឬតម្រូវការជំនាញជាក់លាក់ទេ គឺធ្វើយ៉ាងណាឱ្យអាជីវកម្មនោះមានដំណើរការបានល្អប្រសើរគឺគេអាចចាត់ទុកថាជាអាជីវកម្មមួយទទួលបានជោគជ័យ។ ប៉ុន្តែបើទោះបីជាមានករណីបែបនេះក្តី ក៏នៅមានករណីពិសេសជាច្រើនទៀតដែលបានកំណត់ពីការរៀបចំបើកដំណើរការអាជីវកម្មមួយឱ្យស្របតាមជំនាញដែលបានសិក្សាពីសាកលវិទ្យាល័យក្នុងគោលបំណងធានាភាពរឹងមាំ និងស្ថេរភាពនៃអាជីវកម្មយូរអង្វែង។ ក្នុងចំណោមអាជីវកម្មផ្ទាល់ខ្លួនសរុប ១២ករណី ក្នុងនោះមាន ៥ករណី ដំណើរការស្របជំនាញដែលបានសិក្សា និង ៧ករណី ដំណើរការជីវកម្មមិនស្របជំនាញ។ ខាងក្រោមនេះបង្ហាញករណីនៃការបង្កើតអាជីវកម្មស្របជំនាញ។

- ចំនួននិស្សិតមានអាជីវកម្ម/សហគ្រាសផ្ទាល់ខ្លួនត្រូវនឹងជំនាញ សរុប/ស្រី
  - %ធៀបនឹងនិស្សិតបញ្ចប់ការសិក្សាសរុប សរុប/ស្រី
    ចំនួននិស្សិតមានអាជីវកម្ម/សហគ្រាសផ្ទាល់ខ្លួនត្រូវនឹងជំនាញ សរុប ៥នាក់ ស្មើនឹង ០,៧៨% (ស្រីចំនួន ២នាក់ ស្មើនឹង ០,៣១%)នៃនិស្សិតសរុប ៦៣៥នាក់
  - %ធៀបនឹងនិស្សិតចូលរួមឆ្លើយសរុប សរុប/ស្រី
    ចំនួននិស្សិតមានអាជីវកម្ម/សហគ្រាសផ្ទាល់ខ្លួនត្រូវនឹងជំនាញ សរុប ៥នាក់ ស្មើនឹង ០,៨៥% (ស្រីចំនួន ២នាក់ ស្មើនឹង ០,៣៤%)នៃនិស្សិតសរុប ៥៨៦នាក់
  - %ធៀបនឹងនិស្សិតចូលរួមឆ្លើយតាមសំណួរ សរុប/ស្រី
    ចំនួននិស្សិតមានអាជីវកម្ម/សហគ្រាសផ្ទាល់ខ្លួនត្រូវនឹងជំនាញ សរុប ៥នាក់ ស្មើនឹង ៤១,៦៦% (ស្រីចំនួន ២នាក់ ស្មើនឹង ១៦,៦៦%)នៃនិស្សិតសរុប ១២នាក់
  - %ធៀបនឹងនិស្សិតមានការងារធ្វើសរុប សរុប/ស្រី
    ចំនួននិស្សិតមានអាជីវកម្ម/សហគ្រាសផ្ទាល់ខ្លួនត្រូវនឹងជំនាញ សរុប ៥នាក់ ស្មើនឹង ០,៩% (ស្រីចំនួន ២នាក់ ស្មើនឹង ០,៣៦%)នៃនិស្សិតសរុប ៥៥៥នាក់

## ៣.៥. ព័ត៌មានពីតម្រូវការមុខជំនាញ

ជំនាញទន់គឺជាលក្ខណៈផ្ទាល់ខ្លួនដែលអាចឱ្យនរណាម្នាក់ធ្វើអន្តរកម្មប្រកបដោយប្រសិទ្ធភាព និងចុះសម្រុងជាមួយមនុស្សផ្សេងទៀត។ ជំនាញទាំងនេះអាចរួមបញ្ចូលគុណធម៌សង្គម សមត្ថភាពទំនាក់ទំនង ជំនាញភាសា ទម្លាប់ផ្ទាល់ខ្លួន ការយល់ដឹង ឬអារម្មណ៍យល់ចិត្ត ការគ្រប់គ្រងពេលវេលា ការងារជាក្រុម និងលក្ខណៈនៃភាពជាអ្នកដឹកនាំ។ ជំនាញទន់ច្រើនតែផ្ទុយនឹងជំនាញរឹងដែលជាជំនាញបច្ចេកទេស ជាក់លាក់សម្រាប់ការងារ ឬឧស្សាហកម្មជាក់លាក់មួយ។ ជំនាញរឹងអាចរៀនបានតាមរយៈការអប់រំផ្លូវការ ឬការបណ្តុះបណ្តាល ប៉ុន្តែជំនាញទន់គឺពិបាកជាងក្នុងការទទួលបាន ហើយជារឿយៗត្រូវបានអភិវឌ្ឍតាមរយៈបទពិសោធន៍។ ជំនាញទន់មានសារៈសំខាន់សម្រាប់ភាពជោគជ័យក្នុងគ្រប់វិស័យនៃជីវិត រួមទាំងការងារ សាលារៀន និងទំនាក់ទំនងផ្ទាល់ខ្លួន។ មនុស្ស

ដែលមានជំនាញទន់ខ្លាំងអាចទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព បង្កើតទំនាក់ទំនង ធ្វើការបានល្អជាមួយអ្នកដទៃ និងដោះស្រាយជម្លោះ។ ពួកគេក៏អាចសម្របខ្លួនទៅនឹងការផ្លាស់ប្តូរ និងគ្រប់គ្រងពេលវេលារបស់ពួកគេប្រកបដោយប្រសិទ្ធភាពផងដែរ។ ឧទាហរណ៍នៃជំនាញទន់៖ ជំនាញទំនាក់ទំនង ជំនាញការងារជាក្រុម ជំនាញភាពជាអ្នកដឹកនាំ ជំនាញដោះស្រាយបញ្ហា ជំនាញគិតត្រិះរិះពិចារណា ភាពច្នៃប្រឌិត ការយល់ចិត្ត ការយល់ដឹងអំពីខ្លួនឯង អាចសម្របបាន ក្រមសីលធម៌ការងារ ជំនាញគ្រប់គ្រងពេលវេលា ជំនាញដោះស្រាយជម្លោះ។

**សារៈសំខាន់នៃជំនាញទន់៖** ជំនាញទន់មានសារៈសំខាន់សម្រាប់ភាពជោគជ័យក្នុងគ្រប់វិស័យនៃជីវិត រួមទាំងការងារ សាលារៀន និងទំនាក់ទំនងផ្ទាល់ខ្លួន។ មនុស្សដែលមានជំនាញទន់ខ្លាំងអាចធ្វើទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព បង្កើតទំនាក់ទំនង ធ្វើការបានល្អជាមួយអ្នកដទៃ និងដោះស្រាយជម្លោះ។ ពួកគេក៏អាចសម្របខ្លួនទៅនឹងការផ្លាស់ប្តូរ និងគ្រប់គ្រងពេលវេលារបស់ពួកគេប្រកបដោយប្រសិទ្ធភាពផងដែរ។ នៅកន្លែងធ្វើការ ជំនាញទន់កាន់តែមានសារៈសំខាន់ ដោយសារការងារកាន់តែស្មុគស្មាញ និងទាមទារឱ្យមានកិច្ចសហការកាន់តែច្រើន។ និយោជកកំពុងស្វែងរកបេក្ខជនដែលមានជំនាញទន់ ដែលអាចធ្វើការប្រកបដោយប្រសិទ្ធភាពជាផ្នែកមួយនៃក្រុម និងដោះស្រាយបញ្ហាប្រកបដោយភាពច្នៃប្រឌិត។

**វិធីបង្កើនជំនាញទន់៖** មានរឿងជាច្រើនដែលអ្នកអាចធ្វើដើម្បីបង្កើនជំនាញទន់។ នេះគឺជាគន្លឹះមួយចំនួន៖

- ត្រូវដឹងពីចំណុចខ្លាំង និងចំណុចខ្សោយរបស់អ្នកនៅពេលដែលអ្នកដឹងពីកន្លែងដែលអ្នកស្ថិតនៅ នោះអ្នកអាចចាប់ផ្តើមបង្កើតផែនការដើម្បីបង្កើនជំនាញរបស់អ្នក។
- កំណត់គោលដៅសម្រាប់ខ្លួនអ្នក តើជំនាញទន់ជាក់លាក់មួយណាដែលអ្នកចង់កែលម្អ? នៅពេលដែលអ្នកដឹងពីគោលដៅរបស់អ្នក អ្នកអាចចាប់ផ្តើមបង្កើតផែនការដើម្បីសម្រេចវាបាន។
- ស្វែងរកមតិកែលម្អពីអ្នកដទៃ សួរមិត្តភក្តិ ក្រុមគ្រួសារ មិត្តរួមការងារ ឬអ្នកគ្រប់គ្រងរបស់អ្នកសម្រាប់មតិកែលម្អលើជំនាញទន់របស់អ្នក។ វាអាចជួយអ្នកក្នុងការកំណត់អត្តសញ្ញាណតំបន់ដែលអ្នកត្រូវការកែលម្អ។
- ស្វែងរកឱកាសដើម្បីអនុវត្តជំនាញទន់របស់អ្នក អ្នកហាត់កាន់តែច្រើន អ្នកនឹងក្លាយជាអ្នកជំនាញទាំងនេះកាន់តែប្រសើរ។
- ធនធានជាច្រើនដែលអាចរកបានដើម្បីជួយអ្នកបង្កើនជំនាញទន់ គឺអ្នកអាចស្វែងរកសៀវភៅ អត្ថបទ និងវគ្គសិក្សាតាមអ៊ីនធឺណិតលើប្រធានបទជំនាញទន់ផ្សេងៗ។

តាមរយៈការវិនិយោគលើជំនាញទន់ អ្នកអាចបង្កើនឱកាសជោគជ័យក្នុងគ្រប់វិស័យនៃជីវិតរបស់អ្នក។ ប្រសិទ្ធភាពការងារគឺជាការបំពេញការងារបានតាមផែនការកំណត់ទាំងបរិមាណ និងគុណភាព។ សមិទ្ធិផលទាំងនោះកើតចេញពីការងារស្របជំនាញដែលទទួលបានចំណេះ ជំនាញពីការបណ្តុះបណ្តាលនៅគ្រឹះស្ថានអប់រំ។ ផលិតភាពនៃការងារស្របជំនាញតែងតែមានគុណតម្លៃខ្ពស់ ទាំងតម្លៃ បរិមាណ និងគុណភាព។

ជាបន្តយើងនឹងសិក្សាពិនិត្យមើលការវាយតម្លៃការងារតាមរយៈជំនាញដែលបានសិក្សាកន្លងមក។

### ៣.៥.១. តម្រូវការបំណិនជំនាញសម្រាប់ការងារដែលកំពុងធ្វើបច្ចុប្បន្ន

តារាង 23 តម្រូវការបំណិនជំនាញសម្រាប់ការងារ

| លរ | បំណិនជំនាញមានសារៈសំខាន់ | ចាំបាច់តិចតួច | ចាំបាច់មធ្យម | ចាំបាច់បង្គួរ | ចាំបាច់ខ្លាំង | ចាំបាច់ខ្លាំងណាស់ |
|---|---|---|---|---|---|---|
| ១ | សមត្ថភាពបង្កើតគំនិតនិងដំណោះស្រាយថ្មីៗ | 2.7% | 31.1% | 34.5% | 27.5% | 4.3% |
| ២ | សមត្ថភាពសម្របខ្លួនតាមការផ្លាស់ប្តូរ | 2.2% | 35.3% | 35.5% | 23.7% | 3.2% |
| ៣ | ការគិតត្រិះរិះពិចារណា | 2.7% | 26.6% | 36.9% | 29.4% | 4.4% |
| ៤ | សមត្ថភាពធ្វើការដើម្បីឆ្ពោះទៅរកគោលដៅ | 2.7% | 24.6% | 35.0% | 31.9% | 5.8% |
| ៥ | សមត្ថភាពធ្វើការងារជាក្រុម | 1.7% | 25.8% | 31.9% | 34.1% | 6.5% |
| ៦ | សមត្ថភាពបង្កើតទំនាក់ទំនងអន្តរបុគ្គល | 3.1% | 25.8% | 36.0% | 29.5% | 5.6% |
| ៧ | ចំណេះដឹងផ្នែកបច្ចេកវិទ្យាព័ត៌មាន | 6.1% | 34.5% | 32.4% | 23.0% | 3.9% |
| ៨ | ភាពជាអ្នកដឹកនាំ | 3.9% | 32.9% | 33.1% | 25.8% | 4.3% |

តារាងខាងលើបានបង្ហាញថា តម្រូវការបំណិនជំនាញលើជំនាញទន់ ដែលមានសារៈសំខាន់សម្រាប់ការងារដែលកំពុងធ្វើបច្ចុប្បន្ន ទី១ សមត្ថភាពបង្កើតគំនិតនិងដំណោះស្រាយថ្មីៗ កម្រិតចាំបាច់ខ្លាំងណាស់មាន ៤,៣% ទី២ សមត្ថភាពសម្របខ្លួនតាមការផ្លាស់ប្តូរ កម្រិតចាំបាច់ខ្លាំងណាស់មាន ៣,២% ទី៣ ការគិតត្រិះរិះពិចារណា កម្រិតចាំបាច់ខ្លាំងណាស់មាន៤,៤% ទី៤ សមត្ថភាពធ្វើការដើម្បីឆ្ពោះទៅរកគោលដៅ កម្រិតចាំបាច់ខ្លាំងណាស់មាន ៥,៨% ទី៥ សមត្ថភាពធ្វើការងារជាក្រុម កម្រិតចាំបាច់ខ្លាំងណាស់មាន ៦,៥% ទី៦ សមត្ថភាពបង្កើតទំនាក់ទំនងអន្តរបុគ្គល កម្រិតចាំបាច់ខ្លាំងណាស់មាន ៥,៦% ទី៧ ចំណេះដឹងផ្នែកបច្ចេកវិទ្យាព័ត៌មាន កម្រិតចាំបាច់ខ្លាំងណាស់មាន ៣,៩% និងទី៨ ភាពជាអ្នកដឹកនាំ កម្រិតចាំបាច់ខ្លាំងណាស់មាន ៤,៣%។ ជាសន្និដ្ឋាន ការផ្តល់គុណតម្លៃលើជំនាញទន់ថាមានសារៈសំខាន់ ចាំបាច់ខ្លាំង នេះគឺជាព័ត៌មានត្រឡប់របស់និស្សិតតាមរយៈស្ទង់មតិ។

មុខវិជ្ជាសំខាន់របស់និស្សិតម្នាក់ៗអាចទាក់ទងគ្នាយ៉ាងសំខាន់ជាមួយបំណិន និងសក្តានុពលបង្កើនប្រាក់ចំណូលរបស់ពួកគេ ដោយសារវិស័យសិក្សាផ្សេងៗគ្នា ជារឿយៗនាំទៅរកអាជីពដែលមានប្រាក់ឈ្នួលមធ្យមខុសៗគ្នា។ នេះគឺជាចំណុចសំខាន់ៗដែលត្រូវពិចារណា និងមានការពាក់ព័ន្ធជាមួយបំណិន៖

### 1. តម្រូវការជំនាញ

- មុខជំនាញក្នុងវិស័យ STEM (វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម គណិតវិទ្យា) មានទំនោរទៅរកប្រាក់ចំណូលខ្ពស់ដោយសារតម្រូវការខ្លាំងសម្រាប់ជំនាញបច្ចេកទេស។ ឧទាហរណ៍ វិទ្យាសាស្ត្រកុំព្យូទ័រ វិស្វកម្ម និងជំនាញវិភាគទិន្នន័យ ច្រើនតែឃើញប្រាក់ខែចាប់ផ្តើមខ្ពស់ជាង។

### 2. កម្រិតឯកទេស

- មុខជំនាញដែលអភិវឌ្ឍជំនាញឯកទេសខ្ពស់ ដូចជាផ្នែកហិរញ្ញវត្ថុ ឬផ្នែកដែលទាក់ទងនឹងការថែទាំសុខភាព ជារឿយៗតម្រឹមជាមួយទីផ្សារការងារដែលរកកម្រៃបានល្អ។
- ផ្ទុយទៅវិញ មុខជំនាញដែលផ្តោតលើជំនាញទូទៅ អាចត្រូវការជំនាញបន្ថែម ( ឧ. សញ្ញាបត្រកម្រិតខ្ពស់ ) សម្រាប់ប្រាក់ចំណូលខ្ពស់។

**3. ជំនាញដែលអាចផ្ទេរបាន**

- ខណៈពេលដែលមុខជំនាញមួយចំនួនប្រហែលជាមិនទាក់ទងដោយផ្ទាល់ទៅនឹងប្រាក់ឈ្នួលខ្ពស់ ជំនាញទន់ដែលពួកគេបណ្តុះ ដូចជាការទំនាក់ទំនង ការដោះស្រាយបញ្ហា និងការសម្របខ្លួនអាចនាំទៅរកភាពជោគជ័យក្នុងតួនាទីដែលមានប្រាក់ខែខ្ពស់តាមពេលវេលា។

**4. កំណើនរយៈពេលវែង**

- មុខជំនាញមួយចំនួននាំទៅរកការងារដែលមានប្រាក់ឈ្នួលចាប់ផ្តើមទាប ប៉ុន្តែផ្តល់សក្តានុពលកំណើនគួរឱ្យកត់សម្គាល់។ ជាឧទាហរណ៍ ការងារសង្គមអាចចាប់ផ្តើមទាប ប៉ុន្តែកើនឡើងប្រសិនបើគូជាមួយថ្នាក់អនុបណ្ឌិត ឬតួនាទីឯកទេស។

**5. និន្នាការទីផ្សារការងារ**

- តម្លៃសេដ្ឋកិច្ចបានជះឥទ្ធិពលលើប្រាក់ឈ្នួលទៅតាមជំនាញមួយចំនួននៅពេលជាក់លាក់។ ឧទាហរណ៍ វិស្វកម្មថាមពលកកើតឡើងវិញកំពុងទទួលបានភាពលេចធ្លោ នៅពេលដែលពិភពលោកផ្លាស់ប្តូរឆ្ពោះទៅរកនិរន្តរភាព។
- ទីផ្សារឌីជីថល( Digital marketing ) វិភាគទិន្នន័យ Supply Change Management

**តារាង 24 តេស្តលទ្ធផលទាក់ទងជាមួយបំណិតលើជំនាញនីមួយៗ**

| Variable | Major | Level of Skill |
|---|---|---|
| Management | | p-value |
| | Development Economics | 0.293 |
| | Accounting | 0.059* |
| | Bank and Finance | 0.017** |
| | Tourism and Hospitality | 0.703 |
| | F | 5.415 |
| | Sig. | 0.000*** |
| | N | 585 |

*: p<0.10, **: p<0.05, ***: p<0.01

តារាងខាងលើបានបង្ហាញថា ៖

លទ្ធផលតេស្ត ANOVA តាមវិធីប្រៀបធៀបភាពខុសយ៉ាងសំខាន់( LSD )ត្រង់កម្រិតជឿជាក់៩៥% ÷

- ជំនាញគ្រប់គ្រងធុរកិច្ចមានកម្រិត «ប្រើប្រាស់បំណិនក្នុងការងារជំនាញ» មានភាពផ្សេងគ្នារវាងជំនាញគណនេយ្យ និងជំនាញ ធនាគារនិងហិរញ្ញវត្ថុ ក្នុងតម្លៃប្រូបាប៊ីលីតេ 10% និង5%។ រីឯជំនាញផ្សេងទៀតមិនមានភាពផ្សេងគ្នា។

**តារាង 25 តេស្តលទ្ធផលទាក់ទងជាមួយបំណិតនៃការសម្រេចចិត្តលើជំនាញនីមួយៗ**

| Variable<br>Accounting | Major | Decision Making<br>p-value |
|---|---|---|
| | Business Management | 0.059* |
| | Development Economics | 0.476 |
| | Bank and Finance | 0.000*** |
| | Tourism and Hospitality | 0.473 |
| | F | 5.415 |
| | Sig. | 0.000*** |
| | N | 585 |

*: p<0.10, **: p<0.05, ***: p<0.01

តារាងខាងលើបានបង្ហាញថា ៖

លទ្ធផលតេស្ត ANOVA តាមវិធីប្រៀបធៀបភាពខុសយ៉ាងសំខាន់(LSD)ត្រង់កម្រិតជឿជាក់៩៥% ÷

- ជំនាញគណនេយ្យមានកម្រិត «ប្រើប្រាស់បំណិនក្នុងការងារជំនាញ» មានភាពផ្សេងគ្នារវាងជំនាញគ្រប់គ្រងធុរកិច្ច និងជំនាញ ធនាគារនិងហិរញ្ញវត្ថុ ក្នុងតម្លៃប្រូបាប៊ីលីតេ 10% និង1%។ រីឯជំនាញផ្សេងទៀតមិនមានភាពផ្សេងគ្នា។

**តារាង 26 តេស្តលទ្ធផលទាក់ទងជាមួយបំណិតនៃការសម្រេចចិត្តលើជំនាញនីមួយៗ**

| Variable<br>Development Economics | Major | Decision Making<br>p-value |
|---|---|---|
| | Business Management | 0.293 |
| | Accounting | 0.476 |
| | Bank and Finance | 0.001*** |
| | Tourism and Hospitality | 0.792 |
| | F | 5.415 |
| | Sig. | 0.000*** |
| | N | 585 |

*: p<0.10, **: p<0.05, ***: p<0.01

តារាងខាងលើបានបង្ហាញថា ៖

លទ្ធផលតេស្ត ANOVA តាមវិធីប្រៀបធៀបភាពខុសយ៉ាងសំខាន់(LSD)ត្រង់កម្រិតជឿជាក់៩៥% ÷

- ជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍កម្រិត «ប្រើប្រាស់បំណិនក្នុងការងារជំនាញ» មានភាពផ្សេងគ្នារវាងជំនាញជំនាញ ធនាគារនិងហិរញ្ញវត្ថុ ក្នុងតម្លៃប្រូបាប៊ីលីតេ 1%។ រីឯជំនាញផ្សេងទៀតមិនមានភាពផ្សេងគ្នា។

**តារាង 27 តេស្តលទ្ធផលទាក់ទងជាមួយបំណិតនៃការសម្រេចចិត្តលើជំនាញនីមួយៗ**

| Variable | Major | Decision Making |
|---|---|---|

| Bank and Finance | p-value |
|---|---|
| Business Management | 0.017** |
| Development Economics | 0.001*** |
| Accounting | 0.000*** |
| Tourism and Hospitality | 0.089* |
| F | 5.415 |
| Sig. | 0.000*** |
| N | 585 |

*: p<0.10, **: p<0.05, ***: p<0.01

តារាងខាងលើបានបង្ហាញថា ៖

លទ្ធផលតេស្ត ANOVA តាមវិធីប្រៀបធៀបភាពខុសយ៉ាងសំខាន់(LSD)ត្រង់កម្រិតជឿជាក់៩៥% ÷

- ជំនាញធនាគារនិងហិរញ្ញវត្ថុកម្រិត «ប្រើប្រាស់បំណិនក្នុងការងារជំនាញ» មានភាពផ្សេងគ្នារវាងជំនាញគណនេយ្យ និងជំនាញ សេដ្ឋកិច្ចអភិវឌ្ឍន៍ក្នុងតម្លៃប្រូបាប៊ីលីតេ 1% និងជំនាញផ្សេងទៀតលើសពី 5%។ រីឯជំនាញផ្សេងទៀតមិនមានភាពផ្សេងគ្នា។

### ៣.៥.២. ការប្រើប្រាស់ចំណេះដឹងក្នុងការបំពេញការងារប្រចាំថ្ងៃ

ការដំណើរការអាជីវកម្មនៅក្នុងអង្គភាពអាជីវកម្ម ឬស្ថាប័នរដ្ឋក្តី ការងារនីមួយៗគឺតម្រូវឱ្យបុគ្គលិកមានការទទួលខុសត្រូវខ្ពស់ទៅលើសកម្មភាពការងារនិងលទ្ធផលការងារដែលទទួលបាន។ ចំណុចទាំងអស់នេះទាមទារឱ្យបុគ្គលិកក៏ដូចជាអ្នកទទួលខុសត្រូវនៅតាមលំដាប់ថ្នាក់ធ្វើការឱ្យអស់ពីសមត្ថភាព ទៅតាមកម្រិតចំណេះដឹងដែលទទួលបានពីការសិក្សារបស់ខ្លួនដែលរៀនកន្លងមក។ តទៅនេះយើងនឹងសិក្សាលើការប្រើប្រាស់សមត្ថភាព ចំណេះដឹងរបស់និស្សិតបញ្ចប់ការសិក្សានៅតាមជំនាញនីមួយៗ។

**តារាង 28 កម្រិតប្រែប្រួលនៃការប្រើប្រាស់ចំណេះដឹងក្នុងការងារធៀបនឹងសញ្ញាបត្រជំនាញ**

| កម្រិតប្រែប្រួលនៃការប្រើប្រាស់ចំណេះដឹងក្នុងការងារធៀបនឹងសញ្ញាបត្រជំនាញ | | | |
|---|---|---|---|
| | ចំនួន | ភាគរយ | ភាគរយបូកបង្គរ |
| ប្រើចំណេះដឹងទាបជាងកម្រិតសញ្ញាបត្រ | 254 | 43.3% | 43.3% |
| ប្រើចំណេះដឹងត្រូវនឹងកម្រិតសញ្ញាបត្រ | 316 | 53.9% | 97.3% |
| ប្រើចំណេះដឹងខ្ពស់ជាងកម្រិតសញ្ញាបត្រ | 16 | 2.7% | 100.0% |
| **សរុប** | 586 | 100.0% | |

តារាងខាងលើបានបង្ហាញថា និស្សិតបានប្រើប្រាស់ចំណេះដឹងក្នុងការបំពេញការងារត្រូវនឹងកម្រិតសញ្ញាបត្ររបស់ខ្លួនមានចំនួន ៣១៦នាក់ ស្មើនឹង ៥៣,៩% នៃនិស្សិតសរុបចំនួន៥៨៦នាក់។ ចំណែកនិស្សិតបានប្រើប្រាស់ចំណេះដឹងក្នុងការបំពេញការងារទាបជាងកម្រិតសញ្ញាបត្រមាន ៤៣,៣% ករណីមាននិស្សិត ២,៧% ដែលបានប្រើប្រាស់សមត្ថភាពលើសកម្រិតសញ្ញាបត្ររបស់ពួកគាត់។ ជាបន្ត យើងនឹងពិនិត្យលើជំនាញនីមួយៗស្តីពីការប្រើប្រាស់ចំណេះដឹងត្រូវនឹងកម្រិតសញ្ញាបត្រដើម្បីបំពេញការងារ។

### ក្រាភិច 14 កម្រិតប្រែប្រួលនៃការប្រើប្រាស់ចំណេះដឹងក្នុងការងារធៀបនឹងសញ្ញាបត្រជំនាញ




ក្រាភិកបានបង្ហាញថា ជាមធ្យមជិត ៥៤,0% នៃជំនាញនីមួយៗបានប្រើប្រាស់សមត្ថភាពស្មើរស្មើកម្រិតសញ្ញាបត្ររបស់ខ្លួន ជាពិសេស ជំនាញធនាគារនិងហិរញ្ញវត្ថុ ជាង ៦៥% ប្រើសមត្ថភាពស្មើកម្រិតសញ្ញាបត្រច្រើនជាងគេ។ លើកលែងជំនាញគណនេយ្យប្រើប្រាស់សមត្ថភាពទាបជាងកម្រិតសញ្ញាបត្រមានចំនួនជាង ៥២,៣%។ ករណីជំនាញទេសចរណ៍និងបដិសណ្ឋារកិច្ច និងគណនេយ្យអាចមានលទ្ធភាពប្រើសមត្ថភាពលើសកម្រិតសញ្ញាបត្រមានចំនួនជាង ២%។

**ខាងក្រោមនេះជាព័ត៌មានតម្រូវការជំនាញផ្សេងៗក្រៅពីជំនាញដែលបានសិក្សានៅស.ភ.ន.វ.ស. ៖**

- Digital marketing ចំនួន ៣ករណី
- Soft skill ចំនួន ៧ករណី
- ជំនាញ Computor and Mecanic ចំនួន ១ករណី
- ជំនាញទំនាក់ទំនង ចំនួន ៥ករណី
- ជំនាញ Chiniss languages ចំនួន ១ករណី

## ៣.៦. ព័ត៌មានពីមតិយោបល់របស់អ្នកចូលរួម

នៅតាមសាកលវិទ្យាល័យមានការិយាល័យសេវានិស្សិត ដែលមានភារកិច្ចជួយដោះស្រាយបញ្ហាដល់តម្រូវការផ្សេងៗដែលនិស្សិតអាចទទួលបានពីសាកលវិទ្យាល័យជាពិសេសព័ត៌មានការស្វែងរកការងារផ្ញើទៅកាន់និស្សិត និងអត្ថប្រយោជន៍ផ្សេងៗទៀត។ តទៅនេះយើងពិនិត្យលទ្ធភាពខ្លះៗដែលនិស្សិតបានទទួលសេវានានាពីសាកលវិទ្យាល័យ និងស្តាប់ព័ត៌មាន ឬសំណូមពរត្រឡប់ពីនិស្សិតវិញ។

### ៣.៦.១. ការជួយនិស្សិតដើម្បីទទួលបានការងារ

ជារៀងរាល់ឆ្នាំ សាកលវិទ្យាល័យបានផ្តល់ព័ត៌មានទៅកាន់និស្សិតតាមរយៈការផ្សព្វផ្សាយមានដូចជា ខិត្តប័ណ្ណ

ផ្សព្វផ្សាយធ្វើសិក្ខាសាលា ឬបង្ហាញការស្វែងរកការងារតាមរយៈ website ជាដើម ក្នុងគោលបំណងឱ្យនិស្សិតបានដឹងព័ត៌មានតម្រូវការការងារនៃទីផ្សារពលកម្ម។

**តារាង 29 ការជួយនិស្សិតដើម្បីទទួលបានការងារ**

| | ចំនួន | ភាគរយ | ភាគរយបូកបង្គរ |
|---|---|---|---|
| បានជួយតិចតួច | 74 | 13.3% | 13.3% |
| បានជួយមធ្យម | 162 | 29.1% | 42.4% |
| បានជួយបង្គួរ | 163 | 29.3% | 71.8% |
| បានជួយច្រើន | 157 | 28.2% | 100.0% |
| **សរុប** | 556 | 100.0% | |

តាមលទ្ធផលបង្ហាញថាក្នុងការទទួលបានការងារធ្វើ មាននិស្សិត ១៣,៣% ថាបានជួយតិចតួច ខណៈមាននិស្សិត ២៨,២% ថាបានជួយច្រើន។

**តារាង 30 តេស្តលទ្ធផល**

| Label | N | Mean | SD | t | Sig. | Lower | Upper |
|---|---|---|---|---|---|---|---|
| RULE supporting to get the Job | 556 | 2.72 | 1.016 | 63.239 | 0.000*** | 2.64 | 2.81 |

*: p<0.10, **: p<0.05, ***: p<0.01

បើយោងតាមវិធីវាយតម្លៃ One Sample T-Test ក្នុងកម្រិតជឿជាក់ ៩៥%នេះ លទ្ធផលបង្ហាញថានិស្សិតយ៉ាងតិច ៥៨,៤% បានវាយតម្លៃថាបានជួយនិស្សិតដល់កម្រិតល្អបង្គួរក្នុងការទទួលបានព័ត៌មានការងារធ្វើ។

### ៣.៦.២. ការបណ្តុះបណ្តាលបន្ថែមនៅកន្លែងការងារ

នៅក្នុងស្ថាប័នរដ្ឋ ឬនៅតាមបណ្តាអង្គភាពអាជីវកម្មនានានៅពេលដែលមានការផ្លាស់ប្តូរបច្ចេកវិទ្យាថ្មី ឬបំពាក់បច្ចេកទេសថ្មីដើម្បីបង្កើនផលិតភាពការងារ វាតែងតែរៀបចំធ្វើការបណ្តុះបណ្តាលដល់បុគ្គលិករបស់ខ្លួនទៅតាមពេលវេលាត្រឹមត្រូវ ដល់មនុស្សត្រឹមត្រូវ និងសមត្ថភាពត្រឹមត្រូវ។ តទៅនេះយើងនឹងបានដឹងព័ត៌មានត្រឡប់។

**តារាង 31 ការបណ្តុះបណ្តាលបន្ថែមនៅកន្លែងការងារ**

| | ចំនួន | ភាគរយ | ភាគរយបូកបង្គរ |
|---|---|---|---|
| បានទទួលការបណ្តុះបណ្តាល | 429 | 73.2% | 73.2% |
| មិនបានទទួលការបណ្តុះបណ្តាល | 157 | 26.8% | 100.0% |
| **សរុប** | 586 | 100.0% | |

លទ្ធផលបង្ហាញថា និស្សិត៤២៩នាក់ស្មើនឹង៧៣,២% ទទួលបានការបណ្តុះបណ្តាលជំនាញបន្ថែមនៅ

កន្លែងការងារ ករណីមាន១៥៧នាក់ស្មើ២៦,៨% ផ្សេងទៀតមិនទទួលបានការបណ្តុះបណ្តាលជំនាញបន្ថែម។

**ក្រាភិច 15 ការបណ្តុះបណ្តាលនៅតាមបណ្តាស្ថាប័ននានា**




នៅលើក្រាភិកបង្ហាញថា វិស័យឯកជននៅជួរមុខក្នុងការបណ្តុះបណ្តាលជំនាញបន្ថែមមានចំនួន៧៨,៩%នៃនិស្សិតដែលបានទទួលការងារធ្វើក្នុងវិស័យឯកជនត្រូវបានទទួលការបណ្តុះបណ្តាលបន្ថែមបន្ទាប់ពីចូលបំរើការងារបានមួយរយៈ។ ទន្ទឹមគ្នាដែរ និស្សិតដែលបានការងារធ្វើនៅស្ថាប័នរដ្ឋមានចំនួន ៧១,០% ត្រូវបានទទួលការបណ្តុះបណ្តាលជំនាញបន្ថែមផងដែរ។

### ៣.៦.៣. ការសិក្សាបន្តទៅកម្រិតសញ្ញាបត្រផ្សេងទៀត

នៅពេលទទួលបានការងារធ្វើរួចហើយ វាអាចមាននិស្សិតមួយចំនួនសម្រេចចិត្តបន្តការសិក្សាលើបរិញ្ញាបត្រជំនាញផ្សេងបន្ថែម ឬបន្តទៅសិក្សាកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ទៀតដើម្បីបំពេញចន្លោះតម្រូវការទីផ្សារការងារដែលមានការប្រែប្រួលថ្មីៗ។ តទៅនេះយើងនឹងបានដឹងព័ត៌មានត្រឡប់ដែលមានសារៈសំខាន់។

**តារាង 32 ការសិក្សាបន្តទៅកម្រិតសញ្ញាបត្រផ្សេងទៀត**

| | ចំនួន | ភាគរយ | ភាគរយបូកបង្គរ |
|---|---|---|---|
| បានរៀន និងបញ្ចប់ដោយជោគជ័យ | 33 | 5.8% | 5.8% |
| កំពុងសិក្សា | 61 | 10.7% | 16.5% |
| មិនបានបន្តការសិក្សា | 476 | 83.5% | 100.0% |
| **សរុប** | 570 | 100.0% | |

ជាលទ្ធផលមាននិស្សិតបានរៀននិងបញ្ចប់ដោយជោគជ័យនូវកម្រិតបរិញ្ញាបត្រ និង/ឬបរិញ្ញាបត្រជាន់ខ្ពស់

ផ្សេងមានចំនួន ៥,៨% កំពុងតែសិក្សាមាន ១០,៧% និងមិនបានសិក្សាបន្តទៅកម្រិតបរិញ្ញាបត្រនិង/ឬបរិញ្ញាបត្រជាន់ខ្ពស់ផ្សេងមានចំនួន ៨៣,៥% ។

### ៣.៦.៤. ការគាំទ្រដល់ការសិក្សាជំនាញខ្លីៗ

ការបំពេញការងារប្រចាំថ្ងៃតែងជួបនូវការខ្វះចន្លោះបច្ចេកទេសសម្រាប់ដោះស្រាយការងារចៀសពុំរួច។ ដើម្បីដោះស្រាយបញ្ហាទាំងនោះ ការឆ្លៀតពេលទៅរៀនវគ្គសិក្សាជំនាញខ្លីៗគឺមានសារៈសំខាន់សម្រាប់មនុស្សដែលមានភាពឧស្សាហ៍ព្យាយាម។ យើងនឹងពិនិត្យភាពជាក់ស្តែងនៃការសិក្សាជំនាញខ្លីៗ។

**តារាង 33 ការគាំទ្រដល់ការសិក្សាបន្តលើជំនាញខ្លីៗ**

| អ្នកគាំទ្រដល់វគ្គបណ្តុះបណ្តាលខ្លីៗ | ចំនួន | ភាគរយ | ភាគរយបូកបង្គរ |
|---|---|---|---|
| ខ្លួនឯង | 148 | 26.7% | 26.7% |
| ស្ថាប័នកំពុងបំរើការ | 144 | 25.9% | 52.6% |
| ភ្នាក់ងារសហប្រត្តិបត្តិការផ្សេងៗ | 128 | 23.1% | 75.7% |
| មិនបានទទួល | 135 | 24.3% | 100.0% |
| **សរុប** | 555 | 100.0% | |

ការបណ្តុះបណ្តាលបន្ថែមលើជំនាញខ្លីៗ ភាគច្រើនទទួលបានការគាំទ្រតាមរយៈអង្គភាព និងភ្នាក់ងារសហ-ប្រត្តិបត្តិការផ្សេងៗដែលពួកគាត់កំពុងបំរើការមានចំនួន ៤៩,០% ចំណែកឯការបណ្តុះបណ្តាលដោយចំណាយថវិកាផ្ទាល់ខ្លួនមាន ២៦,៧% រីឯករណីមិនទទួលបានការគាំទ្រផ្សេងៗមាន ២៤,៣% ។

### ៣.៦.៥. ការចូលរួមសកម្មភាពសង្គម

ការងារសង្គមជាសកម្មភាពសប្បុរសធម៌មួយបែបដែលត្រូវបានគេនិយមប្រើប្រាស់សង្គម ឬប្រទេសសម័យទំនើប ឬអាចនិយាយម្យ៉ាងទៀតថាប្រទេសរីកចំរើនគឺសំដៅដល់អ្នកមានសមត្ថភាព មានបទពិសោធន៍ ឬមានធនធាន ដើម្បីចែករំលែកអ្វីទាំងអស់នោះទៅកាន់អ្នករស់នៅក្នុងតំបន់កំពុងអភិវឌ្ឍន៍ជាអាទិភាព។ ម្យ៉ាងទៀត ការចូលរួមសកម្មភាពសង្គម សំដៅលើការចូលរួមយ៉ាងសកម្ម និងការចូលរួមរបស់បុគ្គលម្នាក់ក្នុងអន្តរកម្មសង្គម ព្រឹត្តិការណ៍ ឬសកម្មភាពជាក្រុម។ វារួមបញ្ចូលអាកប្បកិរិយា ការប្រាស្រ័យទាក់ទង និងទំនាក់ទំនងដែលធ្វើឡើងជាមួយអ្នកដទៃក្នុងការកំណត់ផ្សេងៗ រាប់ចាប់ពីការជួបជុំធម្មតា រហូតដល់ព្រឹត្តិការណ៍សហគមន៍ ឬអង្គការដែលមានរចនាសម្ព័ន្ធ។ ការចូលរួមនេះជារឿយៗត្រូវបានផ្សារភ្ជាប់ជាមួយនឹងអត្ថប្រយោជន៍ដូចជា សុខភាពផ្លូវចិត្តប្រសើរឡើង ទំនាក់ទំនងកាន់តែរឹងមាំ និងបង្កើនជំនាញសង្គម។ ឧទាហរណ៍ខ្លះនៃការចូលរួមសកម្មភាពសង្គមមានដូចជា៖

1. ការចូលរួមរបស់សហគមន៍៖
   - ការងារស្ម័គ្រចិត្តនៅតាមទីជម្រក បណ្ណាល័យ ឬមជ្ឈមណ្ឌលសហគមន៍។
   - រៀបចំ ឬចូលរួមព្រឹត្តិការណ៍នានាក្នុងតំបន់ ថែរក្សាបរិស្ថានល្អ ឬការសម្អាតទីសាធារណៈ ។
2. សកម្មភាពក្រុម៖
   - ចូលរួមជាមួយក្លឹប ឬសង្គម ដូចជាក្លឹបសៀវភៅ ក្រុមកីឡា ឬក្រុមចំណូលចិត្ត។

- ការចូលរួមក្នុងថ្នាក់លំហាត់ប្រាណជាក្រុមដូចជាយូហ្គា Zumba ឬសិល្បៈក្បាច់គុន។

3. បណ្ដាញ និងព្រឹត្តិការណ៍អាជីព៖
   - ចូលរួមក្នុងសន្និសិទ សិក្ខាសាលា ឬការប្រជុំទាក់ទងនឹងការអភិវឌ្ឍន៍អាជីព។
   - ចូលរួមកម្មវិធីចម្រុះសង្គម ឬព្រឹត្តិការណ៍បង្កើតក្រុមនៅកន្លែងធ្វើការ។
4. អន្តរកម្មសង្គមធម្មតា៖
   - ជួបមិត្តភ័ក្តិសម្រាប់កាហ្វេ អាហារ ឬពេលយប់មើលកុន ។
   - ចូលរួមនៅក្នុងសហគមន៍អនឡាញ ឬលេងហ្គេមជាមួយមិត្តភក្តិ។
5. សកម្មភាពវប្បធម៌ និងកម្សាន្ត៖
   - ចូលរួមការប្រគុំតន្ត្រី ការសម្តែងល្ខោន ឬការតាំងពិពណ៌សិល្បៈជាមួយអ្នកដទៃ។
   - ចូលរួមក្នុងពិធីបុណ្យវប្បធម៌ ឬព្រឹត្តិការណ៍បេតិកភណ្ឌ។

ឧទាហរណ៍ជាក់ស្តែងទាំងនេះបង្ហាញពីវិធីដែលបុគ្គលម្នាក់ៗអាចចូលរួមយ៉ាងសកម្ម ទៅក្នុងអន្តរកម្មប្រកបដោយអត្ថន័យ លើកកម្ពស់អារម្មណ៍នៃភាពជាកម្មសិទ្ធិ និងសហគមន៍។

**តារាង 34 ការចូលរួមសកម្មភាពសង្គម**

| | ចំនួន | ភាគរយ | ភាគរយបូកបង្គរ |
|---|---|---|---|
| មិនបានចូលរួម | 158 | 27.0% | 27.0% |
| បានចូលរួមតិចតួច | 223 | 38.1% | 65.0% |
| បានចូលរួមមធ្យម | 158 | 27.0% | 92.0% |
| បានចូលរួមបង្គួរ | 42 | 7.2% | 99.1% |
| បានចូលរួមច្រើន | 5 | 0.9% | 100.0% |
| សរុប | 586 | 100.0% | |

ជាលទ្ធផលយើងបានសង្កេតឃើញថា មានយ៉ាងហោចណាស់ជាង៦៥,១% នៃនិស្សិតបញ្ចប់ការសិក្សាបានចូលរួមរាប់ពីសកម្មភាពតិចតួច និងមធ្យមក្នុងសកម្មភាពសង្គមដែលគួរឱ្យកត់សម្គាល់។

**តារាង 35 តេស្តលទ្ធផល**

| Label | N | Mean | SD | t | Sig. | Lower | Upper |
|---|---|---|---|---|---|---|---|
| Social Activity | 586 | 2.17 | .936 | 56.108 | 0.000*** | 2.09 | 2.24 |

*:p<0.10, **:p<0.05, ***:p<0.01

បើយោងតាមវិធីវាយតម្លៃ One Sample T-Test ក្នុងកម្រិតជឿជាក់ ៩៥% នេះលទ្ធផលបង្ហាញថានិស្សិតប្រមាណជាង ៦៥,០% បានចូលរួមចាប់ពីកម្រិតមធ្យមក្នុងការងារសង្គមជាសកម្មភាពបែបសប្បុរសធម៌។

## ៣.៦.៦. លទ្ធផលនៃកម្មវិធីសិក្សាបានឆ្លើយតបនឹងក្របខ័ណ្ឌគុណវុឌ្ឍិជាតិ

កម្មវិធីសិក្សានៃមុខជំនាញនីមួយៗ ត្រូវបានរៀបចំឡើងដោយស្របតាមក្របខ័ណ្ឌគុណវុឌ្ឍិជាតិ ដែលបានដែលផ្សព្វផ្សាយឱ្យប្រើដោយអនុក្រឹត្យស្តីពីក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា លេខ១៥៣ អនក្រ.បកចុះថ្ងៃទី ២៨ ខែមីនា ឆ្នាំ២០១៤ ។ លទ្ធសិក្សានៃក្របខ័ណ្ឌគុណវុឌ្ឍិជាតិ រួមមាន៖

ទី១. ចំណេះដឹង៖ នៅក្នុងចំណុចត្រេទី៣មានពាក្យគន្លឹះសំខាន់មួយដែលអាចវាស់បានគឺ « ដំណោះស្រាយបញ្ហា » សម្រាប់វាយតម្លៃសូចនាករទី១

ទី២ .ជំនាញក្នុងការគិត៖ នៅក្នុងចំណុចត្រេទី៣មានពាក្យគន្លឹះសំខាន់មួយដែលអាចវាស់បានគឺ « ចំណេះដឹង ឬការគិតពិចារណា » សម្រាប់វាយតម្លៃសូចនាករទី២

ទី៣. ជំនាញទំនាក់ទំនងអន្តរបុគ្គលនិងការទទួលខុសត្រូវ៖ នៅក្នុងចំណុចត្រេទី១មានពាក្យគន្លឹះសំខាន់មួយដែលអាចវាស់បានគឺ « ភាពជាអ្នកដឹកនាំ» សម្រាប់វាយតម្លៃសូចនាករទី៣

ទី៤. ជំនាញលេខនព្វន្ត ព័ត៌មានវិទ្យា និងទំនាក់ទំនង៖ នៅក្នុងចំណុចត្រេទី១មានពាក្យគន្លឹះសំខាន់មួយដែលអាចវាស់បានគឺ « បច្ចេកវិទ្យាព័ត៌មាន » សម្រាប់វាយតម្លៃសូចនាករទី៤

ដូច្នេះ ដើម្បីដឹងថាកម្មវិធិសិក្សាទទួលបានលទ្ធផលរំពឹងទុកស្របតាមគុណវុឌ្ឍិជាតិដល់កម្រិតណា គឺការធ្វើតេស្តជាកត្តាសំខាន់។

**ប្រើវិធីវិភាគ** Binary Logistic Model ៖

នៅក្នុងអថេរ *ភេទ* ករណីភេទ បើ ប្រុស=1 និងផ្ទុយមកវិញ បើ ស្រី=0

ករណីអថេរផ្សេងទៀតដែលវាស់ជាគុណភាព ( Dummy variable ) នៅក្នុងគំរូវិភាគត្រូវកំណត់យកក្នុង

បច្ចេកទេសតក្កវិទ្យា (1/0) សម្រាប់ការវិភាគនិងស្វែងរកលទ្ធផលដែលមាននៅក្នុងក្របខ័ណ្ឌគុណវុឌ្ឍិជាតិ

លទ្ធផលត្រូវបានបង្ហាញក្នុងតារាងខាងក្រោមនេះ÷

**តារាង 36 ការវិភាគលទ្ធផលទៅនឹងក្របខ័ណ្ឌគុណវុឌ្ឍិជាតិ**

| ល.រ | អថេរពាក់ព័ន្ធក្នុងគំរូវិភាគ | ដោះស្រាយបញ្ហា | ចំណេះដឹង/ ការគិតពិចារណា | ភាពជាអ្នកដឹកនាំ | បច្ចេកវិទ្យាព័ត៌មាន |
|---|---|---|---|---|---|
| | | Coef. | Coef. | Coef. | Coef. |
| 1 | ( Constant ) | 0.628*** | 0.750*** | 0.380*** | 0.427*** |
| 2 | ភេទ | -0.009 | 0.020 | 0.032 | -0.040 |
| 3 | កម្មវិធីសិក្សាឆ្លើយតបតម្រូវការទីផ្សារ | 0.043 | 0.047** | 0.112*** | 0.174*** |
| 4 | ទ្រឹស្តីមានសារៈសំខាន់ចំពោះការងារ | 0.182*** | 0.028 | 0.183*** | 0.080 |
| 5 | គំនិតច្នៃប្រឌិត | 0.015 | 0.031 | 0.013 | -0.012 |
| 6 | គំនិតត្រិះរិះពិចារណា | -0.019 | -0.027 | -0.065 | -0.106** |

| | | | | | |
|---|---|---|---|---|---|
| 7 | ធ្វើការងារឆ្ពោះទៅរកគោលដៅ | 0.016 | 0.030 | -0.002 | -0.026 |
| 8 | ធ្វើការងារជាក្រុម | 0.017 | -0.014 | 0.031 | -0.022 |
| 9 | ភាពជាអ្នកដឹកនាំ | 0.077** | 0.006 | 0.104*** | 0.039 |
| 10 | សមត្ថភាពសម្របតាមការផ្លាស់ប្តូរ | -0.020 | 0.004 | -0.001 | 0.004 |
| 11 | ចំណេះដឹងផ្នែកបច្ចេកវិទ្យាព័ត៌មាន | -0.001 | -0.020 | 0.015 | 0.129*** |
| 12 | សមត្ថភាពភាសាអង់គ្លេស | 0.064* | 0.159*** | 0.216*** | 0.278*** |
| | N | 585 | 585 | 585 | 585 |
| | R-square | 0.120 | 0.124 | 0.196 | 0.176 |
| | Sig. | 0.001** | 0.001** | 0.001** | 0.001*** |

*:p<0.10, * *:p<0.05, * * *:p<0.01

- ទី១. កម្រិតចំណេះដឹង៖ *ការដោះស្រាយបញ្ហា* មានទំនាក់ទំនងជាមួយនឹងអេថេរ៖ ទ្រឹស្តីមានសារៈសំខាន់ចំពោះការងារ, ភាពជាអ្នកដឹកនាំ, និងភាសាអង់គ្លេស ។
- ទី២. ជំនាញក្នុងការគិត៖ *ចំណេះដឹង* មានទំនាក់ទំនងជាមួយអេថេរ៖ កម្មវិធីសិក្សាឆ្លើយតបតម្រូវការទីផ្សារ និងសមត្ថភាពអង់គ្លេស ។
- ទី៣. ជំនាញទំនាក់ទំនងអន្តរបុគ្គលនិងការទទួលខុសត្រូវ៖ *ភាពជាអ្នកដឹកនាំ* មានទំនាក់ទំនងជាមួយនឹងអថេរ៖ កម្មវិធីសិក្សាឆ្លើយតបតម្រូវការទីផ្សារ, ទ្រឹស្តីមានសារៈសំខាន់ចំពោះការងារ, ភាពជាអ្នកដឹកនាំ, និងសមត្ថភាពភាសាអង់គ្លេស។
- ទី៤. ជំនាញលេខនព្វន្ត ព័ត៌មានវិទ្យា និងទំនាក់ទំនង៖ *បច្ចេកវិទ្យាព័ត៌មាន* មានទំនាក់ទំនងជាមួយនឹងអថេរ៖ កម្មវិធីសិក្សាឆ្លើយតបតម្រូវការទីផ្សារ, គំនិតត្រិះរិះពិចារណា, ចំណេះដឹងផ្នែកបច្ចេកវិទ្យាព័ត៌មាន និងសមត្ថភាពភាសាអង់គ្លេស ។

លទ្ធផលនៃការសិក្សាលើស្ថានភាពមានការងារធ្វើរបស់និស្សិតក្រោយបញ្ចប់ការសិក្សាបង្ហាញឱ្យដឹងថា កម្មវិធីសិក្សាគ្រប់ជំនាញរបស់មហាវិទ្យាវិទ្យាសាស្ត្រសេដ្ឋកិច្ចនិងគ្រប់គ្រងដែលបាននិងកំពុងអនុវត្ត និងធ្វើការកែលម្អជាបន្តបន្ទាប់មកនេះ បានឆ្លើយតបតាមក្របខ័ណ្ឌគុណវុឌ្ឍិជាតិផង និងជាពិសេសបានឆ្លើយតបតាមស្ថានភាពបរិបទប្រែប្រួលនៃទីផ្សារការងារផង។

## ចំណុចខ្លាំង និងចំណុចខ្វះខាត នៃកម្មវិធីបណ្តុះបណ្តាល

កម្មវិធីសិក្សាទាំង៥ជំនាញរួមមាន៖ ជំនាញគ្រប់គ្រងធុរកិច្ច ជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍ ជំនាញគណនេយ្យ ជំនាញធនាគារនិងហិរញ្ញវត្ថុ និងជំនាញគ្រប់គ្រងសណ្ឋាគារនិងបដិសណ្ឋារកិច្ច បានអនុវត្តតាមការណែនាំពីគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ចាប់តាំងពីឆ្នាំ ២០០៤ និងជាពិសេសនៅចុងក្រោយនេះគឺបានដើរតាមក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជាចាប់តាំងពីឆ្នាំ២០១៤ បន្ថែមពីលើអ្វីដែលសាកលវិទ្យាល័យបាននិងកំពុងអនុវត្តក្នុង

ពេលបច្ចុប្បន្ន។

លទ្ធផលនៃការស្រាវជ្រាវពីភាពមានការងារធ្វើរបស់និស្សិតបញ្ចប់ការសិក្សាបានបង្ហាញថា៖

**ចំណុចខ្លាំង**

- អត្រានៃចំនួននិស្សិតដែលទទួលបានការងារធ្វើ បន្ទាប់ពីបញ្ចប់ការសិក្សានៅតែមានកម្រិតខ្ពស់ជុំវិញ ៩៤,៧%
- ជាង ៥៦% នៃនិស្សិតបញ្ចប់ការសិក្សាទទួលបានការងារធ្វើស្របជំនាញ
- និស្សិតរកការងារធ្វើបានភ្លាមៗមាន ៦២,៩% និងក្រោម១ខែមាន ៩,៥%
- និស្សិតប្រមាណ ៥៣,៩% បានប្រើប្រាស់ចំណេះដឹងបំពេញការងារស្របនឹងកម្រិតសញ្ញាបត្រ រីឯ ២,៧% បានប្រើប្រាស់ចំណេះដឹងបំពេញការងារលើសកម្រិតសញ្ញាបត្រ
- ការបើកអាជីវកម្មស្របជំនាញសរុបមាន ៤១,៦% ដែលក្នុងនោះជាង ១៦,៦% ដឹកនាំដោយស្ត្រី
- ភាសាអង់គ្លេសមានចំណែកដើរតួនាទីជាយាន្តសម្រាប់ពង្រឹងសមត្ថភាពទាំងជំនាញរឹង និងជំនាញទន់
- កម្មវិធីសិក្សាបានឆ្លើយតបទៅនឹងក្របខ័ណ្ឌគុណវុឌ្ឍិជាតិ៖ កម្រិតចំណេះដឹង ជំនាញក្នុងការគិត ជំនាញទំនាក់ទំនងអន្តរបុគ្គលនិងការទទួលខុសត្រូវ និង ជំនាញលេខនព្វន្ត ព័ត៌មានវិទ្យានិងទំនាក់ទំនង។

**ចំណុចប្រឈម**

- ការងារជាអ្នកបច្ចេកទេសនៅមានកម្រិតទាបជុំវិញ ៦,៧% ខណៈអ្នកគ្រប់គ្រងកម្រិតខ្ពស់មាន ១,៧%
- ប្រាក់ឈ្នួលភាគច្រើននៅចន្លោះ ២០០$ ដល់ ៦០០$ មានដល់កម្រិត ៨៥,៥% ខណៈអ្នកមានប្រាក់ឈ្នួលច្រើនជាង ១០០០$ ឬយ៉ាងតិចស្មើ៥ដងនៃកម្មករគ្មានជំនាញមាន ១,៥%
- ក្នុងកម្រិតជឿជាក់៩៥%នៃសេចក្តីពេញចិត្ត និស្សិតបានពេញចិត្តខ្លាំងចំពោះកម្មវិធីសិក្សា។

**មតិយោបល់រួមរបស់អ្នកចូលរួម**

- កុំតម្រូវសិស្សឱ្យរៀននិងធ្វើតាមតែស្វាយដូចគ្នា ចូរឱ្យពួកគេអាចបញ្ចេញភាពច្នៃប្រឌិត និងសមត្ថភាពពិតរបស់ពួកគេផង
- គួរពង្រឹងផ្នែករដ្ឋបាលអោយបានល្អជាងនេះ
- សូមបន្ថែមមុខជំនាញដូចជា Financial modelling, equity investment, equity research, investor relation សម្រាប់ថ្នាក់បរិញ្ញាបត្រ។
- កម្មវិធីសិក្សាមិនសូវមានភាសាបរទេសជាហេតុធ្វើឱ្យសិស្សពិបាកសម្របខ្លួនពេលចេញធ្វើការ
- សូមខាងសាលាពង្រឹងផ្នែកភាសាបន្ថែម រួមបញ្ចូលទាំង computer & soft skill
- កុំតម្លើងថ្លៃសិក្សារទៀតអី ពីមួយឆ្នាំទៅមួយឆ្នាំនិស្សិតរកលុយបង់មិនទាន់ទេ
- សូមមានវគ្គបណ្តុះបណ្តាលបន្ថែមទៅលើបច្ចេកវិទ្យា
- គួរមានកម្មវិធីអនុវត្តអោយច្រើនងាយយល់ និងមានសកម្មភាពអនុវត្តច្រើនជាងទ្រឹស្តី
- សូមឱ្យមានកម្មវិធី ចុះកម្មសិក្សារផ្សេងៗ និងឱ្យចំជំនាញ

# ផ្នែកទី៤. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ការសិក្សាស្តីពីស្ថានភាពមានការងារធ្វើរបស់និស្សិតបញ្ចប់ការសិក្សានៅឆ្នាំ២០២៣នេះ ធ្វើឡើងដើម្បីស្វែងរកភាពខ្លាំង និងភាពខ្វះចន្លោះនៃកម្មវិធីសិក្សា។ បន្ទាប់ពីបានដឹងចំណុចទាំងអស់នេះហើយ សេចក្តីសន្និដ្ឋាននិងអនុសាសន៍មួយចំនួនបានបង្ហាញជាបន្តបន្ទាប់ខាងក្រោមនេះ៖

## ៤.១. ការសន្និដ្ឋាន

តាមលទ្ធផលដែលបានបង្ហាញខាងលើបញ្ជាក់ឱ្យឃើញថា កម្មវិធីបណ្តុះបណ្តាលជំនាញទាំង៥របស់មហាវិទ្យាល័យវិទ្យាសាស្ត្រសេដ្ឋកិច្ចនិងគ្រប់គ្រង បានដំណើរការល្អទាំងជំនាញ ចំណេះដឹងគ្រប់គ្រាន់ដល់និស្សិតដែលអាចឱ្យពួកគេបន្ទាប់ពីបញ្ចប់ការសិក្សាទៅអាចនឹងរកការងារធ្វើបានឆាប់។ និស្សិតភាគច្រើនមានការងារធ្វើតាំងពីនៅកំពុងសិក្សា បន្ទាប់ពីនោះប្រើពេលតិចជាង១ខែ និងនៅចន្លោះពី១ខែ ទៅ ៣ខែអាចរកបានការងារធ្វើស្មើរគ្នា។ ភាគច្រើនមានការងារធ្វើត្រូវតាមជំនាញច្រើជាង៥៦% តាមកម្មវិធីបណ្តុះបណ្តាលនៅ ស.ភ.ន.វ.ស.។ បន្ថែមពីនេះ និស្សិតមានលទ្ធភាពប្រើប្រាស់ចំណេះដឹងស្របកម្រិតសញ្ញាបត្រជិត៥៤% ក្នុងការបំពេញការងារប្រចាំថ្ងៃរបស់ពួកគេ។ ទទួលបានប្រាក់ឈ្នួលខ្ពស់យ៉ាងតិច៥ដងនៃកម្មការគ្មានជំនាញមាន១,៥% និងមាននិស្សិត ដែលមានសមត្ថភាពបង្កើតសហគ្រាសអាជីវកម្មផ្ទាល់ខ្លួនក្នុងនោះមានភាគច្រើនអាជីវកម្មដឹកនាំដោយស្ត្រី។ ចំណុចសំខាន់ចុងក្រោយគឺកម្មវិធីសិក្សាទាំង៥ជំនាញបានឆ្លើយតបតាមក្របខ័ណ្ឌគុណវុឌ្ឍិជាតិដូចបានបង្ហាញក្នុងតារាងវិភាគលេខ៣៦ស្រាប់។

## ៤.២. អនុសាសន៍

ដើម្បីឱ្យភាពខ្លាំងទាំងឡាយដែលបានលើកយកមកបង្ហាញខាងលើនេះ កាន់តែមានឧត្តមភាពបន្ថែមទៀត មហាវិទ្យាល័គួរពិចារណាលើ ៣ចំណុច សម្រាប់ធ្វើការពិនិត្យ និងពិចារណា៖

- គួរពិនិត្យមើលសំណួរពាក់ព័ន្ធកម្រិតពេញចិត្តរបស់និស្សិតចំពោះកម្មវិធីសិក្សាឱ្យជាពិសេសទំហំរង្វាស់ និងមើលវិធីសាស្ត្របង្រៀន ឬពិភាក្សាវិធីបង្រៀនជាមួយអ្នកបង្រៀន។
- គួរពិនិត្យមើលឡើងវិញប្លង់មេរៀនលម្អិតតាមជំនាញនីមួយៗ ដើម្បីបំពេញកម្មវិធីសិក្សាឱ្យកាន់តែប្រសើរជាពិសេសការលើកឧទាហរណ៍មកអនុវត្តន៍ឱ្យស្របតាមខ្លឹមសាររបស់មុខវិជ្ជានីមួយៗនៃកម្មវិធីសិក្សា
- គួរពិនិត្យមើលបច្ចេកទេសបង្រៀន ជាពិសេសការបង្រៀនផ្នែកទ្រឹស្តីផ្សារភ្ជាប់ជាមួយការអនុវត្តន៍ និងឱ្យស្របតាមស្ថានភាពពិតនៃសេដ្ឋកិច្ចទីផ្សារ។

# ផែនការសម្រាប់ឆ្នាំ២០២៥ និងសំណូមពរ

លទ្ធផលស្រាវជ្រាវនេះបានឆ្លុះបញ្ចាំងពីសកម្មភាពមួយចំនួនដែលបានជួបប្រទះនៅពេលបច្ចុប្បន្ន។ ក្នុងពេលអនាគតអ្វីៗមានការប្រែប្រួលទោះក្នុងកម្រិតណាមួយ។ ដូច្នេះចំណុចដែលគួរធ្វើបន្ត និងជាសំណូមពរ៖

- ត្រូវពិនិត្យ និងធ្វើបច្ចុប្បន្នភាពកម្រងសំនួរស្រាវជ្រាវសម្រាប់សិក្សាស្វែងយល់ចំពោះនិស្សិតបញ្ចប់ការសិក្សាក្នុងឆ្នាំសិក្សា២០២៣-២០២៤ និងឆ្នាំសិក្សាបន្តបន្ទាប់
- សិក្សាពីការវិវត្តទីផ្សារការងារ និងបច្ចេកវិទ្យាឌីជីថល

- នៅក្នុងទីផ្សារការងារប្រកួតប្រជែង រដ្ឋាភិបាលគួរមានសេចក្តីណែនាំស្តីពីការកំណត់ប្រាក់ឈ្នួលអប្បរមាសម្រាប់អ្នកមានសញ្ញាបត្រទៅតាមលំដាប់នៃកម្រិតសញ្ញាបត្រទុកជាការលើកទឹកចិត្តដល់អ្នកសិក្សា។

## ឯកសារយោង


1. អនុក្រឹត្យស្តីពីក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា លេខ១៥៣ អនក្រ.បកចុះថ្ងៃទី ២៨ ខែមីនា ឆ្នាំ២០១៤
2. សេចក្តីណែនាំលេខ៥០ អយក.សណន ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា
3. គោលការណ៍ណែនាំលេខ៦៥៥ ស.ភ.ន.វ.ស ចុះថ្ងៃទី ២៤ ខែឧសភា ឆ្នាំ២០២២ ស្តីពីការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច
4. លិខិតឧទ្ទេសនាមលេខ៧២៨ ស.ភ.ន.វ.ស ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២២ ស្តីពីគណៈកម្មការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា
5. លិខិតឧទ្ទេសនាមលេខ១៦៦៥ ស.ភ.ន.វ.ស ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីគណៈកម្មការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា
6. របាយការណ៍ស្តីពីលទ្ធផលអង្កេតពីភាពមានការងារធ្វើរបស់និស្សិត ស.ភ.ន.វ.ស. ខែមីនា ឆ្នាំ២០១៦
7. របាយការណ៍ស្តីពីលទ្ធផលអង្កេតពីភាពមានការងារធ្វើរបស់និស្សិត ស.ភ.ន.វ.ស. ខែធ្នូ ឆ្នាំ២០១៦
8. របាយការណ៍ស្តីពីលទ្ធផលអង្កេតពីភាពមានការងារធ្វើរបស់និស្សិត ស.ភ.ន.វ.ស. ឆ្នាំ២០១៧
9. របាយការណ៍ស្តីពីលទ្ធផលអង្កេតពីភាពមានការងារធ្វើរបស់និស្សិត ស.ភ.ន.វ.ស. ឆ្នាំ២០១៨
10. របាយការណ៍ស្តីពីលទ្ធផលអង្កេតពីភាពមានការងារធ្វើរបស់និស្សិត ស.ភ.ន.វ.ស. ឆ្នាំ២០១៩
11. របាយការណ៍ស្តីពីលទ្ធផលអង្កេតពីភាពមានការងារធ្វើរបស់និស្សិត ស.ភ.ន.វ.ស. ឆ្នាំ ២០២០
12. របាយការណ៍ស្តីពីការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សាឆ្នាំ២០២២ នៃមហាវិទ្យាល័យវិទ្យាសាស្ត្រសេដ្ឋកិច្ច និងគ្រប់គ្រងនៃស.ភ.ន.វ.ស.
13. របាយការណ៍ស្តីពីការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សាឆ្នាំ២០២៣ នៃមហាវិទ្យាល័យវិទ្យាសាស្ត្រសេដ្ឋកិច្ច និងគ្រប់គ្រងនៃស.ភ.ន.វ.ស.
14. www.brainstation.uk/blog/Training/Training/60.
15. en.widipedia.org/wiki/Soft_skills.

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ 1. គោលការណ៍ណែនាំស្តីពីការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
លេខ...៨៥៥.....ស.ភ.ន.វ.ស

**គោលការណ៍ណែនាំ**
**ស្តីពី**
**ការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា**
**នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

ដើម្បីចូលរួមអនុវត្តសកម្មភាពគោលនយោបាយនៃផែនការយុទ្ធសាស្ត្រអប់រំ សំដៅពង្រឹងគុណភាពនៃការបណ្តុះបណ្តាលនៅឧត្តមសិក្សា និងកាត់បន្ថយគម្លាតជំនាញរវាងការបណ្តុះបណ្តាលនៅឧត្តមសិក្សានឹងតម្រូវការទីផ្សារ ព្រមទាំងការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមកម្ពុជា សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច (ស.ភ.ន.វ.ស.) បង្កើតគោលការណ៍ ស្តីពីការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា ដែលមានខ្លឹមសារដូចខាងក្រោម៖

**ជំពូកទី១**
**បទប្បញ្ញត្តិទូទៅ**

**ប្រការ១.-**

គោលការណ៍នេះមានគោលបំណងប្រមូលព័ត៌មានត្រឡប់ពីនិស្សិតក្រោយបញ្ចប់ការសិក្សានៅ ស.ភ.ន.វ.ស. ដើម្បីយកទៅប្រើប្រាស់សម្រាប់កែលម្អគុណភាពអប់រំ ឱ្យឆ្លើយតបទៅនឹងលទ្ធផលរំពឹងទុករបស់កម្មវិធីសិក្សា និងពិនិត្យតាមដានអំពីប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីសិក្សា និងភាពឆ្លើយតបនៃជំនាញដែលបានបណ្តុះបណ្តាលទៅនឹងទីផ្សារការងារ និងភាពប្រែប្រួលនៃស្ថានភាពការងាររបស់និស្សិតបន្ទាប់ពីបញ្ចប់ការសិក្សា។

**ប្រការ២.-**

គោលការណ៍នេះ មានវិសាលភាពអនុវត្តនៅ ស.ភ.ន.វ.ស.។

**ជំពូកទី២**
**ការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា**

**ប្រការ៣.-**

ការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា គឺជាការប្រមូលព័ត៌មានតាមរយៈការស្ទង់មតិជាទម្រង់សរសេរ ឬធ្វើបទសម្ភាសន៍ ជាមួយនិស្សិតដែលទើបបញ្ចប់ការសិក្សា និង/ឬក្នុងអំឡុងពេល

១

Monivong Blvd, Sangkat Tonle Bassac, Khan Chamkamon, Phnom Penh, Cambodia.
P.O. Box 842, Tel: (855) 23 214 703, Fax: (855) 23 214 953, E-mail: rector@rule.edu.kh, website: www.rule.edu.kh

ណាមួយក្រោយបញ្ចប់ការសិក្សា។

**ប្រការ៤.-**

ការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា ផ្តោតលើចំណុចសំខាន់ៗដូចខាងក្រោម៖

- ចំនួននិស្សិតបញ្ចប់ការសិក្សា ដែលបំពេញការងារនៅបណ្តារាជធានី ខេត្ត និងក្រៅប្រទេស
- ចំនួន/ភាគរយនៃនិស្សិតបញ្ចប់ការសិក្សាដែលបានបង្កើតសហគ្រាសធុនតូច/មធ្យម នៅបណ្តារាជធានី ខេត្ត និងក្រៅប្រទេស
- ចំនួន/ភាគរយនៃនិស្សិតទទួលបានបរិមាណប្រាក់ចំណូលពីការចុះធ្វើកម្មសិក្សា
- ចំនួន/ភាគរយនៃនិស្សិតបញ្ចប់ការសិក្សាទទួលបានការងារ ដែលមានកម្រិតប្រាក់បៀវត្ស ឬចំណូល ពី ៥ ទៅ ១០ដង បើប្រៀបធៀបទៅនឹងកម្មករដែលមិនមានជំនាញ
- ចំនួន/ភាគរយនៃនិស្សិតបញ្ចប់ការសិក្សាទទួលបានការងារ ជាអ្នកគ្រប់គ្រងកម្រិតកណ្តាល និងខ្ពស់នៅក្នុងក្រុមហ៊ុនឯកជន អង្គការអន្តរជាតិ និងភ្នាក់ងារផ្នែកកិច្ចសហប្រតិបត្តិការ។

## ជំពូកទី៣
## យន្តការសម្រាប់គ្រប់គ្រងការអនុវត្ត

**ប្រការ៥.-**

ស.ភ.ន.វ.ស. រៀបចំបង្កើតគណៈកម្មការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា។

**ប្រការ៦.-**

សមាសភាពនៃគណៈកម្មការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា រួមមានដូចខាងក្រោម៖

**ក. គណៈកម្មការទទួលបន្ទុករួម**

- ប្រធាន ០១រូប
- អនុប្រធាន ០១ ឬច្រើនរូប
- សមាជិកមួយចំនួនតាមតម្រូវការការងារ

**ខ. អនុគណៈកម្មការគាំទ្រ**

- ប្រធាន ០១រូប
- អនុប្រធាន ០១ ឬច្រើនរូប
- សមាជិកមួយចំនួនតាមតម្រូវការការងារ

**គ. អនុគណៈកម្មការបច្ចេកទេស**

- ប្រធាន ០១ រូប
- អនុប្រធាន ០១ ឬច្រើនរូប
- សមាជិកមួយចំនួនតាមតម្រូវការការងារ

២

ឃ. អនុគណៈកម្មការគណនេយ្យ

- ប្រធាន ០១ រូប
- អនុប្រធាន ០១ ឬច្រើនរូប
- សមាជិកមួយចំនួនតាមតម្រូវការការងារ

**ប្រការ៧.-**

គណៈកម្មការទទួលបន្ទុករួម មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- សម្រេចលើការសិក្សាពីស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា
- ពិនិត្យតាមដានលើការអនុវត្តការងាររបស់អនុគណៈកម្មការនានា ដោយផ្អែកលើផែនការសកម្មភាពដែលបានកំណត់
- រៀបចំបង្កើត ឬកែលំអកម្រងសំណួរដែលត្រូវប្រើប្រាស់ក្នុងការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា ដែលមានការចូលរួមពីអនុគណៈកម្មការនានា
- ពិនិត្យរបាយការណ៍លទ្ធផលនៃការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា ដែលទទួលបានពីអនុគណៈកម្មការគាំទ្រ
- រាយការណ៍ពីលទ្ធផលនៃការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា ជូនប្រធានក្រុមប្រឹក្សាភិបាល
- បង្ហាញលទ្ធផលទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីលើកសំណើ និងការពារថវិកាកម្មវិធីវិនិយោគប្រចាំឆ្នាំ និងភាគីពាក់ព័ន្ធ ក្នុងការកៀរគរមូលនិធិសម្រាប់ការអភិវឌ្ឍគ្រឹះស្ថានឧត្តមសិក្សា
- បំពេញភារកិច្ចផ្សេងទៀតដែលពាក់ព័ន្ធ។

**ប្រការ៨.-**

អនុគណៈកម្មការគាំទ្រ មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- សម្របសម្រួលក្នុងការបង្កើតក្រុមការងារបច្ចេកទេស ដោយមានឈ្មោះ និងកិច្ចការច្បាស់លាស់ ដែលមានការអនុម័តពីសាកលវិទ្យាធិការ
- ជួយកម្រិតគ្រប់គ្រង ក្នុងការពិនិត្យតាមដានលើការអនុវត្តការងារក្រុមការងារបច្ចេកទេសលើការងារសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា ដោយផ្អែកលើផែនការសកម្មភាពដែលបានកំណត់
- ប្រមូលទិន្នន័យនៃស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា ដោយប្រើកម្រងសំណួរដែលបានកំណត់
- ប្រគល់ទិន្នន័យដែលប្រមូលបានខាងលើ ជូនអនុគណៈកម្មការបច្ចេកទេស
- រៀបចំរបាយការណ៍លទ្ធផល នៃការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា ដែលទទួលបានពីក្រុមការងារបច្ចេកទេស ជូនសាកលវិទ្យាធិការ ដើម្បីឯកភាព និងបោះពុម្ព

៣

- សម្របសម្រួលលើការរៀបចំកម្មវិធីផ្សព្វផ្សាយលទ្ធផលក្នុងគ្រឹះស្ថាន និងស្ថាប័នផ្សេងៗ
- បំពេញភារកិច្ចផ្សេងទៀតដែលពាក់ព័ន្ធ។

**ប្រការ៩.-**

អនុគណៈកម្មការបច្ចេកទេស មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- បញ្ចូលទិន្នន័យនៃការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា
- ពិនិត្យ និងវិភាគលទ្ធផលនៃការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា
- រៀបចំរបាយការណ៍លទ្ធផល នៃការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សាជូនសាកលវិទ្យាធិការ ដើម្បីពិនិត្យ និងសម្រេច
- ប្រៀបធៀប និងវិភាគការអនុវត្តកម្រិតកម្មវិធី និងពិនិត្យលើផលជះ នៃការកែលម្អគុណភាពអប់រំដែលបានមកពីកម្មវិធីធ្វើការវិនិយោគ និងមិនបានធ្វើការវិនិយោគ
- ធ្វើបទបង្ហាញផ្សព្វផ្សាយលទ្ធផលដែលទទួលបានក្នុងសាកលវិទ្យាល័យ និងស្ថាប័នពាក់ព័ន្ធ
- បំពេញភារកិច្ចផ្សេងទៀតដែលពាក់ព័ន្ធ។

**ប្រការ១០.-**

អនុគណៈកម្មការគណនេយ្យ មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ពិនិត្យ និងរៀបចំគម្រោងថវិកាសម្រាប់ការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា
- បំពេញភារកិច្ចផ្សេងទៀតដែលពាក់ព័ន្ធ។

## ជំពូកទី៤
## ដំណើរការនៃការអនុវត្ត

**ប្រការ១១.-**

ការប្រមូលទិន្នន័យនៃស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា ត្រូវធ្វើឡើងក្នុងអំឡុងពេល៦ខែ ១ឆ្នាំ ២ឆ្នាំ និង៣ឆ្នាំ សម្រាប់ជំនាន់នីមួយៗទៅតាមមុខជំនាញ បន្ទាប់ពីនិស្សិតបានបញ្ចប់ការសិក្សា។

**ប្រការ១២.-**

ក្រោយពីទទួលបានការសម្រេចលើកាលបរិច្ឆេទ នៃការសិក្សាពីស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា អនុគណៈកម្មការគាំទ្រ ត្រូវចាប់ផ្តើមដំណើរការប្រមូលទិន្នន័យក្នុងរយៈពេល៣សប្តាហ៍ និងត្រូវបញ្ជូនទិន្នន័យដែលប្រមូលបានទៅអនុគណៈកម្មការបច្ចេកទេស។

**ប្រការ១៣.-**

អនុគណៈកម្មការបច្ចេកទេស ត្រូវរៀបចំបញ្ចូល វិភាគទិន្នន័យ និងសរសេររបាយការណ៍លទ្ធផលក្នុងរយៈពេល៣ខែ រួចប្រគល់ជូនសាកលវិទ្យាធិការ ដើម្បីពិនិត្យ និងសម្រេច។

៤

**ប្រការ១៤.-**

គណៈកម្មការទទួលបន្ទុករួម ត្រូវរៀបចំរបាយការណ៍លទ្ធផលនៃការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា ក្នុងរយៈពេល១ខែ និងដាក់ជូនក្រុមប្រឹក្សាភិបាលអនុម័ត។

## ជំពូកទី៥
## ផ្សព្វផ្សាយរបាយការណ៍លទ្ធផល និងប្រើប្រាស់លទ្ធផល

**ប្រការ១៥.-**

បន្ទាប់ពីទទួលបានការអនុម័តពីក្រុមប្រឹក្សាភិបាល គណៈកម្មការទទួលបន្ទុករួម ត្រូវបោះពុម្ព និងផ្សព្វផ្សាយលទ្ធផលនៃការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា ជាមួយភាគីពាក់ព័ន្ធនៅក្នុង និងក្រៅសាកលវិទ្យាល័យ តាមរយៈសិក្ខាសាលា វេទិកាផ្សេងៗ បណ្តាញទំនាក់ទំនងសង្គម និងគេហទំព័ររបស់សាកលវិទ្យាល័យ។

សាកលវិទ្យាល័យ ត្រូវបញ្ជូនរបាយការណ៍លទ្ធផលនៃការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សាទៅក្រសួងអាណាព្យាបាល ជារៀងរាល់ឆ្នាំ។

**ប្រការ១៦.-**

មហាវិទ្យាល័យ ថ្នាក់ក្រោយបរិញ្ញាបត្រ និងផ្នែកពាក់ព័ន្ធ ត្រូវយកលទ្ធផលដែលទទួលបានពីការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា ទៅអភិវឌ្ឍនិងកែលម្អកម្មវិធីសិក្សាសម្រាប់មុខជំនាញដែលពាក់ព័ន្ធ និងកែលម្អកម្រងសំណួរស្រាវជ្រាវលើការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សាសម្រាប់ប្រើប្រាស់នៅឆ្នាំបន្ទាប់។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**ប្រការ១៧.-**

គោលការណ៍នេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៥រោច ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២២

**សាកលវិទ្យាធិការ**

**បណ្ឌិត លុយ ចណ្ណា**

**ចម្លងជូនៈ**

- គ្រប់អង្គភាពចំណុះ ស.ភ.ន.វ.ស. "ដើម្បីមុខការ"
- ឯកសារ កាលប្បវត្តិ

៥

## ឧបសម្ព័ន្ធ 2. លិខិតឧទ្ទេសនាម

1. លិខិតឧទ្ទេសនាមលេខ៧២៨ ស.ភ.ន.វ.ស ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីគណៈកម្មការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
លេខ.១៣៣៤..ស.ភ.ន.វ.ស

### លិខិតឧទ្ទេសនាម

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជាគណៈកម្មការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រគ្រប់ជំនាញ នៃមហាវិទ្យាល័យវិទ្យាសាស្ត្រសេដ្ឋកិច្ច និងគ្រប់គ្រង ក្នុងគោលបំណងប្រមូលព័ត៌មានត្រឡប់ពីនិស្សិតក្រោយបញ្ចប់ការសិក្សា ដើម្បីយកទៅប្រើប្រាស់សម្រាប់កែលម្អគុណភាពអប់រំឱ្យឆ្លើយតបទៅនឹងលទ្ធផលសិក្សារំពឹងទុករបស់កម្មវិធីសិក្សា ពិនិត្យតាមដានអំពីប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីសិក្សា ភាពឆ្លើយតបនៃជំនាញដែលបានបណ្តុះបណ្តាលទៅនឹងទីផ្សារការងារ និងភាពប្រែប្រួលនៃស្ថានភាពការងាររបស់និស្សិតបន្ទាប់ពីបញ្ចប់ការសិក្សា។

I. គណៈកម្មការទទួលបន្ទុក

| | | |
|---|---|---|
| ១. ឯកឧត្តម បណ្ឌិត លុយ ចណ្ណា | សាកលវិទ្យាធិការ | ប្រធាន |
| ២. លោក យិត សួរ៉េច | សាកលវិទ្យាធិការរង | អនុប្រធាន |
| ៣. លោកបណ្ឌិត សឿន សោភ័ណ | សាកលវិទ្យាធិការរង | អនុប្រធាន |
| ៤. លោក ប៊ុន រស្មី | សាកលវិទ្យាធិការរង | អនុប្រធាន |
| ៥. លោកបណ្ឌិត នៀ សុផន | សាកលវិទ្យាធិការរង | អនុប្រធាន |
| ៦. លោកបណ្ឌិត ហាប់ ផល្លី | សាកលវិទ្យាធិការរង | អនុប្រធាន |
| ៧. លោក ឈាង ម៉េងហៀក | ព្រឹទ្ធបុរសមហាវិទ្យាល័យវិទ្យាសាស្ត្រសេដ្ឋកិច្ច និងគ្រប់គ្រង | សមាជិក |
| ៨. លោកស្រី យក់ បញ្ញាតី | ព្រឹទ្ធបុរសរងមហាវិទ្យាល័យវិទ្យាសាស្ត្រសេដ្ឋកិច្ច និងគ្រប់គ្រង | សមាជិកា |

II. អនុគណៈកម្មការគាំទ្រ

| | | |
|---|---|---|
| ៩. លោក ងួន ហេង | ប្រធានដេប៉ាតឺម៉ង់សេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ១០. លោក សៅ ស៊ីវុត្ថា | ប្រធានការិយាល័យសិក្សា | អនុប្រធាន |

1

អាសយដ្ឋាន៖ មហាវិថីព្រះមុនីវង្ស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រទេសកម្ពុជា ប្រអប់សំបុត្រលេខ៖ ៨៤២
ទូរស័ព្ទ (៨៥៥) ២៣ ២១៥ ៧០៣ Email: rector@rule.edu.kh Website: www.rule.edu.kh

| | | |
|---|---|---|
| ១១. លោក អៀន មុនីរដ្ឋ | អនុប្រធានដេប៉ាតឺម៉ង់គណនេយ្យ និងគ្រប់គ្រង | សមាជិក |
| ១២. លោក ហោ បូលីន | គ្រូទទួលបន្ទុកថ្នាក់ | សមាជិក |
| ១៣. កញ្ញា សុផានី ស៊ីនិច | គ្រូទទួលបន្ទុកថ្នាក់ | សមាជិកា |

III. អនុគណៈកម្មការបច្ចេកទេស (បញ្ចូលទិន្នន័យ វិភាគ និងសរសេររបាយការណ៍)

| | | |
|---|---|---|
| ១៤. បណ្ឌិត ង៉ាន់ ស៊ុនដេត | ប្រធានដេប៉ាតឺម៉ង់គណនេយ្យ និងគ្រប់គ្រង | ប្រធាន |
| ១៥. លោក ឈាង ហ៊ុយ | អនុប្រធានដេប៉ាតឺម៉ង់សេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |

**១. គណៈកម្មការទទួលបន្ទុករួម មានតួនាទី និងភារកិច្ចដូចខាងក្រោម៖**

- សម្រេចលើការសិក្សាពីស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា
- ពិនិត្យតាមដានលើការអនុវត្តការងាររបស់អនុគណៈកម្មការនានា ដោយផ្អែកលើផែនការសកម្មភាពដែលបានកំណត់
- រៀបចំបង្កើត ឬកែលំអកម្រងសំណួរដែលត្រូវប្រើប្រាស់ក្នុងការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា ដែលមានការចូលរួមពីអនុគណៈកម្មការនានា
- ពិនិត្យរបាយការណ៍លទ្ធផលនៃការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា ដែលទទួលបានពីអនុគណៈកម្មការគាំទ្រ
- រាយការណ៍ពីលទ្ធផលនៃការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា ជូនប្រធានក្រុមប្រឹក្សាភិបាល
- បង្ហាញលទ្ធផលទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីលើកសំណើ និងការពារថវិកាកម្មវិធីវិនិយោគប្រចាំឆ្នាំ និងភាគីពាក់ព័ន្ធ ក្នុងការកៀរគររកមូលនិធិសម្រាប់ការអភិវឌ្ឍគ្រឹះស្ថានឧត្តមសិក្សា
- បំពេញភារកិច្ចផ្សេងទៀតដែលពាក់ព័ន្ធ។

**២. អនុគណៈកម្មការគាំទ្រ មានតួនាទី និងភារកិច្ចដូចខាងក្រោម៖**

- សម្របសម្រួលក្នុងការបង្កើតក្រុមការងារបច្ចេកទេស ដោយមានឈ្មោះ និងកិច្ចការច្បាស់លាស់ ដែលមានការអនុម័តពីសាកលវិទ្យាធិការ
- ជួយកម្រិតគ្រប់គ្រង ក្នុងការពិនិត្យតាមដានលើការអនុវត្តការងារក្រុមការងារបច្ចេកទេស លើការងារសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា ដោយផ្អែកលើផែនការសកម្មភាពដែលបានកំណត់
- ប្រមូលទិន្នន័យនៃស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា ដោយប្រើកម្រងសំណួរដែលបានកំណត់
- ប្រគល់ទិន្នន័យដែលប្រមូលបានខាងលើ ជូនអនុគណៈកម្មការបច្ចេកទេស

2

| | | |
|---|---|---|
| ១១. លោក អឿន មុនីវង្ស | អនុប្រធានដេប៉ាតឺម៉ង់គណនេយ្យ និងគ្រប់គ្រង | សមាជិក |
| ១២. លោក ហោ បូលីន | គ្រូទទួលបន្ទុកថ្នាក់ | សមាជិក |
| ១៣. កញ្ញា សុផានី ស៊ីនិច | គ្រូទទួលបន្ទុកថ្នាក់ | សមាជិកា |

III. អនុគណៈកម្មការបច្ចេកទេស (បញ្ចូលទិន្នន័យ វិភាគ និងសរសេររបាយការណ៍)

| | | |
|---|---|---|
| ១៤. បណ្ឌិត ង៉ាន់ ស៊ុនដេត | ប្រធានដេប៉ាតឺម៉ង់គណនេយ្យ និងគ្រប់គ្រង | ប្រធាន |
| ១៥. លោក ឈាង ហ៊ុយ | អនុប្រធានដេប៉ាតឺម៉ង់សេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |

**១. គណៈកម្មការទទួលបន្ទុករួម មានតួនាទី និងភារកិច្ចដូចខាងក្រោម៖**

- សម្រេចលើការសិក្សាពីស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា
- ពិនិត្យតាមដានលើការអនុវត្តការងាររបស់អនុគណៈកម្មការនានា ដោយផ្អែកលើផែនការសកម្មភាពដែលបានកំណត់
- រៀបចំបង្កើត ឬកែលំអកម្រងសំណួរដែលត្រូវប្រើប្រាស់ក្នុងការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា ដែលមានការចូលរួមពីអនុគណៈកម្មការនានា
- ពិនិត្យរបាយការណ៍លទ្ធផលនៃការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា ដែលទទួលបានពីអនុគណៈកម្មការគាំទ្រ
- រាយការណ៍ពីលទ្ធផលនៃការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា ជូនប្រធានក្រុមប្រឹក្សាភិបាល
- បង្ហាញលទ្ធផលទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីលើកសំណើ និងការពារថវិកាកម្មវិធីវិនិយោគប្រចាំឆ្នាំ និងភាគីពាក់ព័ន្ធ ក្នុងការកៀរគររកមូលនិធិសម្រាប់ការអភិវឌ្ឍគ្រឹះស្ថានឧត្តមសិក្សា
- បំពេញភារកិច្ចផ្សេងទៀតដែលពាក់ព័ន្ធ។

**២. អនុគណៈកម្មការគាំទ្រ មានតួនាទី និងភារកិច្ចដូចខាងក្រោម៖**

- សម្របសម្រួលក្នុងការបង្កើតក្រុមការងារបច្ចេកទេស ដោយមានឈ្មោះ និងកិច្ចការច្បាស់លាស់ ដែលមានការអនុម័តពីសាកលវិទ្យាធិការ
- ជួយកម្រិតគ្រប់គ្រង ក្នុងការពិនិត្យតាមដានលើការអនុវត្តការងារក្រុមការងារបច្ចេកទេស លើការងារសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា ដោយផ្អែកលើផែនការសកម្មភាពដែលបានកំណត់
- ប្រមូលទិន្នន័យនៃស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា ដោយប្រើកម្រងសំណួរដែលបានកំណត់
- ប្រគល់ទិន្នន័យដែលប្រមូលបានខាងលើ ជូនអនុគណៈកម្មការបច្ចេកទេស

2

- រៀបចំរបាយការណ៍លទ្ធផល នៃការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា ដែលទទួលបានពីក្រុមការងារបច្ចេកទេស ជូនសាកលវិទ្យាធិការ ដើម្បីឯកភាព និងបោះពុម្ព
- សម្របសម្រួលលើការរៀបចំកម្មវិធីផ្សព្វផ្សាយលទ្ធផលក្នុងគ្រឹះស្ថាន និងស្ថាប័នផ្សេងៗ
- បំពេញភារកិច្ចផ្សេងទៀតដែលពាក់ព័ន្ធ។

**៣. អនុគណៈកម្មការបច្ចេកទេស មានតួនាទី និងភារកិច្ចដូចខាងក្រោម៖**

- បញ្ចូលទិន្នន័យនៃការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា
- ពិនិត្យ និងវិភាគលទ្ធផលនៃការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា
- រៀបចំរបាយការណ៍លទ្ធផល នៃការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សាជូន សាកលវិទ្យាធិការ ដើម្បីពិនិត្យ និងសម្រេច
- ប្រៀបធៀប និងវិភាគការអនុវត្តកម្រិតកម្មវិធី និងពិនិត្យលើផលជះ នៃការកែលម្អគុណភាពអប់រំដែលបានមកពីកម្មវិធីធ្វើការវិនិយោគ និងមិនបានធ្វើការវិនិយោគ
- ធ្វើបទបង្ហាញផ្សព្វផ្សាយលទ្ធផលដែលទទួលបានក្នុងសាកលវិទ្យាល័យ និងស្ថាប័នពាក់ព័ន្ធ
- បំពេញភារកិច្ចផ្សេងទៀតដែលពាក់ព័ន្ធ។

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវបំពេញភារកិច្ចតាមការចាត់តាំងនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃអង្គារ ៨កើត ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២៤

**សាកលវិទ្យាធិការ**

**បណ្ឌិត លុយ ចន្ធា**

**កន្លែងទទួល**

គ្រប់អង្គភាពចំណុះ ស.ភ.ន.វ.ស.

"ដើម្បីមុខការ"

សាមីខ្លួន "ដើម្បីអនុវត្ត"

ឯកសារ កាលប្បវត្តិ

3

## ឧបសម្ព័ន្ធ 3. កម្រងសំណួរស្រាវជ្រាវ

សួស្តីនិស្សិតដែលបានបញ្ចប់ការសិក្សានៅសាកលវិទ្យាល័យនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ( RULE )
សូមនិស្សិតដែលបានបញ្ចប់ការសិក្សាមេត្តាជួយឆ្លើយកម្រងសំណួរខាងក្រោមនេះដើម្បីឱ្យថ្នាក់ដឹកនាំសាកលវិទ្យាល័យទទួលបានព័ត៌មានជាក់លាក់ទាក់ទងនឹងការសិក្សា ប្រភេទការងារ ការសិក្សាបន្ថែម ឬសកម្មភាពផ្សេងទៀតចាប់តាំងពីអ្នកបានបញ្ចប់ការសិក្សានៅសាកលវិទ្យាល័យនេះ។ ព័ត៌មានដែលអ្នកបានផ្តល់ជូនតាមរយៈកម្រងសំណួរនេះនឹងជួយដល់សាកលវិទ្យាល័យដើម្បីរៀបចំផែនការបណ្តុះបណ្តាល និងកែលម្អកម្មវិធីសិក្សានាពេលអនាគតឱ្យឆ្លើយតបតាមតម្រូវការទីផ្សារការងារ។ ចម្លើយដែលអ្នកបានផ្តល់ជូននឹងត្រូវរក្សាជាការសម្ងាត់។
សូមថ្លែងអំណរគុណចំពោះការចូលរួមសហការ!

### ១-ព័ត៌មានផ្ទាល់ខ្លួន ៖

- ភេទ : ☐1. ប្រុស ☐2. ស្រី
- ឆ្នាំកំណើត : …………………
- លេខទូរស័ព្ទ : …………………
- អ៊ីម៉ែលហ្វេសបុក/ : …………………
- អតីតសិស្សមកពីវិទ្យាល័យ : ………………… រាជធានី/ខេត្ត: …………………………
- អាសយដ្ឋានបច្ចុប្បន្ន :

…………………………………………………………………………………………………………

### ២- ព័ត៌មានសិក្សា ៖

*សូមបំពេញចម្លើយ ឬ គូសសញ្ញា ✓ ក្នុងប្រអប់នៃចម្លើយ*

១. តើអ្នកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជំនាញអ្វី?

☐1. គ្រប់គ្រងធុរកិច្ច
☐2. សេដ្ឋកិច្ចអភិវឌ្ឍន៍
☐3. គណនេយ្យ
☐4. ធនាគារ និងហិរញ្ញវត្ថុ
☐5. គ្រប់គ្រងទេសចរណ៍ និងបដិសណ្ឋារកិច្ច

២. តើអ្នកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជំនាញខាងលើនៅឆ្នាំណា?

☐1. ឆ្នាំសិក្សា ២០២០-២០២១
☐2. ឆ្នាំសិក្សា ២០២១-២០២២

### ៣. កម្មវិធីបណ្តុះបណ្តាល ៖

*សូមគូសសញ្ញា ✓ ក្នុងតារាងនៃចម្លើយ*

១. សូមអ្នកជួយផ្តល់ចំណាត់ថ្នាក់លើ**បំណិន**ដែលទទួលបានពីកម្មវិធីបណ្តុះបណ្តាលក្នុងពេលសិក្សាដូចខាងក្រោម៖ (1=តិចតួចណាស់ 2=តិចតួច 3=មធ្យម 4=ច្រើន 5=ច្រើនណាស់)

| | 1 | 2 | 3 | 4 | 5 |
|---|---|---|---|---|---|
| ភាពច្នៃប្រឌិត | | | | | |
| ការធ្វើការងារជាក្រុម | | | | | |
| ការគិតពិចារណា | | | | | |
| ការដោះស្រាយបញ្ហា | | | | | |
| សហគ្រិនភាព | | | | | |
| ភាពជាអ្នកដឹកនាំ | | | | | |
| ការសម្រេចចិត្ត | | | | | |
| ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន | | | | | |
| ការទំនាក់ទំនងអន្តរបុគ្គល និងការទទួលខុសត្រូវ | | | | | |
| ភាសាអង់គ្លេស | | | | | |

២. តើអ្នកយល់ថាទ្រឹស្តីដែលបានផ្តល់ក្នុងអំឡុងពេលសិក្សាមានសារៈសំខាន់យ៉ាងណា ចំពោះការងារនាពេលបច្ចុប្បន្ន?

☐1. តិចតួចណាស់

☐2. តិចតួច

☐3. មធ្យម

☐4. ខ្លាំង

☐5. ខ្លាំងណាស់

៣. តើអ្នកយល់ថាការអនុវត្តជំនាញដែលបានផ្តល់ក្នុងអំឡុងពេលសិក្សាមានសារៈសំខាន់យ៉ាងណា ចំពោះការងារនាពេលបច្ចុប្បន្ន?

☐1. តិចតួចណាស់

☐2. តិចតួច

☐3. មធ្យម

☐4. ខ្លាំង

☐5. ខ្លាំងណាស់

៤. តើកម្មវិធីសិក្សានៅ RULE អាចឆ្លើយតបតម្រូវការទីផ្សារការងារបានកម្រិតណា ?

☐1. តិចតួច

☐2. កម្រិតមធ្យម

☐3. កម្រិតបង្គួរ

☐4. ច្រើន

☐5. ច្រើនណាស់

៥. តើអ្នកពេញចិត្តកម្មវិធីសិក្សានៃមុខជំនាញដែលបានសិក្សារួចកម្រិតណា ?

☐1. តិចតួចណាស់

☐2. តិចតួច

☐3. មធ្យម

☐4. ខ្លាំង

☐5. ខ្លាំងណាស់

៦. តើអ្នកបានចុះកម្មសិក្សា/ហាត់ការក្នុងអំឡុងពេលសិក្សាដែរ ឬទេ ?

☐1. បានចុះកម្មសិក្សា/ហាត់ការ

☐2. មិនបានចុះកម្មសិក្សា/ហាត់ការ

៧. បើបានចុះកម្មសិក្សា/ហាត់ការ តើអ្នកយល់យ៉ាងណាចំពោះរយៈពេលនៃការចុះកម្មសិក្សាក្នុងអំឡុងពេលសិក្សា ?

☐1. ខ្លីពេក

☐2. សមស្រប

☐3. វែងពេក

៨. តើការចុះកម្មសិក្សាក្នុងអំឡុងពេលសិក្សាអាចជួយឱ្យអ្នកយល់ពីទ្រឹស្តីកម្រិតណា ?

☐1. តិចតួចណាស់

☐2. តិចតួច

☐3. មធ្យម

☐4. ខ្លាំង

☐5. ខ្លាំងណាស់

៩. តើការចុះកម្មសិក្សាក្នុងអំឡុងពេលសិក្សាអាចជួយអ្នកពង្រឹងការអនុវត្តជាក់ស្តែងលើមុខជំនាញដែលបានសិក្សាកម្រិតណា ?

☐1. តិចតួចណាស់

☐2. តិចតួច

☐3. មធ្យម

☐4. ខ្លាំង

☐5. ខ្លាំងណាស់

១០. តើអ្នកបានទទួលប្រាក់ឧបត្ថម្ភពីការចុះកម្មសិក្សាក្នុងអំឡុងពេលសិក្សាឬទេ?

☐1. មិនបានទទួលប្រាក់ឧបត្ថម្ភ

☐2. ក្រុមហ៊ុន/ស្ថាប័នផ្តល់អាហារូបករណ៍ថ្លៃសិក្សាមួយផ្នែក

☐3. ក្រុមហ៊ុន/ស្ថាប័នផ្តល់អាហារូបករណ៍ថ្លៃសិក្សាទាំងស្រុង

១១. ករណីបានទទួលប្រាក់ឧបត្ថម្ភជាមធ្យមប្រចាំខែពីក្រុមហ៊ុន/ស្ថាប័នពេលចុះកម្មសិក្សា តើបានចំនួនប៉ុន្មាន?

........................................................................................................................................

## ៤. ស្ថានភាពការងារ៖

***សូមបំពេញចម្លើយ ឬ គូសសញ្ញា ✓ ក្នុងប្រអប់នៃចម្លើយ***

១. តើអ្នកកំពុងធ្វើការងារអ្វីនាបច្ចុប្បន្ននេះ?

☐1. មិនមានការងារធ្វើ/មិនមានអាជីវកម្មផ្ទាល់ខ្លួន

☐2. មានការងារធ្វើ

☐3. អាជីវកម្មផ្ទាល់ខ្លួន

☐4. មានការងារធ្វើផង និងមានអាជីវកម្មផ្ទាល់ខ្លួន

☐5. មានការងារធ្វើផ្សេងៗ

☐6. បន្តការសិក្សា

☐7. ព្រះសង្ឃ

☐8. ផ្សេងៗ

២. ករណីអ្នកមានការងារធ្វើ តើការងារពេញម៉ោង ឬមិនពេញម៉ោង?

☐1. ការងារពេញម៉ោង

☐2. ការងារមិនពេញម៉ោង

៣. ករណីអ្នកមានអាជីកម្មផ្ទាល់ខ្លួន តើជាប្រភេទអាជីកម្មមួយណា?

☐1. សហគ្រាសធុនតូចផ្ទាល់ខ្លួន

☐2. សហគ្រាសធុនមធ្យមផ្ទាល់ខ្លួន

☐3. សហគ្រាសធុនធំផ្ទាល់ខ្លួន

☐4. ផ្សេងៗ

៤. តើអ្នកទទួលបានការងារធ្វើនៅកន្លែង ដែលអ្នកបានចុះកម្មសិក្សា/ហាត់ការដែរឬទេក្រោយពីបានបញ្ចប់

ការសិក្សា?

☐1. បាន

☐2. មិនបាន

៥. តើអ្នកធ្វើការងារក្នុងស្ថាប័នប្រភេទណា?

☐1. រដ្ឋ

☐2. ឯកជន

☐3. អង្គការជាតិ

☐4. អង្គការអន្តរជាតិ

☐5. ភ្នាក់ងារសហប្រតិបត្តិការ

☐6. ផ្សេងៗ

៦. តើអ្នកបំពេញការងារក្នុងឋានៈឬតួនាទីប្រភេទណា?

☐1. បុគ្គលិកទូទៅ

☐2. បុគ្គលិកបច្ចេកទេស

☐3. អ្នកគ្រប់គ្រងកម្រិតទាប

☐4. អ្នកគ្រប់គ្រងកម្រិតកណ្ដាល

☐5. អ្នកគ្រប់គ្រងកម្រិតខ្ពស់

៧. តើការងារ/អាជីវកម្មផ្ទាល់ខ្លួនរបស់អ្នកមានទីតាំងនៅទីណា?

..............................................................................................................................................

៨. ករណីមានការងារ/អាជីវកម្មផ្ទាល់ខ្លួននៅបរទេស សូមសរសេរឈ្មោះប្រទេសនោះ

..............................................................................................................................................

៩. តើអ្នកចំណាយពេលប៉ុន្មានដើម្បីទទួលបានការងារធ្វើបន្ទាប់ពីបានបញ្ចប់ការសិក្សា?

☐1. មានការងារធ្វើមុនពេលបញ្ចប់ការសិក្សា

☐2. តិចជាង១ខែ

☐3. ចន្លោះពី១ខែ ទៅ៣ខែ

☐4. ចន្លោះពី៣ខែ ទៅ៦ខែ

☐5. ចន្លោះពី៦ខែ ទៅ៩ខែ

☐6. ចន្លោះពី៩ខែ ទៅ១២ខែ

☐7. លើសពី១២ខែ

១០. តើអ្នកចំណាយពេលប៉ុន្មានដើម្បីបង្កើតអាជីវកម្មផ្ទាល់ខ្លួនបន្ទាប់ពីបានបញ្ចប់ការសិក្សា?

☐1. មុនពេលបញ្ចប់ការសិក្សា

☐2. តិចជាង១ខែ

☐3. ចន្លោះពី១ខែ ទៅ៣ខែ

☐4. ចន្លោះពី៣ខែ ទៅ៦ខែ

☐5. ចន្លោះពី៦ខែ ទៅ៩ខែ

☐6. ចន្លោះពី៩ខែ ទៅ១២ខែ

☐7. លើសពី១២ខែ

១១. តើអ្នកបានទទួលការងារស្របតាមជំនាញឬទេ?

☐1. ស្របតាមជំនាញ

☐2. មិនស្របតាមជំនាញ

១២. តើអ្នកបង្កើតអាជីវកម្មផ្ទាល់ខ្លួនស្របតាមជំនាញឬទេ?

☐1. ស្របតាមជំនាញ

☐2. មិនស្របតាមជំនាញ

១៣. តើអ្នកបានទទួលប្រាក់ចំណូលចំនួនប៉ុន្មានក្នុង១ខែ?

☐1. តិចជាង ២០០$

☐2. ២០០$ - ៤០០$

☐3. ៤០១$- ៦០០$

☐4. ៦០១$- ៨០០$

☐5. ៨០១$- ១០០០$

☐6. ច្រើនជាង ១០០០$

១៤. ករណីអ្នកធ្វើការងារមិនស្របតាមជំនាញ តើបណ្តាលមកពីកត្តាអ្វីសំខាន់ជាងគេ?

☐1. ប្រាក់ចំណូលច្រើន

☐2. ទីផ្សារពលកម្មចង្អៀត

☐3. មានអាជីវកម្មផ្ទាល់ខ្លួន

☐4. តាមតម្រូវការទីផ្សារ

☐5. ចំណង់ចំណូលចិត្ត

☐6. ផ្សេងៗ

១៥. ករណីមិនទាន់មានការងារធ្វើ តើបណ្តាលមកពីកត្តាអ្វី?

☐1. ពិបាករកការងារធ្វើ

☐2. ការងារខុសជំនាញ

☐3. កំពុងរៀនបន្ត

☐4. មានគ្រួសារ

☐5. ផ្លាស់ប្តូរទីលំនៅ

☐6. ផ្សេងៗ

## ៥ .តម្រូវការមុខជំនាញ៖

១. តើអ្នកយល់យ៉ាងណាចំពោះតម្រូវការជំនាញ សម្រាប់ការងារដែលខ្លួនកំពុងធ្វើបច្ចុប្បន្ននេះ?

(1=មានតិចតួច 2=មានមធ្យម 3=មានច្រើនបង្គួរ 4=មានច្រើន 5=មានច្រើនណាស់)

| | 1 | 2 | 3 | 4 | 5 |
|---|---|---|---|---|---|
| សមត្ថភាពបង្កើតគំនិត និងដំណោះស្រាយថ្មីៗ | | | | | |
| សមត្ថភាពសម្របខ្លួនតាមការផ្លាស់ប្តូរស្ថានភាព | | | | | |
| ការគិតត្រិះរិះពិចារណា | | | | | |
| សមត្ថភាពធ្វើការដើម្បីឆ្ពោះទៅរកគោលដៅ | | | | | |
| សមត្ថភាពធ្វើការងារជាក្រុម | | | | | |
| សមត្ថភាពទំនាក់ទំនងអន្តរបុគ្គល(ទាំងការនិយាយ និងសរសេរ) | | | | | |
| ចំណេះដឹងផ្នែកបច្ចេកវិទ្យាព័ត៌មាន | | | | | |
| សម្ថភាពក្នុងការដឹកនាំ | | | | | |

២. បើតាមការវាយតម្លៃជាក់ស្តែង តើអ្នកបានប្រើប្រាស់ចំណេះដឹង និងជំនាញផ្នែកលើសញ្ញាបត្របាន កម្រិតណា សម្រាប់បំពេញការងាររបស់ខ្លួនក្នុងពេលបច្ចុប្បន្ន?

☐1. ប្រើតិចតួច

☐2. ប្រើមធ្យម

☐3. ប្រើច្រើនបង្គួរ

☐4. ប្រើច្រើន

☐5. ប្រើច្រើនណាស់

## ៦ .ព័ត៌មានត្រឡប់ ៖

១. តើអ្នក គិតថាសាកលវិទ្យាល័យបានជួយអ្នកកម្រិតណា ដើម្បីទទួលបានការងារធ្វើ?

☐1. បានជួយតិចតួច

☐2. បានជួយមធ្យម

☐3. បានជួយបង្គួរ

☐4. បានជួយច្រើន

☐5. បានជួយច្រើនណាស់

២. តើអ្នកបានទទួលការបណ្តុះបណ្តាលបន្ថែមពីកន្លែងការងារបច្ចុប្បន្នរបស់អ្នកដែរឬទេ?

☐1. បានទទួល

☐2. មិនបានទទួល

៣. ប្រសិនបើបានទទួលការបណ្តុះបណ្តាល តើអ្នកបានផ្តល់ការបណ្តុះបណ្តាលអ្វី?

.......................................................................................................................................

៤. អ្នកបាន និងកំពុងសិក្សាជំនាញខ្លីៗតាមរយៈអ្វី?

☐1. ខ្លួនឯង

☐2. ពីស្ថាប័នកំពុងបម្រើការងារ

☐3. ផ្សេងៗ

☐4. អត់បានទទួល

៥. អ្នកបាន និងកំពុងសិក្សាកម្រិតបរិញ្ញាបត្រផ្សេងទៀត និង/ឬបរិញ្ញាបត្រជាន់ខ្ពស់ដែរឬទេ?

☐1. បានរៀន និងបញ្ចប់ដោយជោគជ័យ

☐2. កំពុងសិក្សា

☐3. មិនបានបន្តការសិក្សា

៦. តើអ្នកបាន និងកំពុងសិក្សាកម្រិតបរិញ្ញាបត្រផ្សេងទៀត និង/ឬបរិញ្ញាបត្រជាន់ខ្ពស់លើមុខជំនាញអ្វី?

.......................................................................................................................................

៧. អ្នកបានចូលរួមក្នុងសកម្មភាពសង្គមបានកម្រិតណា ក្រោយបញ្ចប់ការសិក្សានៅ RULE?

☐1. ពុំបាន

☐2. បានតិចតួច

☐3. បានកម្រិតមធ្យម

☐4. បានច្រើន

☐5. បានច្រើនណាស់

៨. យោបល់ស្ថាបនា ប្រសិនបើមាន។

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

**សូមអរគុណចំពោះការសហការ!**